(១៧៨) យេ កេចិ ទុក្ខន្តិ វាចំ ភាសន្តិ សព្វេ តេ មគ្គំ ភាវេន្តីតិ ។ អាមន្តា ។ ពាលបុថុជ្ជនា ទុក្ខន្តិ វាចំ ភាសន្តិ ពាលបុថុជ្ជនា មគ្គំ ភាវេន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មាតុឃាតកោ ។ បេ ។ បិតុឃាតកោ អរហន្តឃាតកោ រុហិរុប្បាទកោ(១) ។ បេ ។ សង្ឃភេទកោ ទុក្ខន្តិ វាចំ ភាសតិ សង្ឃភេទកោ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ទុក្ខាហារកថា ។

ចិត្តដ្ឋិតិកថា

(១៧៩) ឯកំ ចិត្តំ ទិវសំ តិដ្ឋតីតិ ។ អាមន្តា ។ ឧបឌ្ឍទិវសោ ឧប្បាទក្ខណោ ឧបឌ្ឍទិវសោ វយក្ខណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

១ ម. លោហិតុប្បាទកោ ។

ទុក្ខាហារកថា

(១៧៧) ការនាំមកនូវញាណ (ការថើង) ក្នុងទុក្ខ ជាអង្គនៃមគ្គ ដែលរាប់បញ្ចូលក្នុងមគ្គឬ ។ អើ ។ ពួកជនណាមួយ ពោលពាក្យថា ទុក្ខ ជនទាំងអស់នោះ តែងចំរើននូវមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៧៨) ពួកជនណាមួយ ពោលពាក្យថា ទុក្ខ ជនទាំងអស់នោះ តែងចំរើននូវមគ្គឬ ។ អើ ។ ពួកពាលបុថុជ្ជន ពោលពាក្យថា ទុក្ខ ពួកពាលបុថុជ្ជន តែងចំរើននូវមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ជនអ្នកសម្លាប់មាតា ។ បេ ។ ជនអ្នកសម្លាប់បិតា ជនអ្នកសម្លាប់ព្រះអរហន្ត ជនអ្នកធ្វើព្រះលោហិតឲ្យពុះពោរឡើង ។ បេ ។ ជនអ្នកបំបែកសង្ឃ ពោលពាក្យថា ទុក្ខ ជនអ្នកបំបែកសង្ឃ តែងចំរើននូវមគ្គដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ទុក្ខាហារកថា ។

ចិត្តដ្ឋិតិកថា

(១៧៩) ចិត្តមួយ ឋិតនៅអស់មួយថ្ងៃឬ ។ អើ ។ កន្លះថ្ងៃ ជាឧប្បាទក្ខណៈ កន្លះថ្ងៃ ជាវយក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៨០) ឯកំ ចិត្តំ ទ្វេ ទិវសេ តិដ្ឋតីតិ ។ អាមន្តា ។ ទិវសោ ឧប្បាទក្ខណោ ទិវសោ វយក្ខណោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

(១៨១) ឯកំ ចិត្តំ ចត្តារោ ទិវសេ តិដ្ឋតិ ។បេ ។ អដ្ឋ ទិវសេ តិដ្ឋតិ ទស ទិវសេ តិដ្ឋតិ វីសតិ ទិវសេ តិដ្ឋតិ មាសំ តិដ្ឋតិ ទ្វេ មាសេ តិដ្ឋតិ ចត្តារោ មាសេ តិដ្ឋតិ អដ្ឋ មាសេ តិដ្ឋតិ ទស មាសេ តិដ្ឋតិ សំវច្ឆរំ តិដ្ឋតិ ទ្វេ វស្សានិ តិដ្ឋតិ ចត្តារិ វស្សានិ តិដ្ឋតិ អដ្ឋ វស្សានិ តិដ្ឋតិ ទស វស្សានិ តិដ្ឋតិ វីសតិ វស្សានិ តិដ្ឋតិ តឹស វស្សានិ តិដ្ឋតិ ចត្តាឡីស វស្សានិ តិដ្ឋតិ បញ្ញាស វស្សានិ តិដ្ឋតិ វស្សសតំ តិដ្ឋតិ ទ្វេ វស្សសតានិ តិដ្ឋតិ ចត្តារិ វស្សសតានិ តិដ្ឋតិ បញ្ច វស្សសតានិ តិដ្ឋតិ វស្សសហស្សំ តិដ្ឋតិ ទ្វេ វស្សសហស្សានិ តិដ្ឋតិ ចត្តារិ វស្សសហស្សានិ តិដ្ឋតិ អដ្ឋ វស្សសហស្សានិ តិដ្ឋតិ សោឡស វស្សសហស្សានិ តិដ្ឋតិ កប្បំ តិដ្ឋតិ ទ្វេ កប្បេ តិដ្ឋតិ ចត្តារោ កប្បេ តិដ្ឋតិ អដ្ឋ កប្បេ តិដ្ឋតិ

(១៨០) ចិត្តមួយ ឋិតនៅអស់ពីរថ្ងៃឬ ។ អើ ។ មួយថ្ងៃ ជាឧប្បាទក្ខណៈ មួយថ្ងៃ ជាវយក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។

(១៨១) ចិត្តមួយ ឋិតនៅអស់៤ថ្ងៃ ។បេ ។ ឋិតនៅអស់៨ថ្ងៃ ឋិតនៅអស់១០ថ្ងៃ ឋិតនៅអស់២០ថ្ងៃ ឋិតនៅអស់១ខែ ឋិតនៅអស់ ២ ខែ ឋិតនៅអស់៤ខែ ឋិតនៅអស់៨ខែ ឋិតនៅអស់១០ខែ ឋិតនៅអស់១ឆ្នាំ ឋិតនៅអស់២ឆ្នាំ ឋិតនៅអស់ ៤ ឆ្នាំ ឋិតនៅអស់៨ ឆ្នាំ ឋិតនៅអស់ ១០ ឆ្នាំ ឋិតនៅអស់ ២០ ឆ្នាំ ឋិតនៅអស់ ៣០ ឆ្នាំ ឋិតនៅអស់ ៤០ ឆ្នាំ ឋិតនៅអស់ ៥០ ឆ្នាំ ឋិតនៅអស់ ១០០ ឆ្នាំ ឋិតនៅអស់ ២០០ ឆ្នាំ ឋិតនៅអស់ ៤០០ ឆ្នាំ ឋិតនៅអស់ ៥០០ ឆ្នាំ ឋិតនៅអស់ ១០០០ ឆ្នាំ ឋិតនៅអស់ ២០០០ ឆ្នាំ ឋិតនៅអស់ ៤០០០ ឆ្នាំ ឋិតនៅអស់ ៨.០០០ ឆ្នាំ ឋិតនៅអស់ ១៦.០០០ ឆ្នាំ ឋិតនៅអស់ ១ កប្ប ឋិតនៅអស់ ២ កប្ប ឋិតនៅអស់ ៤ កប្ប ឋិតនៅអស់ ៨ កប្ប

សោឡស កប្បេ តិដ្ឋតិ ទ្វត្តឹស កប្បេ តិដ្ឋតិ ចតុ-
សដ្ឋី កប្បេ តិដ្ឋតិ បញ្ច កប្បសតានិ តិដ្ឋតិ កប្ប-
សហស្សំ តិដ្ឋតិ ទ្វេ កប្បសហស្សានិ តិដ្ឋតិ ចត្តារិ
កប្បសហស្សានិ តិដ្ឋតិ អដ្ឋ កប្បសហស្សានិ តិដ្ឋតិ
សោឡស កប្បសហស្សានិ តិដ្ឋតិ វីសតិ កប្បស-
ហស្សានិ តិដ្ឋតិ ចត្តាឡីស កប្បសហស្សានិ តិដ្ឋតិ
សដ្ឋី កប្បសហស្សានិ តិដ្ឋតិ ។បេ។ ចតុរាសីតិ
កប្បសហស្សានិ តិដ្ឋតីតិ ។ អាមន្តា ។ ទ្វេ ចត្តា-
ឡីស កប្បសហស្សានិ ឧប្បាទក្ខណោ ទ្វេ ចត្តា-
ឡីស កប្បសហស្សានិ វយក្ខណោតិ ។ ន ហេវំ
វត្តព្វេ ។បេ។

[១៨២] ឯកំ ចិត្តំ ទិវសំ តិដ្ឋតីតិ ។ អា-
មន្តា ។ អត្ថញ្ញេ ធម្មា ឯកាហំ ពហុម្បិ ឧប្បជ្ជិត្វា
និរុជ្ឈន្តីតិ ។ អាមន្តា ។ តេ ធម្មា ចិត្តេន លហុប-
រិវត្តាតិ ។ ន ហេវំ វត្តព្វេ ។បេ។

[១៨៣] តេ ធម្មា ចិត្តេន លហុបរិវត្តាតិ ។
អាមន្តា ។ ននុ វុត្តំ ភគវតា នាហំ ភិក្ខវេ អញ្ញំ
ឯកំ ធម្មម្បិ សមនុបស្សាមិ យំ ឯវំ លហុបរិវត្តំ

ឋិតនៅអស់ ១៦ កប្ប ឋិតនៅអស់ ៣២ កប្ប ឋិតនៅអស់ ៦៤ កប្ប
ឋិតនៅអស់ ៥ រយកប្ប ឋិតនៅអស់ ១ ពាន់កប្ប ឋិតនៅអស់ ២ ពាន់
កប្ប ឋិតនៅអស់ ៤ ពាន់កប្ប ឋិតនៅអស់ ៨ ពាន់កប្ប ឋិតនៅអស់
១៦ ពាន់កប្ប ឋិតនៅអស់ ២០ ពាន់កប្ប ឋិតនៅអស់ ៤០ ពាន់កប្ប ឋិត
នៅអស់ ៦០ ពាន់កប្ប ។បេ។ ឋិតនៅអស់ ៨៤ ពាន់កប្បឬ ។ អើ ។
៤២ ពាន់កប្ប ជាឧប្បាទក្ខណៈ ៤២ ពាន់កប្ប ជាវយក្ខណៈឬ ។ អ្នក
មិនគួរពោលយ៉ាងនេះទេ ។បេ។

(១៨២) ចិត្តមួយ ឋិតនៅអស់ ១ ថ្ងៃឬ ។ អើ ។ ពួកធម៌
ដទៃ ដែលកើតឡើងអស់ ១ ថ្ងៃ ឬច្រើនថ្ងៃ ហើយរលត់ទៅវិញ មាន
ដែរឬ ។ អើ ។ ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តដែរឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(១៨៣) ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តដែរឬ ។
អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត
ពិចារណាក៏មិនឃើញ នូវធម៌ដទៃ សូម្បីតែមួយ ដែលប្រព្រឹត្តទៅរហ័ស

យថយិទំ ភិក្ខវេ ចិត្តំ យាវញ្ចិទំ ភិក្ខវេ ឧបមាបិ ន សុករា យាវ លហុបរិវត្តំ ចិត្តន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ តេ ធម្មា ចិត្តេន លហុបរិវត្តាតិ ។

(១៨៦) តេ ធម្មា ចិត្តេន លហុបរិវត្តាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សេយ្យថាបិ ភិក្ខវេ មក្កដោ អរញ្ញេ បវនេ ចរមានោ សាខំ គណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ គណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ គណ្ហាតិ ឯវមេវ ខោ ភិក្ខវេ យមិទំ វុច្ចតិ ចិត្តំ ឥតិបិ មនោ ឥតិបិ វិញ្ញាណំ ឥតិបិ តំ រត្តិយា ច ទិវសស្ស ច អញ្ញទេវ ឧប្បជ្ជតិ អញ្ញំ និរុជ្ឈតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ តេ ធម្មា ចិត្តេន លហុបរិវត្តាតិ ។

(១៨៧) ឯកំ ចិត្តំ ទិវសំ តិដ្ឋតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ ទិវសំ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតវិញ្ញាណំ ។ បេ ។ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ អកុសលំ ចិត្តំ រាគសហគតំ ទោសសហគតំ មោហសហគតំ

យ៉ាងនេះ ដូចជាចិត្តនេះទេ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះ ប្រព្រឹត្តទៅរហ័ស មិនងាយបុគ្គលនឹងធ្វើសេចក្តីប្រៀបបានឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តទេ ។

(១៨៦) ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វស្វា ត្រាច់ទៅក្នុងព្រៃតូច ព្រៃធំ ចាប់កាន់មែកឈើ លែងមែកឈើនោះ ហើយចាប់មែកដទៃ លែងមែកនោះហើយ ចាប់មែកដទៃ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណា ហៅថាចិត្តដូច្នេះក្តី ហៅថាមនោដូច្នេះក្តី ហៅថាវិញ្ញាណដូច្នេះក្តី ធម្មជាតនោះ ជាធម្មជាតដទៃមែនពិត កើតឡើងក្នុងវេលាយប់ផង ក្នុងវេលាថ្ងៃផង ធម្មជាតដទៃរលត់ទៅវិញផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តទេ ។

(១៨៧) ចិត្តមួយ ឋិតនៅអស់១ថ្ងៃឬ ។ អើ ។ ចក្ខុវិញ្ញាណ ឋិតនៅអស់១ថ្ងៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សោតវិញ្ញាណ ។ បេ ។ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ អកុសលចិត្ត ចិត្តដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ

មានសហគតំ ទិដ្ឋិសហគតំ វិចិកិច្ឆាសហគតំ ថីនស-
ហគតំ ឧទ្ធច្ចសហគតំ អហិរិកសហគតំ អនោត្តប្បស-
ហគតំ ចិត្តំ ទិវសំ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៨៦) ឯកំ ចិត្តំ ទិវសំ តិដ្ឋតីតិ ។ អា-
មន្តា ។ យេនេវ ចិត្តេន ចក្ខុនា រូបំ បស្សតិ តេនេវ
ចិត្តេន សោតេន សទ្ទំ សុណាតិ ។ បេ ។ ឃានេន
គន្ធំ ឃាយតិ ជិវ្ហាយ រសំ សាយតិ កាយេន ផោ-
ដ្ឋព្វំ ផុសតិ ។ បេ ។ មនសា ធម្មំ វិជានាតិ ។ បេ ។
យេនេវ ចិត្តេន មនសា ធម្មំ វិជានាតិ តេនេវ ចិត្តេន
ចក្ខុនា រូបំ បស្សតិ ។ បេ ។ សោតេន សទ្ទំ សុណាតិ
ឃានេន គន្ធំ ឃាយតិ ជិវ្ហាយ រសំ សាយតិ ។ បេ ។
កាយេន ផោដ្ឋព្វំ ផុសតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៨៧) ឯកំ ចិត្តំ ទិវសំ តិដ្ឋតីតិ ។ អាមន្តា ។
យេនេវ ចិត្តេន អភិក្កមតិ តេនេវ ចិត្តេន បដិក្កមតិ
យេនេវ ចិត្តេន បដិក្កមតិ តេនេវ ចិត្តេន អភិក្ក-
មតិ យេនេវ ចិត្តេន អាលោកេតិ តេនេវ ចិត្តេន
វិលោកេតិ យេនេវ ចិត្តេន វិលោកេតិ តេនេវ
ចិត្តេន អាលោកេតិ យេនេវ ចិត្តេន សម្មិញ្ជេតិ

៦៨

ប្រកបដោយមានះ ប្រកបដោយទិដ្ឋិ ប្រកបដោយវិចិកិច្ឆា ប្រកបដោយ
ថីនៈ ប្រកបដោយឧទ្ធច្ចៈ ប្រកបដោយអហិរិកៈ ប្រកបដោយអនោត្តប្បៈ
ឋិតនៅអស់១ថ្ងៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៨៦) ចិត្តមួយ ឋិតនៅអស់១ថ្ងៃឬ ។ អើ ។ បុគ្គលឃើញ
រូបដោយភ្នែក ដោយចិត្តណា ក៏ឮសំឡេងដោយត្រចៀក ដោយចិត្ត
នោះដែរ ។ បេ ។ ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្តាត ពាល់
ត្រូវផ្សព្វដោយកាយ ។ បេ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត ។ បេ ។
បុគ្គលដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត ដោយចិត្តណា ក៏ឃើញរូបដោយ
ភ្នែក ដោយចិត្តនោះដែរ ។ បេ ។ ឮសំឡេងដោយត្រចៀក ធុំក្លិនដោយ
ច្រមុះ លិទ្ធភ្លក្សរសដោយអណ្តាត ។ បេ ។ ពាល់ត្រូវផ្សព្វដោយកាយ
(ដោយចិត្តនោះ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៨៧) ចិត្តមួយ ឋិតនៅអស់១ថ្ងៃឬ ។ អើ ។ បុគ្គល ឈាន
ទៅមុខ ដោយចិត្តណា ឈានថយមកក្រោយ ដោយចិត្តនោះដែរ ឈានថយ
មកក្រោយ ដោយចិត្តណា ឈានទៅមុខ ដោយចិត្តនោះដែរ មើលទៅមុខ
ដោយចិត្តណា មើលចំហៀង ដោយចិត្តនោះដែរ មើលចំហៀង ដោយ
ចិត្តណា មើលទៅមុខ ដោយចិត្តនោះដែរ បត់អវយវៈចូល ដោយចិត្តណា

តេនេវ ចិត្តេន បសាវតិ យេនេវ ចិត្តេន បសាវតិ តេនេវ ចិត្តេន សម្មញ្ចតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៨៨) អាកាសានញ្ចាយតនូបគានំ ទេវានំ ឯកំ ចិត្តំ យាវតាយុកំ តិដ្ឋតីតិ ។ អាមន្តា ។ មនុស្សានំ ឯកំ ចិត្តំ យាវតាយុកំ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៨៩) អាកាសានញ្ចាយតនូបគានំ ទេវានំ ឯកំ ចិត្តំ យាវតាយុកំ តិដ្ឋតីតិ ។ អាមន្តា ។ ចាតុម្មហារាជិកានំ ទេវានំ ។ បេ ។ តាវត្តឹសានំ ទេវានំ ... យាមានំ ទេវានំ ... តុសិតានំ ទេវានំ ... និម្មានរតីនំ ទេវានំ ... បរនិម្មិតវសវត្តីនំ ទេវានំ ... ព្រហ្មបារិសជ្ជានំ ទេវានំ ... ព្រហ្មបុរោហិតានំ ទេវានំ ... មហាព្រហ្មានំ ទេវានំ ... បរិត្តាភានំ ទេវានំ ... អប្បមាណាភានំ ទេវានំ ... អាភស្សរានំ ទេវានំ ... បរិត្តសុភានំ ទេវានំ ...

លោកយោះចេញ ដោយចិត្តនោះដែរ លោកយោះចេញ ដោយចិត្តណា លោកយោះចូល ដោយចិត្តនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៨៨) ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងឋានអាកាសានញ្ចាយតនៈ ឋិតនៅដរាបដល់អស់អាយុដែរឬ ។ អើ ។ ចិត្តមួយ របស់មនុស្សទាំងឡាយ ឋិតនៅដរាបដល់អស់អាយុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៨៩) ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងឋានអាកាសានញ្ចាយតនៈ ឋិតនៅដរាបដល់អស់អាយុដែរឬ ។ អើ ។ ចិត្តមួយ របស់ពួកទេវតាដែលឋិតនៅក្នុងឋានចាតុម្មហារាជិកា ។ បេ ។ របស់ពួកទេវតា ដែលឋិតនៅក្នុងឋានតាវត្តិង្ស ... ពួកទេវតា ដែលឋិតនៅក្នុងឋានយាមៈ ... ពួកទេវតា ដែលឋិតនៅក្នុងឋានតុសិត ... ពួកទេវតា ដែលឋិតនៅក្នុងឋាននិម្មានរតី ... ពួកទេវតា ដែលឋិតនៅក្នុងឋានបរនិម្មិតវសវត្តី ... ពួកទេវតា ដែលឋិតនៅក្នុងឋានព្រហ្មបារិសជ្ជា ... ពួកទេវតា ដែលឋិតនៅក្នុងឋានព្រហ្មបុរោហិត ... ពួកទេវតា ដែលឋិតនៅក្នុងឋានមហាព្រហ្ម ... ពួកទេវតា ដែលឋិតនៅក្នុងឋានបរិត្តាភា ... ពួកទេវតា ដែលឋិតនៅក្នុងឋានអប្បមាណាភា ... ពួកទេវតា ដែលឋិតនៅក្នុងឋានអាភស្សរៈ ... ពួកទេវតា ដែលឋិតនៅក្នុងឋានបរិត្តសុភា ...

អប្បមាណាសុភានំ ទេវានំ ... សុភកិណ្ហានំ ទេវានំ ... វេហប្ផលានំ ទេវានំ ... អវិហានំ ទេវានំ ... អតប្បានំ ទេវានំ ... សុទស្សានំ ទេវានំ ... សុទស្សីនំ ទេវានំ ។ បេ ។ អកនិដ្ឋានំ ទេវានំ ឯកំ ចិត្តំ យាវតាយុកំ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៩០) អាកាសានញ្ចាយតនូបគានំ ទេវានំ វីសតិ កប្បសហស្សានិ អាយុប្បមាណំ អាកាសានញ្ចាយតនូបគានំ ទេវានំ ឯកំ ចិត្តំ វីសតិ កប្បសហស្សានិ តិដ្ឋតីតិ ។ អាមន្តា ។ មនុស្សានំ វស្សសតំ អាយុប្បមាណំ មនុស្សានំ ឯកំ ចិត្តំ វស្សសតំ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៩១) អាកាសានញ្ចាយតនូបគានំ ទេវានំ វីសតិ កប្បសហស្សានិ អាយុប្បមាណំ អាកាសានញ្ចាយតនូបគានំ ទេវានំ ឯកំ ចិត្តំ វីសតិ កប្បសហស្សានិ តិដ្ឋតីតិ ។ អាមន្តា ។ ចាតុម្មហារាជិកានំ ទេវានំ បញ្ច វស្សសតានិ អាយុប្បមាណំ

ពួកទេវតា ដែលឋិតនៅក្នុងឋានអប្បមាណាសុភា ... ពួកទេវតា ដែលឋិតនៅក្នុងឋានសុភកិណ្ហា ... ពួកទេវតា ដែលឋិតនៅក្នុងឋានវេហប្ផលា ... ពួកទេវតា ដែលឋិតនៅក្នុងឋានអវិហា ... ពួកទេវតា ដែលឋិតនៅក្នុងឋានអតប្បា ... ពួកទេវតា ដែលឋិតនៅក្នុងឋានសុទស្សា ... ពួកទេវតា ដែលឋិតនៅក្នុងឋានសុទស្សី ។ បេ ។ ពួកទេវតា ដែលឋិតនៅក្នុងឋានអកនិដ្ឋ ឋិតនៅដរាបដល់អស់អាយុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៩០) ២០ពាន់កប្ប ជាប្រមាណនៃអាយុ របស់ពួកទេវតា ដែលចូលទៅ កើតក្នុងឋានអាកាសានញ្ចាយតនៈ ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងឋានអាកាសានញ្ចាយតនៈ (នោះ) ឋិតនៅអស់ ២០ ពាន់កប្បដែរឬ ។ អើ ។ មួយរយឆ្នាំ ជាប្រមាណនៃអាយុ របស់មនុស្សទាំងឡាយ ចិត្តមួយ របស់ពួកមនុស្ស ឋិតនៅអស់មួយរយឆ្នាំដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៩១) ២០ ពាន់កប្ប ជាប្រមាណនៃអាយុ របស់ពួកទេវតា ដែលចូលទៅកើតក្នុងឋានអាកាសានញ្ចាយតនៈ ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងឋានអាកាសានញ្ចាយតនៈ ឋិតនៅអស់ ២០ ពាន់កប្បដែរឬ ។ អើ ។ ប្រាំរយឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតា

ចាតុម្មហារាជិកានំ ទេវានំ ឯកំ ចិត្តំ បញ្ច វស្សស-
តានិ តិដ្ឋតិ ។ បេ ។ វស្សសហស្សំ តិដ្ឋតិ ទ្វេ វស្ស-
សហស្សានិ តិដ្ឋតិ ចត្តារិ វស្សសហស្សានិ តិដ្ឋតិ អដ្ឋ
វស្សសហស្សានិ តិដ្ឋតិ សោឡស វស្សសហស្សានិ
តិដ្ឋតិ កប្បស្ស តតិយភាគំ តិដ្ឋតិ ឧបឌ្ឍកប្បំ តិដ្ឋ-
តិ ឯកំ កប្បំ តិដ្ឋតិ ទ្វេ កប្បេ តិដ្ឋតិ ចត្តារោ
កប្បេ តិដ្ឋតិ អដ្ឋ កប្បេ តិដ្ឋតិ សោឡស កប្បេ
តិដ្ឋតិ ពត្តឹស កប្បេ តិដ្ឋតិ ចតុសដ្ឋី កប្បេ តិដ្ឋតិ
បញ្ច កប្បសតានិ តិដ្ឋតិ កប្បសហស្សំ តិដ្ឋតិ ទ្វេ
កប្បសហស្សានិ តិដ្ឋតិ ចត្តារិ កប្បសហស្សានិ តិដ្ឋ-
តិ អដ្ឋ កប្បសហស្សានិ តិដ្ឋតិ ។ បេ ។ អកនិដ្ឋានំ
ទេវានំ សោឡស កប្បសហស្សានិ អាយុប្បមាណំ
អកនិដ្ឋានំ ទេវានំ ឯកំ ចិត្តំ សោឡស កប្បស-
ហស្សានិ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៨២) អាកាសានញ្ចាយតនូបគានំ ទេវានំ ចិត្តំ
មុហុត្តំ មុហុត្តំ ឧប្បជ្ជតិ មុហុត្តំ មុហុត្តំ និរុជ្ឈតីតិ ។ អាម-
ន្តា ។ អាកាសានញ្ចាយតនូបគានំ ទេវានំ មុហុត្តំ មុហុត្តំ
ចវន្តិ មុហុត្តំ មុហុត្តំ ឧប្បជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ដែលឋិតនៅក្នុងឋានចាតុម្មហារាជិកា ចិត្តមួយ របស់ពួកទេវតាក្នុងឋាន
ចាតុម្មហារាជិកា (នោះ) ឋិតនៅអស់ប្រាំរយឆ្នាំដែរឬ ។ បេ ។ ឋិតនៅ
អស់ ១ ពាន់ឆ្នាំ ឋិតនៅអស់ ២ ពាន់ឆ្នាំ ឋិតនៅអស់ ៤ ពាន់ឆ្នាំ ឋិត
នៅអស់ ៨ ពាន់ឆ្នាំ ឋិតនៅអស់ ១៦ ពាន់ឆ្នាំ ឋិតនៅអស់ភាគជាគម្រប់បី
នៃកប្ប ឋិតនៅអស់កន្លះកប្ប ឋិតនៅអស់ ១ កប្ប ឋិតនៅអស់ ២ កប្ប
ឋិតនៅអស់ ៤ កប្ប ឋិតនៅអស់ ៨ កប្ប ឋិតនៅអស់ ១៦ កប្ប ឋិត
នៅអស់ ៣២ កប្ប ឋិតនៅអស់ ៦៤ កប្ប ឋិតនៅអស់ប្រាំរយកប្ប
ឋិតនៅអស់ ១ ពាន់កប្ប ឋិតនៅអស់ ២ ពាន់កប្ប ឋិតនៅអស់ ៤ ពាន់
កប្ប ឋិតនៅអស់ ៨ ពាន់កប្ប ។ បេ ។ ១៦ ពាន់កប្ប ជាប្រមាណ
នៃអាយុ របស់ទេវតាក្នុងឋានអកនិដ្ឋ ចិត្តមួយ របស់ពួកទេវតាដែលឋិត
នៅក្នុងឋានអកនិដ្ឋ ឋិតនៅអស់ ១៦ ពាន់កប្បដែរឬ ។ អ្នកមិនគួរ
ពោលយ៉ាងនេះទេ ។ បេ ។

(១៨២) ចិត្ត របស់ពួកទេវតាដែលចូលទៅកើតក្នុងឋានអាកាសា-
នញ្ចាយតនៈ កើតឡើងមួយស្របក់ៗ រលត់ទៅមួយស្របក់ៗឬ ។ អើ ។
ពួកទេវតា ដែលចូលទៅកើតក្នុងឋានអាកាសានញ្ចាយតនៈ ច្យុតមួយស្រ-
បក់ៗ កើតឡើងមួយស្របក់ៗឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៨៣) អាកាសានញ្ចាយតនូបគានំ ទេវានំ ឯកំ ចិត្តំ យាវតាយុកំ តិដ្ឋតីតិ ។ អាមន្តា ។ អាកាសានញ្ចាយតនូបគា ទេវា យេនេវ ចិត្តេន ឧប្បជ្ជន្តិ តេនេវ ចិត្តេន ចវន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ចិត្តដ្ឋិតិកថា ។

កុក្កុឡកថា

(១៨៤) សព្វេ សង្ខារា អនោធិកត្វា កុក្កុឡាតិ ។ អាមន្តា ។ ននុ អត្ថិ សុខា វេទនា កាយិកំ សុខំ ចេតសិកំ សុខំ ទិព្វំ សុខំ មានុសកំ សុខំ លាភសុខំ សក្ការសុខំ យានសុខំ សយនសុខំ ឥស្សរិយសុខំ អាធិបច្ចសុខំ គិហិសុខំ សាមញ្ញសុខំ សាសវំ សុខំ អនាសវំ សុខំ ឧបធិសុខំ និរុបធិសុខំ សាមិសំ សុខំ និរាមិសំ សុខំ សប្បីតិកំ សុខំ និប្បីតិកំ សុខំ ឈានសុខំ វិមុត្តិសុខំ កាមសុខំ នេក្ខម្មសុខំ បវិវេកសុខំ ឧបសមសុខំ សម្ពោធសុខន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ សុខា វេទនា ។ បេ ។

(១៨៣) ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងឋានអាកាសានញ្ចាយតនៈ ឋិតនៅដរាបដល់អស់អាយុឬ ។ អើ ។ ពួកទេវតា ដែលចូលទៅកើតក្នុងឋានអាកាសានញ្ចាយតនៈ កើតឡើងដោយចិត្តណា ច្យុតទៅវិញដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ចិត្តដ្ឋិតិកថា ។

កុក្កុឡកថា

(១៨៤) សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ វេទនា ជាសុខ គឺសុខប្រព្រឹត្តទៅក្នុងកាយ សុខប្រព្រឹត្តទៅក្នុងចិត្ត សុខជាទិព្វ សុខជារបស់មនុស្ស សុខដោយលាភ សុខដោយសក្ការៈ សុខដោយយាន សុខដោយដំណេក សុខដោយភាពនៃខ្លួនជាធំ សុខដោយភាពនៃខ្លួនជាអធិបតី សុខរបស់គ្រហស្ថ សុខរបស់សមណៈ សុខប្រកបដោយអាសវៈ សុខមិនមានអាសវៈ សុខប្រកបដោយឧបធិក្កិលេស សុខមិនមានឧបធិក្កិលេស សុខប្រកបដោយអាមិសៈ សុខមិនមានអាមិសៈ សុខប្រកបដោយបីតិ សុខមិនមានបីតិ សុខដោយឈាន សុខដោយវិមុត្តិ សុខក្នុងកាម សុខដោយការចេញចាកកាម សុខដោយការស្ងប់ស្ងាត់ សុខដោយការរម្ងាប់ សុខដោយការត្រាស់ដឹង ក្រែងមានដែរឬ ។ អើ ។ បើវេទនា ជាសុខ ។ បេ ។

សម្មោជសុទំ ហោ តុ មេ វុត្តេ សព្វេ សង្ខារា អនោធិកត្វា កុក្កុឡាតិ ។

(១៩៥) សព្វេ សង្ខារា អនោធិកត្វា កុក្កុឡាតិ ។ អាមន្តា ។ សព្វេ សង្ខារា ទុក្ខា វេទនា កាយិកា ទុក្ខា ចេតសិកា ទុក្ខា សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៩៦) ន វត្តព្វំ សព្វេ សង្ខារា អនោធិកត្វា កុក្កុឡាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សព្វំ ភិក្ខវេ អាទិត្តំ កិញ្ច ភិក្ខវេ សព្វំ អាទិត្តំ ចក្ខុំ ភិក្ខវេ អាទិត្តំ រូបា អាទិត្តា ចក្ខុវិញ្ញាណំ អាទិត្តំ ចក្ខុសម្ផស្សោ អាទិត្តោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អាទិត្តំ កេន អាទិត្តំ អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន(1) សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ សោតំ អាទិត្តំ សទ្ទា អាទិត្តា ។ បេ ។ ឃានំ អាទិត្តំ គន្ធា អាទិត្តា ។ បេ ។

១ ម. ជរាយ មរណេន ។

សុទ្ធតែអំពិការក្រាស់ដ៏នី មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

(១៩៥) សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ សង្ខារទាំងពួង មានវេទនាជាទុក្ខ គឺទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីសង្រេងសង្រែង ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៩៦) បុគ្គលមិនគួរនិយាយថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងអស់ជារបស់ក្តៅ ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងអស់ គឺអ្វី ជារបស់ក្តៅ ម្នាលភិក្ខុទាំងឡាយ ភ្នែកជារបស់ក្តៅ រូបជារបស់ក្តៅ ចក្ខុវិញ្ញាណជារបស់ក្តៅ ចក្ខុសម្ផស្សជារបស់ក្តៅ ធម្មជាតណា ដែលទទួលអារម្មណ៍ ជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខមិនមែនជាសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះជារបស់ក្តៅ ចុះក្តៅដោយអ្វី ក្តៅដោយភ្លើងគឺរាគៈ ក្តៅដោយភ្លើងគឺទោសៈ ក្តៅដោយភ្លើងគឺមោហៈ ក្តៅដោយជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថា ក្តៅ ត្រចៀកជារបស់ក្តៅ សំឡេងជារបស់ក្តៅ ។ បេ ។ ច្រមុះជារបស់ក្តៅ ក្លិនជារបស់ក្តៅ ។ បេ ។

ជិវ្ហា អាទិត្តា រសា អាទិត្តា ។ បេ ។ កាយោ អាទិត្តោ ផោដ្ឋព្វា អាទិត្តា ។ បេ ។ មនោ អាទិត្តោ ធម្មា អាទិត្តា មនោវិញ្ញាណំ អាទិត្តំ មនោសម្ផស្សោ អាទិត្តោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អាទិត្តំ កេន អាទិត្តំ អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។

[១៩៧] សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិមេ ភិក្ខវេ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនិយា សោតវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា ។ បេ ។ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនិយា ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណាតិ

អណ្តាតជារបស់ក្តៅ រសជារបស់ក្តៅ ។បេ។ កាយជារបស់ក្តៅ ផោដ្ឋព្វៈជារបស់ក្តៅ ។ បេ ។ ចិត្តជារបស់ក្តៅ ធម្មារម្មណ៍ជារបស់ក្តៅ មនោវិញ្ញាណជារបស់ក្តៅ មនោសម្ផ័ស្សជារបស់ក្តៅ ធម្មជាតណា ដែលទទួលអារម្មណ៍ ជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខមិនមែនជាសុខក្តី កើតឡើងព្រោះមនោសម្ផ័ស្សជាបច្ច័យ ធម្មជាតនោះ ជារបស់ក្តៅ ចុះក្តៅដោយអ្វី ក្តៅដោយភ្លើងគឺរាគៈ ក្តៅដោយភ្លើងគឺទោសៈ ក្តៅដោយភ្លើងគឺមោហៈ ក្តៅដោយជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគត ពោលថា ក្តៅ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែន ។

[១៩៧] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ យ៉ាង កាមគុណទាំង ៥ តើដូចម្តេចខ្លះ គឺរូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាតម្រេក ១ សំឡេងដែលគប្បីដឹងដោយត្រចៀក ១ ។ បេ ។ ក្លិនដែលគប្បីដឹងដោយច្រមុះ ១ ។ បេ ។ រសដែលគប្បីដឹងដោយអណ្តាត ១ ។ បេ ។ ផ្សព្វដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាតម្រេក ១ ម្នាលភិក្ខុទាំងឡាយ កាមគុណ មាន ៥ យ៉ាងនេះឯង

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។

(១៤៨) ន វត្តព្វំ សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា លាភា វោ ភិក្ខវេ សុលទ្ធំ វោ ភិក្ខវេ ខណោ វោ បដិលទ្ធោ ព្រហ្មចរិយវាសាយ ទិដ្ឋា មយា ភិក្ខវេ ឆផស្សាយតនិកា នាម និរយា តត្ថ យំ កិញ្ចិ ចក្ខុនា រូបំ បស្សតិ អនិដ្ឋរូបញ្ញេវ បស្សតិ នោ ឥដ្ឋរូបំ អកន្តរូបញ្ញេវ បស្សតិ នោ កន្តរូបំ អមនាបរូបញ្ញេវ បស្សតិ នោ មនាបរូបំ យំ កិញ្ចិ សោតេន សទ្ទំ សុណាតិ ។បេ។ ឃានេន គន្ធំ ឃាយតិ ។បេ។ ជិវ្ហាយ រសំ សាយតិ ។បេ។ កាយេន ផោដ្ឋព្វំ ផុសតិ ។បេ។ មនសា ធម្មំ វិជានាតិ អនិដ្ឋរូបញ្ញេវ វិជានាតិ នោ ឥដ្ឋរូបំ អកន្តរូបញ្ញេវ វិជានាតិ នោ កន្តរូបំ អមនាបរូបញ្ញេវ វិជានាតិ នោ មនាបរូបន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ(១) សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។

១ ម. ឯត្ថន្តរេ (ន វត្តព្វន្តិ) បាឋោ ទិស្សតិ ។

ពាក្យសូត្រនេះ មានក្នុងព្រះសូត្រមែនឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

(១៤៨) បុគ្គលមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ពេញហើយមានលាភ អត្តភាពនៃមនុស្ស អ្នកទាំងឡាយពេញជាបានល្អហើយ ម្នាលភិក្ខុទាំងឡាយ ខណៈ អ្នកទាំងឡាយបានចាក់ដោះហើយ ដើម្បីប្រព្រឹត្តព្រហ្មចរិយៈ ម្នាលភិក្ខុទាំងឡាយ នរក ឈ្មោះឆផស្សាយតនិកៈ គឺតថាគតបានឃើញហើយ បណ្តាធម៌ទាំងនោះ បុគ្គល ឃើញរូបណាមួយដោយភ្នែក តែងឃើញរូបមិនជាទីប្រាថ្នា តែម្យ៉ាង មិនឃើញរូបជាទីប្រាថ្នា តែងឃើញរូបមិនជាទីត្រេកអរ មិនឃើញរូបជាទីត្រេកអរ តែងឃើញរូបមិនជាទីគាប់ចិត្ត មិនឃើញរូបជាទីគាប់ចិត្ត បុគ្គល ឮសំឡេងណាមួយដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ បេ ។ លិទ្ធភ្លក្សរសដោយអណ្តាត ។ បេ ។ ពាល់ត្រូវផ្សព្វដោយកាយ ។ បេ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត តែងដឹងច្បាស់នូវរូបមិនជាទីប្រាថ្នា មិនដឹងច្បាស់នូវរូបជាទីប្រាថ្នា តែងដឹងច្បាស់នូវរូបមិនជាទីត្រេកអរ មិនដឹងច្បាស់នូវរូបជាទីត្រេកអរ តែងដឹងច្បាស់នូវរូបមិនជាទីពេញចិត្ត មិនដឹងច្បាស់នូវរូបជាទីពេញចិត្ត ពាក្យសូត្រនេះ មានក្នុងព្រះសូត្រមែនឬ ។ អើ ។ ព្រោះហេតុនោះ សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែន ។

[១៩៩] សព្វេ សង្ខារា អនោធឹ កត្វា កុក្កុ-
ឡាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា លាភា វោ
ភិក្ខវេ សុលទ្ធំ វោ ភិក្ខវេ ខណោ វោ បដិលទ្ធោ
ព្រហ្មចរិយវាសាយ ទិដ្ឋា មយា ភិក្ខវេ ឆផស្សាយ-
តនិកា នាម សគ្គា តត្ថ យំ កិញ្ចិ ចក្ខុនា រូបំ
បស្សតិ ឥដ្ឋរូបញ្ញេវ បស្សតិ នោ អនិដ្ឋរូបំ កន្តរូ-
បញ្ញេវ បស្សតិ នោ អកន្តរូបំ មនាបរូបញ្ញេវ បស្ស-
តិ នោ អមនាបរូបំ យំ កិញ្ចិ សោតេន សទ្ទំ សុ-
ណាតិ ។បេ។ ឃានេន គន្ធំ ឃាយតិ ។បេ។
ជិវ្ហាយ រសំ សាយតិ ។បេ។ កាយេន ផោដ្ឋព្វំ
ផុសតិ ។បេ។ មនសា ធម្មំ វិជានាតិ ឥដ្ឋរូបញ្ញេវ
វិជានាតិ នោ អនិដ្ឋរូបំ កន្តរូបញ្ញេវ វិជានាតិ នោ
អកន្តរូបំ មនាបរូបញ្ញេវ វិជានាតិ នោ អមនាបរូបន្តិ
អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ
សព្វេ សង្ខារា អនោធឹ កត្វា កុក្កុឡាតិ ។

[១៩៩] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។
អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-
ឡាយ ពេញហៅមានលាភ អត្តភាពនៃមនុស្ស អ្នកទាំងឡាយពេញជា
បានល្អហើយ ម្នាលភិក្ខុទាំងឡាយ ខណៈ អ្នកទាំងឡាយបានចាក់ផុះ
ហើយ ដើម្បីប្រព្រឹត្តព្រហ្មចរិយៈ ម្នាលភិក្ខុទាំងឡាយ ឋានសួគ៌ ឈ្មោះ
ផស្សាយតនិកៈ តថាគតបានឃើញហើយ បណ្តាឋានទាំងនោះ បុគ្គល
ឃើញរូបណាមួយដោយភ្នែក តែងឃើញរូបជាទីប្រាថ្នា មិនឃើញរូប
មិនជាទីប្រាថ្នា តែងឃើញរូបជាទីត្រេកអរ មិនឃើញរូបមិនជាទីត្រេក-
អរ តែងឃើញរូបជាទីពេញចិត្ត មិនឃើញរូបមិនជាទីពេញចិត្ត ឮ
សំឡេងណាមួយដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ បេ ។
លិទ្ធភ្លក្សរសដោយអណ្តាត ។ បេ ។ ពាល់ត្រូវផ្សព្វដោយកាយ ។ បេ ។
ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត តែងដឹងច្បាស់នូវរូបជាទីប្រាថ្នា មិនដឹង
ច្បាស់នូវរូបមិនជាទីប្រាថ្នា តែងដឹងច្បាស់នូវរូបជាទីត្រេកអរ មិនដឹង
ច្បាស់នូវរូបមិនជាទីត្រេកអរ តែងដឹងច្បាស់នូវរូបជាទីពេញចិត្ត មិនដឹង
ច្បាស់នូវរូបមិនជាទីពេញចិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។
ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ
ធ្វើមិនឲ្យមានព្រំដែនទេ ។

កុក្កុឡកថា

[៦០០] ន វត្តព្វំ សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។ អាមន្តា ។ ននុ យទនិច្ចំ តំ ទុក្ខំ វុត្តំ ភគវតា សព្វេ សង្ខារា អនិច្ចាតិ ។ អាមន្តា ។ ហញ្ចិ យទនិច្ចំ តំ ទុក្ខំ វុត្តំ ភគវតា សព្វេ សង្ខារា អនិច្ចា តេន វត រេ វត្តព្វេ សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។

[៦០១] សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។ អាមន្តា ។ ទានំ អនិដ្ឋផលំ អកន្តផលំ អមនុញ្ញផលំ សេចនកផលំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ សីលំ ។បេ។ ឧបោសថោ ។បេ។ ភាវនា ។បេ។ ព្រហ្មចរិយំ អនិដ្ឋផលំ អកន្តផលំ អមនុញ្ញផលំ សេចនកផលំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ ទានំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ អាមន្តា ។ ហញ្ចិ ទានំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកំ នោ ច វត រេ វត្តព្វេ សព្វេ សង្ខារា

កុក្កុឡកថា

[៦០០] បុគ្គលមិនគួរនិយាយថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា របស់ណា មិនទៀង របស់នោះ ជាទុក្ខ ពុំសង្ខារទាំងពួង មិនទៀងឬ ។ អើ ។ បើព្រះមានព្រះភាគត្រាស់ថា របស់ណា មិនទៀង របស់នោះ ជាទុក្ខ សង្ខារទាំងពួង មិនទៀង ម្នាលអ្នកដ៏ចំរើន ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

[៦០១] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ទាន មានផលមិនជាទីប្រាថ្នា មានផលមិនជាទីត្រេកអរ មានផលមិនជាទីគាប់ចិត្ត មានផលច្រឡូកច្រឡំ មានទុក្ខជាកំរៃ មានវិបាកជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សីល ។បេ។ ឧបោសថ ។បេ។ ភាវនា ។បេ។ ព្រហ្មចរិយៈ មានផលមិនជាទីប្រាថ្នា មានផលមិនជាទីត្រេកអរ មានផលមិនជាទីគាប់ចិត្ត មានផលច្រឡូកច្រឡំ មានទុក្ខជាកំរៃ មានវិបាកជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនច្រឡូកច្រឡំ មានសុខជាកំរៃ មានវិបាកជាសុខឬ ។ អើ ។ បើទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនច្រឡូកច្រឡំ មានសុខជាកំរៃ មានវិបាកជាសុខហើយ ម្នាលអ្នកដ៏ចំរើន អ្នកមិនគួរពោលថា សង្ខារទាំងពួង

អនោធីកត្វា កុក្កុច្ចុប្បត្តិ ។ ឧទុ សីលំ ។ បេ ។ ឧបោសថោ ។ បេ ។ ភាវនា ។ បេ ។ ព្រហ្មចរិយំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ អាមន្តា ។ ហញ្ចិ ព្រហ្មចរិយំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកំ នោ ច វត រេ វត្តព្វេ សព្វេ សង្ខារា អនោធីកត្វា កុក្កុច្ចុប្បត្តិ ។

(៦០៦) សព្វេ សង្ខារា អនោធីកត្វា កុក្កុច្ចុប្បត្តិ ។ អាមន្តា ។ ឧទុ វត្តំ ភគវតា

សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ
អព្យាបជ្ជំ សុខំ លោកេ បាណភូតេសុ សញ្ញមោ
សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ
អស្មិមានស្ស យោ វិនយោ ឯតំ វេ បរមំ សុខំ
តំ សុខេន សុខំ បត្តំ អច្ចន្តំ សុខមេវ តំ

ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។ ក្រែងសីល ។ បេ ។ ឧបោសថ ។ បេ ។ ភាវនា ។ បេ ។ ព្រហ្មចរិយៈ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនច្រឡូកច្រឡំ មានសុខជាកម្រៃ មានវិបាកជាសុខឬ ។ អើ ។ បើព្រហ្មចរិយៈ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនច្រឡូកច្រឡំ មានសុខជាកម្រៃ មានវិបាកជាសុខ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

(៦០៦) សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

វិវេក របស់បុគ្គល អ្នកត្រេកអរ ជាអ្នកមានធម៌បានស្តាប់
ហើយ ឃើញ (ធម៌) រមែងនាំមកនូវសេចក្តីសុខ ការមិន
បៀតបៀន គឺការសង្រួម ក្នុងសត្វទាំងឡាយ នាំមកនូវ
សេចក្តីសុខ ក្នុងលោក ការប្រាសចាករាគៈ គឺកិរិយា
កន្លង នូវកាមទាំងឡាយ នាំមក នូវសេចក្តីសុខក្នុងលោក
ការបន្ទាបង់ នូវអស្មិមានះ ណា នុះឯង ជាសេចក្តីសុខ
ដ៏ក្រៃលែង សេចក្តីសុខនោះ បុគ្គល បានដល់ហើយ
ដោយងាយ សេចក្តីសុខនោះឯង មានទីបំផុតដ៏ក្រៃលែង

តិស្សោ វិជ្ជា អនុប្បត្តា ឯតំ វេ បរមំ សុខន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។

កុក្កុឡកថា ។

អនុបុព្វាភិសមយកថា

(៦០៣) អនុបុព្វាភិសមយោតិ ។ អាមន្តា ។ អនុបុព្វេន សោតាបត្តិមគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនុបុព្វេន សោតាបត្តិមគ្គំ ភាវេតីតិ ។ អាមន្តា ។ អនុបុព្វេន សោតាបត្តិផលំ សច្ឆិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦០៤) អនុបុព្វាភិសមយោតិ ។ អាមន្តា ។ អនុបុព្វេន សកទាគាមិមគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនុបុព្វេន សកទាគាមិមគ្គំ ភាវេតីតិ ។ អាមន្តា ។ អនុបុព្វេន សកទាគាមិផលំ សច្ឆិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦០៥) អនុបុព្វាភិសមយោតិ ។ អាមន្តា ។ អនុបុព្វេន អនាគាមិមគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

វិជ្ជា ៣ ដែលគេបានដល់ហើយ នេះ ជាសេចក្តីសុខដ៏ក្រៃលែង ពាក្យនុ៎ះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

ចប់ កុក្កុឡកថា ។

អនុបុព្វាភិសមយកថា

(៦០៣) ការត្រាស់ដឹងជាលំដាប់ មានដែរឬ ។ អើ ។ បុគ្គល ចម្រើនសោតាបត្តិមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចម្រើនសោតាបត្តិមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦០៤) ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ បុគ្គល ចម្រើនសកទាគាមិមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលចម្រើនសកទាគាមិមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦០៥) ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ បុគ្គលចម្រើនអនាគាមិមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អនុបុព្វេន អនាគាមិមគ្គំ ករោតីតិ ។ អាមន្តា ។ អនុបុព្វេន អនាគាមិផលំ សច្ឆិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦០៦) អនុបុព្វាភិសមយោតិ ។ អាមន្តា ។ អនុបុព្វេន អរហត្តមគ្គំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនុបុព្វេន អរហត្តមគ្គំ ករោតីតិ ។ អាមន្តា ។ អនុបុព្វេន អរហត្តផលំ សច្ឆិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦០៧) សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទុក្ខទស្សនេន កឹ ជហាតីតិ ។ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ តទេកដ្ឋេ ច កិលេសេ ចតុព្ភាគំ ជហាតីតិ ។ ចតុព្ភាគំ សោតាបន្នោ ចតុព្ភាគំ ន សោតាបន្នោ ចតុព្ភាគំ សោតាបត្តិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុព្ភាគំ ន កាយេន ផុសិត្វា វិហរតិ ចតុព្ភាគំ សត្តក្ខត្តុបរមោ កោលំកោលោ ឯកពីជី ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។

បុគ្គលចំរើនអនាគាមិមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦០៦) ការត្រាស់ដឹងតាមលំដាប់ មានឬ ។ អើ ។ បុគ្គលចំរើនអរហត្តមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលចំរើនអរហត្តមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវអរហត្តផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦០៧) បុគ្គលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ និងពួកកិលេស ដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុព្ភាគ (មានចំណែកជា ៤) ។ សោតាបន្នបុគ្គល ជាចតុព្ភាគ មិនមែនសោតាបន្នបុគ្គល ជាចតុព្ភាគ បុគ្គលដល់សោតាបត្តិផល បាននូវចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគ សត្តក្ខត្តុបរមបុគ្គល កោលំកោលបុគ្គល ឯកពីជិបុគ្គល ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។ បេ ។ ក្នុងព្រះសង្ឃ ។ បេ ។

អរិយកន្តេហិ សីលេហិ សមន្នាគតោ ចតុក្កំ ន អរិយកន្តេហិ សីលេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយទស្សនេន ។ បេ ។ និរោធទស្សនេន ។ បេ ។ មគ្គទស្សនេន តី ជហតីតិ ។ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ តទេកដ្ឋេ ច កិលេសេ ចតុក្កំ ជហតីតិ ។ ចតុក្កំ សោតាបន្នោ ចតុក្កំ ន សោតាបន្នោ ចតុក្កំ សោតាបត្តិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុក្កំ ន កាយេន ផុសិត្វា វិហរតិ ចតុក្កំ សត្តក្ខត្តុបរមោ កោលំកោលោ ឯកពីជី ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ចតុក្កំ ន អរិយកន្តេហិ សីលេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ប្រកបដោយសីលជាទីត្រេកអររបស់អរិយៈទាំងឡាយ ជាចតុក្កៈ មិនប្រកបដោយសីលជាទីត្រេកអររបស់អរិយៈទាំងឡាយ ជាចតុក្កៈ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយការឃើញសមុទយសច្ច ។ បេ ។ ដោយការឃើញនិរោធសច្ច ។ បេ ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុក្កៈ ។ សោតាបន្នបុគ្គល ជាចតុក្កៈ មិនមែនសោតាបន្នបុគ្គល ជាចតុក្កៈ បុគ្គលដល់សោតាបត្តិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កៈ មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កៈ សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯកពីជិបុគ្គល ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។ បេ ។ ក្នុងព្រះសង្ឃ ។ បេ ។ ប្រកបដោយសីលជាទីត្រេកអររបស់អរិយៈទាំងឡាយ ជាចតុក្កៈ មិនប្រកបដោយសីលជាទីត្រេកអររបស់អរិយៈទាំងឡាយ ជាចតុក្កៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២០៨] សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទុក្ខទស្សនេន កិំ ជហតីតិ ។ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ តទេកដ្ឋេ ច កិលេសេ ចតុព្ភាគំ ជហតីតិ ។ ចតុព្ភាគំ សកទាគាមី ចតុព្ភាគំ ន សកទាគាមី ចតុព្ភាគំ សកទាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុព្ភាគំ ន កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយទស្សនេន ។ បេ ។ និរោធទស្សនេន ។ បេ ។ មគ្គទស្សនេន កិំ ជហតីតិ ។ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ តទេកដ្ឋេ ច កិលេសេ ចតុព្ភាគំ ជហតីតិ ។ ចតុព្ភាគំ សកទាគាមី ចតុព្ភាគំ ន សកទាគាមី ចតុព្ភាគំ សកទាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុព្ភាគំ ន កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២០៨] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគគ្រោតគ្រាត ព្យាបាទគ្រោតគ្រាត និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុព្ភាគ ។ សកទាគាមិបុគ្គល ជាចតុព្ភាគ មិនមែនសកទាគាមិបុគ្គល ជាចតុព្ភាគ បុគ្គល ដល់នូវសកទាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយការឃើញសមុទយសច្ច ។ បេ ។ ដោយការឃើញនិរោធសច្ច ។ បេ ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគគ្រោតគ្រាត ព្យាបាទគ្រោតគ្រាត និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុព្ភាគ ។ សកទាគាមិបុគ្គល ជាចតុព្ភាគ មិនមែនសកទាគាមិបុគ្គល ជាចតុព្ភាគ បុគ្គល ដល់នូវសកទាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១០៨] អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទុក្ខទស្សនេន កឹ ជហាតីតិ ។ អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ តទេកដ្ឋេ ច កិលេសេ ចតុក្កំ ជហាតីតិ ។ ចតុក្កំ អនាគាមី ចតុក្កំ ន អនាគាមី ចតុក្កំ អនាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុក្កំ ន កាយេន ផុសិត្វា វិហរតិ ចតុក្កំ អន្តរាបរិនិព្វាយី ។បេ។ ឧបហច្ចបរិនិព្វាយី ។បេ។ អសង្ខារបរិនិព្វាយី ។បេ។ សសង្ខារបរិនិព្វាយី ។បេ។ ឧទ្ធំសោតោ អកនិដ្ឋគាមី ចតុក្កំ ន ឧទ្ធំសោតោ ន អកនិដ្ឋគាមីតិ ។ ន ហេវំ វត្តព្វេ ។បេ។ សមុទយទស្សនេន ។ប។ និរោធទស្សនេន ។បេ។ មគ្គទស្សនេន កឹ ជហាតីតិ ។ អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ តទេកដ្ឋេ ច កិលេសេ ចតុក្កំ ជហាតីតិ ។ ចតុក្កំ អនាគាមី ចតុក្កំ ន អនាគាមី ចតុក្កំ អនាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុក្កំ

[៦០៨] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគក្រាលស្តើង ព្យាបាទក្រាលស្តើង និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុក្កក ។ អនាគាមិបុគ្គល ជាចតុក្កក មិនមែនអនាគាមិបុគ្គល ជាចតុក្កក បុគ្គល ដល់នូវអនាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កក មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កក អន្តរាបរិនិព្វាយិបុគ្គល ។បេ។ ឧបហច្ចបរិនិព្វាយិបុគ្គល ។បេ។ អសង្ខារបរិនិព្វាយិបុគ្គល ។បេ។ សសង្ខារបរិនិព្វាយិបុគ្គល ។បេ។ ឧទ្ធំសោតៈ អកនិដ្ឋគាមិបុគ្គល ជាចតុក្កក មិនមែនឧទ្ធំសោតៈ មិនមែនអកនិដ្ឋគាមិបុគ្គល ជាចតុក្កក ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយការឃើញសមុទយសច្ច ។បេ។ ដោយការឃើញនិរោធសច្ច ។បេ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគក្រាលស្តើង ព្យាបាទក្រាលស្តើង និងពួកកិលេសដែលដូចគ្នានឹងពួកធម៌ទាំងនោះ ជាចតុក្កក ។ អនាគាមិបុគ្គល ជាចតុក្កក មិនមែនអនាគាមិបុគ្គល ចតុក្កក បុគ្គល ដល់នូវអនាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កក

ន កាយេន ផុសិត្វា វិហរតិ ចតុក្កាតំ អន្តរាបរិ-
និព្ពាយី ។បេ។ ឧបហច្ចបរិនិព្ពាយី ។បេ។ អសង្ខា-
របរិនិព្ពាយី ។បេ។ សសង្ខារបរិនិព្ពាយី ឧទ្ធំសោតោ
អកនិដ្ឋគាមី ចតុក្កាតំ ន ឧទ្ធំសោតោ ន អកនិដ្ឋ-
គាមីតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦១០] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-
លោ ទុក្ខទស្សនេន កឹ ជហាតីតិ ។ រូបរាគំ អរូប-
រាគំ មានំ ឧទ្ធច្ចំ អវិជ្ជំ តទេកដ្ឋេ ច កិលេសេ
ចតុក្កាតំ ជហាតីតិ ។ ចតុក្កាតំ អរហា ចតុក្កាតំ ន
អរហា ចតុក្កាតំ អរហត្តប្បត្តោ បដិលទ្ធោ អធិគតោ
សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា
វិហរតិ ចតុក្កាតំ ន កាយេន ផុសិត្វា វិហរតិ ចតុក្កាតំ
វីតរាគោ វីតទោសោ វីតមោហោ កតករណីយោ
ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជ-
នោ សម្មទញ្ញា វិមុត្តោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិខោ
អព្វុឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ

មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កាត អន្តរាបរិនិព្វាយិបុគ្គល ។បេ។
ឧបហច្ចបរិនិព្វាយិបុគ្គល ។បេ។ អសង្ខារបរិនិព្វាយិបុគ្គល ។បេ។
សសង្ខារបរិនិព្វាយិបុគ្គល ។បេ។ ឧទ្ធំសោតៈ អកនិដ្ឋគាមិបុគ្គល ជា
ចតុក្កាត មិនមែនឧទ្ធំសោតៈ មិនមែនអកនិដ្ឋគាមិបុគ្គល ជាចតុក្កាតឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៦១០] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត
ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះរូបរាគៈ អរូប-
រាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា និងពួកកិលេសដែលដូចគ្នានឹងពួកធម៌ទាំង
នោះ ជាចតុក្កាត ។ ព្រះអរហន្ត ជាចតុក្កាត មិនមែនព្រះអរហន្ត
ជាចតុក្កាត បុគ្គល ដល់នូវអរហត្ត បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់
ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កាត មិនពាល់
ត្រូវដោយនាមកាយ ជាចតុក្កាត ប្រាសចាករាគៈ ប្រាសចាកទោសៈ
ប្រាសចាកមោហៈ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះ
ហើយ មានប្រយោជន៍ជារបស់ខ្លួនដល់ហើយដោយលំដាប់ មាន
សញ្ញោជនៈក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹង
ដោយប្រពៃ មានទ្វារដែលគុលគឺអវិជ្ជាលើកឡើងហើយ មានគូ (ស្នាម
ភ្លោះ) ទម្លាយហើយ មានសសរទៀនដកចោលហើយ មិនមានសន្ទះ
ទ្វារ ចេញចាកសត្រូវ មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ

វិសញ្ញុត្តោ សុវិជិតវិជយោ ទុក្ខស្ស បរិញ្ញាតំ សមុ-
ទយោ បហីនោ និរោធោ សច្ឆិកតោ មគ្គោ ភាវិ-
តោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ
បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ ។ បេ ។ សច្ឆិ-
កាតព្វំ សច្ឆិកតំ ចតុត្ថំ សច្ឆិកាតព្វំ ន សច្ឆិ-
កតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយទស្ស-
នេន ។ បេ ។ និរោធទស្សនេន ។ បេ ។ មគ្គទស្ស-
នេន កឹ ជហាតីតិ ។ រូបរាគំ អរូបរាគំ មានំ ឧទ្ធច្ចំ
អវិជ្ជំ តទេកដ្ឋេ ច កិលេសេ ចតុត្ថំ ជហាតីតិ ។
ចតុត្ថំ អរហា ចតុត្ថំ ន អរហា ចតុត្ថំ អរ-
ហត្តប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧប-
សម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុត្ថំ
ន កាយេន ផុសិត្វា វិហរតិ ចតុត្ថំ វីតរាគោ
វីតទោសោ វីតមោហោ កតករណីយោ ឱហិតភារោ

ប្រាសចាកធម៌ជាគ្រឿងប្រកប មានជ័យឈ្នះដោយប្រពៃ ទុក្ខសច្ច
បុគ្គលនោះ ក៏បានកំណត់ដឹងហើយ សមុទយសច្ច (ហេតុដែលនាំឲ្យ
កើតទុក្ខ) ក៏បានលះបង់ហើយ និរោធសច្ច (ធម៌ជាទីរលត់ទុក្ខ) បាន
ធ្វើឲ្យជាក់ច្បាស់ហើយ មគ្គសច្ច ក៏បានចម្រើនហើយ ធម្មជាតដែលគួរ
ត្រាស់ដឹង ក៏បានត្រាស់ដឹងហើយ ធម្មជាតដែលគួរកំណត់ដឹង ក៏បានកំ-
ណត់ដឹងហើយ ធម្មជាតដែលគួរលះ ក៏បានលះហើយ ធម្មជាតដែល
គួរចម្រើន ក៏បានចម្រើនហើយ ។ បេ ។ ធម្មជាតដែលគួរធ្វើឲ្យជាក់
ច្បាស់ បុគ្គលនោះ ក៏បានធ្វើឲ្យជាក់ច្បាស់ហើយ ជាចតុក្ក ធម្មជាត
ដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះមិនបានធ្វើឲ្យជាក់ច្បាស់ហើយ ជា
ចតុក្ក មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយការ
ឃើញសមុទយសច្ច ។ បេ ។ ដោយការឃើញនិរោធសច្ច ។ បេ ។
ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះរូបរាគៈ អរូប-
រាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំង
នោះ ជាចតុក្ក ។ អរហន្ត ជាចតុក្ក មិនមែនអរហន្ត ជា
ចតុក្ក បុគ្គល ដល់នូវអរហត្ត បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់
ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្ក មិនពាល់
ត្រូវដោយនាមកាយ ជាចតុក្ក ប្រាសចាករាគៈ ប្រាសចាកទោសៈ
ប្រាសចាកមោហៈ មានសោឡសកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ

អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិខោ អព្វុឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ វិសញ្ញុត្តោ សុវិជិតវិជយោ ទុក្ខន្តស្ស បរិញ្ញាតំ សមុទយោ បហី-នោ និរោធោ សច្ឆិកតោ មគ្គោ ភាវិតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ ន-តុក្កាតំ សច្ឆិកាតព្វំ ន សច្ឆិកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦១១] សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទុក្ខំ បស្សន្តោ បដិបន្នកោតិ វត្តព្វោតិ ។ អាមន្តា ។ ទុក្ខេ ទិដ្ឋេ ផលេ ឋិតោតិ វត្តព្វោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយំ បស្សន្តោ ។ បេ ។

បាននូវប្រយោជន៍ជារបស់ខ្លួនដល់ហើយដោយលំដាប់ មានសញ្ញោជនៈក្នុងភពអស់រលីងហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានគូរដឹងគុលគឺអវិជ្ជាលើកឡើងហើយ មានគូទម្លាយហើយ មានសសរទៀនដកចោលហើយ មិនមានសន្ទះទ្វារ ចេញចាកសត្រូវ មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ ប្រាសចាកធម៌ជាគ្រឿងប្រកប មានជ័យជំនះហើយដោយប្រពៃ ទុក្ខសច្ច បុគ្គលនោះបានកំណត់ដឹងហើយ សមុទយសច្ច ក៏បានលះបង់ហើយ និរោធសច្ច ក៏បានធ្វើឲ្យជាក់ច្បាស់ហើយ មគ្គសច្ច ក៏បានចម្រើនហើយ ធម្មជាតដែលគួរត្រាស់ដឹង ក៏បានត្រាស់ដឹងហើយ ធម្មជាតដែលគួរកំណត់ដឹង ក៏បានកំណត់ដឹងហើយ ធម្មជាតដែលគួរលះ ក៏បានលះហើយ ធម្មជាតដែលគួរចម្រើន ក៏បានចម្រើនហើយ ។ បេ ។ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ជាចក្កាត ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះមិនបានធ្វើឲ្យជាក់ច្បាស់ហើយ ជាចក្កាត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦១១] បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិបានឬ ។ អើ ។ កាលបើទុក្ខដែលបុគ្គលបានឃើញហើយ គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលឃើញ សមុទយៈ ។ បេ ។

និរោធំ បស្សន្តោ បដិបន្នកោតិ វត្តព្វោតិ ។ អាម-
ន្តា ។ និរោធេ ទិដ្ឋេ ផលេ ឋិតោតិ វត្តព្វោតិ ។
ន ហេវំ វត្តព្វេ ។បេ ។

(៦១៦) សោតាបត្តិផលសច្ឆិកិរិយាយ បដិ-
បន្នោ បុគ្គលោ មគ្គំ បស្សន្តោ បដិបន្នកោតិ វត្តព្វោ
មគ្គេ ទិដ្ឋេ ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។
ទុក្ខំ បស្សន្តោ បដិបន្នកោតិ វត្តព្វោ ទុក្ខេ ទិដ្ឋេ
ផលេ ឋិតោតិ វត្តព្វោតិ ។ ន ហេវំ វត្តព្វេ ។បេ ។
មគ្គំ បស្សន្តោ បដិបន្នកោតិ វត្តព្វោ មគ្គេ ទិដ្ឋេ
ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។ សមុទយំ
បស្សន្តោ ។បេ ។ និរោធំ បស្សន្តោ បដិបន្នកោតិ
វត្តព្វោ និរោធេ ទិដ្ឋេ ផលេ ឋិតោតិ វត្តព្វោតិ ។
ន ហេវំ វត្តព្វេ ។បេ ។

(៦១៧) សោតាបត្តិផលសច្ឆិកិរិយាយ បដិ-
បន្នោ បុគ្គលោ ទុក្ខំ បស្សន្តោ បដិបន្នកោតិ វត្តព្វោ
ទុក្ខេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។
អាមន្តា ។ មគ្គំ បស្សន្តោ បដិបន្នកោតិ វត្តព្វោ

ឃើញនិរោធ គួរនិយាយថា ជាអ្នកប្រតិបត្តិបានឬ ។ អើ ។ កាល
បើនិរោធ បុគ្គលនោះបានឃើញហើយ គួរនិយាយថា ជាអ្នកឋិតនៅ
ក្នុងផលបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។

(៦១៦) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតា-
បត្តិផល ឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ លុះកាលបើមគ្គ
បុគ្គលនោះបានឃើញហើយ គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបាន
ឬ ។ អើ ។ បុគ្គលឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិ លុះ
កាលបើទុក្ខ បុគ្គលបានឃើញហើយ គួរនិយាយថា ជាអ្នកឋិតនៅក្នុង
ផលបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ បុគ្គលឃើញ
មគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ លុះកាលបើមគ្គ បុគ្គលនោះបានឃើញ
ហើយ គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានឬ ។ អើ ។ បុគ្គល
ឃើញសមុទយៈ ។បេ ។ ឃើញនិរោធ គួរនិយាយថា ជាអ្នក
ប្រតិបត្តិ លុះកាលបើនិរោធ បុគ្គលនោះបានឃើញហើយ គួរនិយាយថា
ជាអ្នកឋិតនៅក្នុងផលបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។

(៦១៧) បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិ-
ផល ឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើទុក្ខ បុគ្គលនោះ
បានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុង
ផលទេឬ ។ អើ ។ បុគ្គលឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ

មគ្គេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយំ បស្សន្តោ ។ បេ ។ និរោធំ បស្សន្តោ បដិបន្នកោតិ វត្តព្វោ និរោធេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។ មគ្គំ បស្សន្តោ បដិបន្នកោតិ វត្តព្វោ មគ្គេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦១៤) សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទុក្ខំ បស្សន្តោ បដិបន្នកោតិ វត្តព្វោ ទុក្ខេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។ និវត្តិយំ(១) ទុក្ខទស្សនត្ថិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយំ បស្សន្តោ ។ បេ ។ និរោធំ បស្សន្តោ បដិបន្នកោតិ វត្តព្វោ និរោធេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។ និវត្តិយំ និរោធទស្សនត្ថិ ។ ន ហេវំ វត្តព្វេ ។ បេ ។

១ ម. និវត្តិយំ ។

កាលបើមគ្គ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ឃើញសមុទយៈ ។ បេ ។ ឃើញនិរោធៈ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើនិរោធ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលទេឬ ។ អើ ។ បុគ្គលឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើមគ្គ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦១៤) បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើទុក្ខ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានទេឬ ។ អើ ។ ការឃើញទុក្ខ ជាការឥតប្រយោជន៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ឃើញសមុទយៈ ។ បេ ។ ឃើញនិរោធ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើនិរោធ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានទេឬ ។ អើ ។ ការឃើញនិរោធ ជាការឥតប្រយោជន៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦១៥) ទុក្ខេ និដ្ឋេ ចត្តារិ សច្ចានិ និដ្ឋានិ ហោន្តីតិ ។ អាមន្តា ។ ទុក្ខសច្ចំ ចត្តារិ សច្ចានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦១៦) រូបក្ខន្ធេ អនិច្ចតោ និដ្ឋេ បញ្ចក្ខន្ធា អនិច្ចតោ និដ្ឋា ហោន្តីតិ ។ អាមន្តា ។ រូបក្ខន្ធោ បញ្ចក្ខន្ធាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦១៧) ចក្ខាយតនេ អនិច្ចតោ និដ្ឋេ ទ្វាទសាយតនានិ អនិច្ចតោ និដ្ឋានិ ហោន្តីតិ ។ អាមន្តា ។ ចក្ខាយតនំ ទ្វាទសាយតនានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦១៨) ចក្ខុធាតុយា អនិច្ចតោ និដ្ឋាយ អដ្ឋារស ធាតុយោ អនិច្ចតោ និដ្ឋា ហោន្តីតិ ។ អាមន្តា ។ ចក្ខុធាតុ អដ្ឋារស ធាតុយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦១៩) ចក្ខុន្ទ្រិយេ អនិច្ចតោ និដ្ឋេ ពាវីសតិន្ទ្រិយានិ អនិច្ចតោ និដ្ឋានិ ហោន្តីតិ ។ អាមន្តា ។ ចក្ខុន្ទ្រិយំ ពាវីសតិន្ទ្រិយានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦១៥) កាលបើទុក្ខ បុគ្គលបានឃើញហើយ សច្ចៈ ៤ ឈ្មោះថាបានឃើញហើយឬ ។ អើ ។ ទុក្ខសច្ច ឈ្មោះថាសច្ចៈ ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦១៦) កាលបើរូបក្ខន្ធ បុគ្គលបានឃើញហើយ ដោយសេចក្តីថាមិនទៀង បញ្ចក្ខន្ធ ឈ្មោះថាបានឃើញហើយ ដោយសេចក្តីថាមិនទៀងឬ ។ អើ ។ រូបក្ខន្ធ ឈ្មោះថាបញ្ចក្ខន្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦១៧) កាលបើចក្ខាយតនៈ បុគ្គលឃើញហើយ ដោយសេចក្តីថា មិនទៀង អាយតនៈ ១២ ឈ្មោះថាបុគ្គលឃើញហើយ ដោយសេចក្តីថា មិនទៀងឬ ។ អើ ។ ចក្ខាយតនៈ ឈ្មោះថាអាយតនៈ ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦១៨) កាលបើចក្ខុធាតុ បុគ្គលបានឃើញហើយ ដោយសេចក្តីថាមិនទៀង ធាតុទាំង ១៨ ឈ្មោះថាបានឃើញហើយ ដោយសេចក្តីថាមិនទៀងឬ ។ អើ ។ ចក្ខុធាតុ ឈ្មោះថាធាតុ ១៨ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦១៩) កាលបើចក្ខុន្ទ្រិយ បុគ្គលបានឃើញហើយ ដោយសេចក្តីថា មិនទៀង ឥន្ទ្រិយទាំង ២២ ឈ្មោះថាបានឃើញហើយ ដោយសេចក្តីថា មិនទៀងឬ ។ អើ ។ ចក្ខុន្ទ្រិយ ឈ្មោះថាឥន្ទ្រិយ ២២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦០) ចតុន្នំ ញាណានំ សោតាបត្តិផលំ សច្ឆិ-
ករោតីតិ ។ អាមន្តា ។ ចត្តារិ សោតាបត្តិផលានីតិ ។
ន ហេវំ វត្តព្វេ ។បេ។ អដ្ឋន្នំ ញាណានំ សោតា-
បត្តិផលំ សច្ឆិករោតីតិ ។ អាមន្តា ។ អដ្ឋ សោតា-
បត្តិផលានីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទ្វាទស-
ន្នំ ញាណានំ សោតាបត្តិផលំ សច្ឆិករោតីតិ ។
អាមន្តា ។ ទ្វាទស សោតាបត្តិផលានីតិ ។ ន ហេវំ
វត្តព្វេ ។បេ។ ចតុចត្តាឡីសាយ ញាណានំ សោ-
តាបត្តិផលំ សច្ឆិករោតីតិ ។ អាមន្តា ។ ចតុចត្តា-
ឡីស សោតាបត្តិផលានីតិ ។ ន ហេវំ វត្តព្វេ ។បេ។
សត្តសត្តតិយា ញាណានំ សោតាបត្តិផលំ សច្ឆិក-
រោតីតិ ។ អាមន្តា ។ សត្តសត្តតិ សោតាបត្តិផលានី-
តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៦១) ន វត្តព្វំ អនុបុព្វាភិសមយោតិ ។ អាមន្តា ។
ននុ វុត្តំ ភគវតា សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ
អនុបុព្វនិន្នោ អនុបុព្វបោណោ អនុបុព្វបព្ភារោ ន អា-
យតកេនេវ បបាតោ ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ ធម្ម-
វិនយេ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា

(៦៦០) បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយ
ញាណទាំង ៤ ឬ ។ អើ ។ សោតាបត្តិផល មាន ៤ ឬ ។ អ្នកមិន
គួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិ-
ផល ដោយញាណទាំង ៨ ឬ ។ អើ ។ សោតាបត្តិផល មាន ៨
ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើឲ្យជាក់ច្បាស់
នូវសោតាបត្តិផល ដោយញាណទាំង ១៦ ឬ ។ អើ ។ សោតាបត្តិ-
ផល មាន ១៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើ
ឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយញាណទាំង ៤៤ ឬ ។ អើ ។
សោតាបត្តិផល មាន ៤៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។
បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយញាណទាំង ៧៧ ឬ ។
អើ ។ សោតាបត្តិផល មាន ៧៧ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះ
ទេ ។បេ។

(៦៦១) បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់
មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ
ទាំងឡាយ មហាសមុទ្រ ទាបទៅដោយលំដាប់ ជ្រាលទៅដោយលំដាប់
ជ្រៅទៅដោយលំដាប់ មិនមែនចោតជ្រៅស្រឡូន ដូចជាអណ្តូងទេ យ៉ាង
ណាមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានការសិក្សាជាលំដាប់
មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិ ដោយលំដាប់

ន អាយតកេនេវ អញ្ញាបដិវេធោតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អនុបុព្វាភិសមយោតិ ។

(៦៦២) ន វត្តព្វំ អនុបុព្វាភិសមយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អនុបុព្វាភិសមយោតិ ។

(៦៦៣) ន វត្តព្វំ អនុបុព្វាភិសមយោតិ ។ អាមន្តា ។ ននុ អាយស្មា គវម្បតិត្ថេរោ ភិក្ខូ ឯតទវោច សម្មុខា មេតំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យោ ភិក្ខវេ ទុក្ខំ បស្សតិ ទុក្ខសមុទយម្បិ សោ បស្សតិ ទុក្ខនិរោធម្បិ បស្សតិ ទុក្ខនិរោធគាមិនីបដិបទម្បិ បស្សតិ យោ ទុក្ខសមុទយំ បស្សតិ ទុក្ខម្បិ សោ បស្សតិ ទុក្ខនិរោធម្បិ បស្សតិ ទុក្ខនិរោធគាមិនីបដិបទម្បិ បស្សតិ យោ ទុក្ខនិរោធំ បស្សតិ ទុក្ខម្បិ សោ បស្សតិ

បំនុំមិនបានត្រាស់ដឹងព្រះអរហត្តផលតែម្តងទេ ក៏យ៉ាងនោះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ការត្រាស់ដឹងជាលំដាប់ មាន ។

(៦៦២) បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

អ្នកមានប្រាជ្ញា គប្បីកំចាត់បង់ នូវមន្ទិលរបស់ខ្លួន បន្តិចម្តង ៗ ក្នុងមួយខណៈ ៗ ដោយលំដាប់ ដូចជាងជាងមាស
ដែលកំចាត់បង់ នូវមន្ទិលនៃប្រាក់ ដូច្នោះដែរ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ការត្រាស់ដឹងជាលំដាប់ មាន ។

(៦៦៣) បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេឬ ។ អើ ។ ក្រែងព្រះគវម្បតិត្ថេរមានអាយុ បានពោលដូច្នេះ នឹងភិក្ខុទាំងឡាយហើយថា ម្នាលលោកមានអាយុទាំងឡាយ ពាក្យនេះ ខ្ញុំបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ឃើញទុក្ខ បុគ្គលនោះ ឈ្មោះថាឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង បុគ្គលណា ឃើញទុក្ខសមុទយៈ បុគ្គលនោះ ឈ្មោះថាឃើញទុក្ខផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង បុគ្គលណា ឃើញទុក្ខនិរោធ បុគ្គលនោះ ឈ្មោះថាឃើញទុក្ខផង

ទុក្ខសមុទយម្បិ បស្សតិ ទុក្ខនិរោធគាមិនីបដិបទម្បិ បស្សតិ យោ ទុក្ខនិរោធគាមិនីបដិបទម្បិ បស្សតិ ទុក្ខម្បិ សោ បស្សតិ ទុក្ខសមុទយម្បិ បស្សតិ ទុក្ខនិរោធម្បិ បស្សតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អនុបុព្វាភិសមយោតិ ។

(៦៦៤) អនុបុព្វាភិសមយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សហាវស្ស ទស្សនសម្បទាយ ។ បេ ។ ឆ ចាភិឋានានិ អភព្វោ កាតុន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អនុបុព្វាភិសមយោតិ ។

(៦៦៥) អនុបុព្វាភិសមយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា យស្មិំ ភិក្ខវេ សមយេ អរិយសាវកស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ សហ ទស្សនុប្បាទា ភិក្ខវេ អរិយសាវកស្ស តីណិ សញ្ញោជនានិ បហីយន្តិ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោតិ

ឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង បុគ្គលណា ឃើញទុក្ខនិរោធគាមិនីបដិបទា បុគ្គលនោះ ឈ្មោះថាឃើញទុក្ខផង ឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេ ។

(៦៦៤) ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាមួយនឹងទស្សនសម្បទា (គឺសោ-តាបត្តិមគ្គ) ។ បេ ។ សោតាបន្នបុគ្គល មិនគួរធ្វើនូវហេតុជាទីតាំងនៃសេចក្តីអាក្រក់ទាំង ៦ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេ ។

(៦៦៥) ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម័យណា ធម្មចក្ខុ ដែលមានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ របស់អរិយសាវក កើតឡើងថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ម្នាលភិក្ខុទាំងឡាយ សម័យនោះ សញ្ញោជនៈ ៣ យ៉ាងគឺ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ឈ្មោះថាអរិយសាវកបានលះបង់

អត្ថិ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អនុបុព្វាភិសមយោតិ ។

អនុបុព្វាភិសមយកថា ។

វោហារកថា

(៦៦៦) ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។ អាមន្តា ។ លោកុត្តរេ សោតេ បដិហញ្ញតិ នោ លោកិយេ លោកុត្តរេន វិញ្ញាណេន បដិវិជានន្តិ នោ លោកិយេន សាវកា បដិវិជានន្តិ នោ បុថុជ្ជនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៧) ន នុ ពុទ្ធស្ស ភគវតោ វោហារោ លោកិយេ សោតេ បដិហញ្ញតីតិ ។ អាមន្តា ។ ហញ្ចិ ពុទ្ធស្ស ភគវតោ វោហារោ លោកិយេ សោតេ បដិហញ្ញតិ នោ វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

(៦៦៨) ន នុ ពុទ្ធស្ស ភគវតោ វោហារំ លោកិយេន វិញ្ញាណេន បដិវិជានន្តីតិ ។ អាមន្តា ។ ហញ្ចិ ពុទ្ធស្ស ភគវតោ វោហារំ លោកិយេន វិញ្ញាណេន

ជាមួយលើការកើតឡើងនៃសច្ចសម្បុទា ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេ ។

ចប់ អនុបុព្វាភិសមយកថា ។

វោហារកថា

(៦៦៦) វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈឬ ។ អើ ។ វោហារ របស់ព្រះពុទ្ធមានព្រះភាគ ប៉ះទង្គិចត្រចៀកជាលោកុត្តរៈ មិនប៉ះទង្គិចត្រចៀកជាលោកិយៈ ជនទាំងឡាយ ដឹងច្បាស់ ដោយវិញ្ញាណជាលោកុត្តរៈ មិនដឹងច្បាស់ ដោយវិញ្ញាណជាលោកិយៈ សាវកទាំងឡាយ ដឹងច្បាស់ បុថុជ្ជនទាំងឡាយ មិនដឹងច្បាស់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៧) ក្រែងវោហារ របស់ព្រះពុទ្ធមានព្រះភាគ ប៉ះទង្គិចត្រចៀកជាលោកិយៈឬ ។ អើ ។ បើវោហារ របស់ព្រះពុទ្ធមានព្រះភាគ ប៉ះទង្គិចត្រចៀកជាលោកិយៈដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

(៦៦៨) ក្រែងពួកសាវក ដឹងច្បាស់ នូវវោហារ របស់ព្រះពុទ្ធមានព្រះភាគ ដោយវិញ្ញាណជាលោកិយៈឬ ។ អើ ។ បើពួកសាវក ដឹងច្បាស់ នូវវោហារ របស់ព្រះពុទ្ធមានព្រះភាគ ដោយវិញ្ញាណជាលោកិយៈដែរ

បដិវិជានន្តិ នោ វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

[៦២៩] ននុ ពុទ្ធស្ស ភគវតោ វោហារំ បុថុជ្ជនា បដិវិជានន្តីតិ ។ អាមន្តា ។ ហញ្ចិ ពុទ្ធស្ស ភគវតោ វោហារំ បុថុជ្ជនា បដិវិជានន្តិ នោ វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

[៦៣០] ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។ អាមន្តា ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ សកទាគាមិមគ្គោ សកទាគាមិផលំ អនាគាមិមគ្គោ អនាគាមិផលំ អរហត្តមគ្គោ អរហត្តផលំ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៣១] ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។ អាមន្តា ។ អត្ថិ កេចិ ពុទ្ធស្ស ភគវតោ វោហារំ សុណន្តីតិ ។ អាមន្តា ។ លោកុត្តរោ ធម្មោ សោតវិញ្ញេយ្យោ សោតស្មិំ បដិហញ្ញតិ សោតស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

[៦២៩] ក្រែងពួកបុថុជ្ជន ដឹងច្បាស់ នូវវោហារ របស់ព្រះពុទ្ធមានព្រះភាគឬ ។ អើ ។ បើពួកបុថុជ្ជន ដឹងច្បាស់ នូវវោហារ របស់ព្រះពុទ្ធមានព្រះភាគដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

[៦៣០] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈឬ ។ អើ ។ ចុះមគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ (ជាលោកុត្តរៈ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៦៣១] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈឬ ។ អើ ។ សាវ័កពួកខ្លះ ស្តាប់វោហាររបស់ព្រះពុទ្ធមានព្រះភាគ មានឬ ។ អើ ។ លោកុត្តរធម៌ បុគ្គលគប្បីដឹងដោយត្រចៀក ប៉ះទង្គិចត្រចៀក មកកាន់ផ្លូវនៃត្រចៀកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៦៣៦] ននុ លោកុត្តរោ ធម្មោ ន សោតវិញ្ញេយ្យោ ន សោតស្មិំ បដិហញ្ញតិ ន សោតស្ស អាបាថំ អាគច្ឆតីតិ ។ អាមន្តា ។ ហញ្ចិ លោកុត្តរោ ធម្មោ ន សោតវិញ្ញេយ្យោ ន សោតស្មិំ បដិហញ្ញតិ ន សោតស្ស អាបាថំ អាគច្ឆតិ នោ ច វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

[៦៣៧] ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។ អាមន្តា ។ អត្ថិ កេចិ ពុទ្ធស្ស ភគវតោ វោហារេ រជ្ជេយ្យុន្តិ ។ អាមន្តា ។ លោកុត្តរោ ធម្មោ រាគដ្ឋានិយោ រជនិយោ កមនិយោ មទនិយោ ពន្ធនិយោ មុច្ឆនិយោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៣៨] ននុ លោកុត្តរោ ធម្មោ ន រាគដ្ឋានិយោ ន រជនិយោ ន កមនិយោ ន មទនិយោ ន ពន្ធនិយោ ន មុច្ឆនិយោតិ ។ អាមន្តា ។ ហញ្ចិ លោកុត្តរោ ធម្មោ ន រាគដ្ឋានិយោ ន រជនិយោ ន កមនិយោ ន មទនិយោ ន ពន្ធនិយោ ន មុច្ឆនិយោ នោ ច វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

[៦៣៦] ក្រែងលោកុត្តរធម៌ បុគ្គលមិនគប្បីដឹងដោយត្រចៀក មិនប៉ះទង្គិចត្រចៀក មិនមកកាន់ផ្លូវនៃត្រចៀកទេឬ ។ អើ ។ បើលោកុត្តរធម៌ បុគ្គលមិនគប្បីដឹងដោយត្រចៀក មិនប៉ះទង្គិចត្រចៀក មិនមកកាន់ផ្លូវនៃត្រចៀកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

(៦១៩) អាកាសានញ្ចាយតនំ ចតុវោការភវេ អត្ថិ តត្ថ សញ្ញាតិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវេ អត្ថិ តត្ថ សញ្ញាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិញ្ញាណញ្ចាយតនំ ។ បេ ។ អាកិញ្ចញ្ញាយតនំ ចតុវោការភវេ អត្ថិ តត្ថ សញ្ញាតិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវេ អត្ថិ តត្ថ សញ្ញាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦១៨) នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេឬ ។ អើ ។ អាកាសានញ្ចាយតនភព ។ បេ ។ វិញ្ញាណញ្ចាយតនភព ។ បេ ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងអាកិញ្ចញ្ញាយតនភព មានឬមិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦១៩) អាកាសានញ្ចាយតនភព ជាចតុវោការភព សញ្ញា ក្នុងអាកាសានញ្ចាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិញ្ញាណញ្ចាយតនភព ។ បេ ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងអាកិញ្ចញ្ញាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦២០] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ អាមន្តា ។ ននុ នេវសញ្ញានាសញ្ញាយតនន្តិ ។ អាមន្តា ។ ហញ្ចិ នេវសញ្ញានាសញ្ញាយតនំ តេន វត រេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។

[៦២១] នេវសញ្ញានាសញ្ញាយតនន្តិ កត្វា នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ អាមន្តា ។ អទុក្ខមសុខា វេទនាតិ កត្វា អទុក្ខមសុខាយ វេទនាយ ន វត្តព្វំ វេទនាតិ វា អវេទនាតិ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

នេវសញ្ញានាសញ្ញាយតនកថា ។

តតិយោ វគ្គោ ។

[៦៦០] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេឬ ។ អើ ។ ក្រែង នេវសញ្ញានាសញ្ញាយតនភព មានឬ ។ អើ ។ ប្រសិនបើ នេវសញ្ញានាសញ្ញាយតនភព មានមែន ម្នាលអ្នកដ៏ចំរើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេ ។

[៦៦១] បុគ្គលធ្វើសេចក្តីចូលចិត្តថា នេវសញ្ញានាសញ្ញាយតនភព ដូច្នេះហើយ មិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេឬ ។ អើ ។ បុគ្គលធ្វើសេចក្តីចូលចិត្តថា អទុក្ខមសុខវេទនា ដូច្នេះហើយ មិនគួរនិយាយថា វេទនា ឬមិនមែនវេទនា ក្នុងអទុក្ខមសុខវេទនាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ នេវសញ្ញានាសញ្ញាយតនកថា ។

ចប់ តតិយវគ្គ ។

តស្ស ឧទ្ទានំ

ពលំ សាធារណំ អរិយំ សរាគំ ចិត្តំ វិមុច្ចតិ
វិមុត្តំ វិមុច្ចមានំ អត្ថិ ចិត្តំ វិមុច្ចមានំ
អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនំ
អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ចិន្ទ្រិយានិ ចក្ខុំ
សោតំ ធម្មុបត្ថទ្ធំ យថាកម្មុបគតញ្ញាណំ ទេវេសុ
សំវរោ អសញ្ញសត្តេសុ សញ្ញា ឋបេ ភវគ្គន្តិ ។

គិហិស្ស អរហាតិកថា

[៤៤២] គិហិស្ស អរហាតិ ។ អាមន្តា ។ អត្ថិ អរហតោ គិហិសញ្ញោជនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ អរហតោ គិហិសញ្ញោជនន្តិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ គិហិសញ្ញោជនំ នោ ច វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

[៤៤៣] គិហិស្ស អរហាតិ ។ អាមន្តា ។ ននុ អរហតោ គិហិសញ្ញោជនំ បហីនំ ឧច្ឆិន្នមូលំ

ឧទ្ទាននៃតតិយវគ្គនោះ គឺ

និយាយអំពីកម្លាំងព្រះតថាគត សាធារណៈដល់សាវ័ក ១ កម្លាំងព្រះតថាគត ជាអរិយៈ ១ ចិត្ត ប្រកបដោយរាគៈ រួចស្រឡះ ១ ចិត្ត រួចស្រឡះហើយ កំពុងរួចស្រឡះ និងចិត្តកំពុងរួចស្រឡះ ១ បុគ្គលទី ៨ លះបង់ទិដ្ឋិបរិយុដ្ឋានៈ ១ បុគ្គលទី ៨ មិនមានឥន្ទ្រិយ ៥ ហើយ ១ មំសចក្ខុ ដែលធម៌ទំនុកបម្រុង ១ មំសសោតដែលធម៌ទំនុកបម្រុង ១ យថាកម្មូបគតញ្ញាណ ១ ការសង្រួម ក្នុងពួកទេវតា ១ សញ្ញា ក្នុងពួកអសញ្ញសត្វ ១ ក្នុងនេវសញ្ញានាសញ្ញាយតនភព ១ ។

គិហិអរហាតិកថា

[៤៤២] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ សញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើសញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

[៤៤៣] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ ក្រែងសញ្ញោជនៈនៃគ្រហស្ថ ព្រះអរហន្ត បានលះបង់ហើយ មានឫសគល់

តាលាវត្ថុកតំ អនភាវង្កតំ អាយតឹអនុប្បាទធម្មំ ។ អាមន្តា ។ ហញ្ចិ អរហតោ គិហិសញ្ញោជនំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹអនុប្បា-ទធម្មំ នោ វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

(៦២៦) គិហិស្ស អរហាតិ ។ អាមន្តា ។ អត្ថិ កេចិ គិហី គិហិសញ្ញោជនំ អប្បហាយ ទិដ្ឋេ វ ធម្មេ ទុក្ខស្សន្តករោតិ ។ នត្ថិ ។ ហញ្ចិ នត្ថិ កេចិ គិហី គិហិសញ្ញោជនំ អប្បហាយ ទិដ្ឋេ វ ធម្មេ ទុក្ខស្សន្តករោ នោ វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

(៦២៧) គិហិស្ស អរហាតិ ។ អាមន្តា ។ ននុ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភោ គោតម កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ កាយស្ស ភេទា ទុក្ខស្សន្តករោតិ នត្ថិ ខោ វច្ឆ កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ កាយស្ស ភេទា ទុក្ខស្សន្តករោតិ អត្ថេវ សុត្តន្តោតិ ។

ផ្តាច់ហើយ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើសញ្ញោជនៈនៃគ្រហស្ថ ព្រះអរហន្ត បានលះបង់ហើយ មានឫសគល់ផ្តាច់ហើយ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

(៦២៦) គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈនៃគ្រហស្ថ ហើយធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន មានដែរឬ ។ មិនមានទេ ។ បើគ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈនៃគ្រហស្ថ ហើយធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

(៦២៧) គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ វច្ឆគោត្តបរិព្វាជក បានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈរបស់គ្រហស្ថ លុះបែកធ្លាយរាងកាយ ហើយធ្វើនូវទីបំផុតនៃទុក្ខ មានដែរឬ (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ម្នាលវច្ឆៈ គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈរបស់គ្រហស្ថ លុះបែកធ្លាយរាងកាយ ហើយធ្វើនូវទីបំផុតនៃទុក្ខ មិនមានទេ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។

អាមន្តា ។ តេន ហិ ន វត្តព្វំ គិហិស្ស អរហាតិ ។

(៤៦៦) គិហិស្ស អរហាតិ ។ អាមន្តា ។ អរហា មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ បុត្តសម្ពាធសយនំ អជ្ឈាវសេយ្យ កាសិកចន្ទនំ បច្ចនុភវេយ្យ មាលាគន្ធវិលេបនំ ធារេយ្យ ជាតរូបរជតំ សាទិយេយ្យ អជេឡកំ បដិគ្គណ្ហេយ្យ កុក្កុដសូករំ បដិគ្គណ្ហេយ្យ ហត្ថិគវស្សវឡវំ បដិគ្គណ្ហេយ្យ តិត្តិរវដ្ដកមោរកបិញ្ជលំ បដិគ្គណ្ហេយ្យ បីតវណ្ណកលមោលិកំ ធារេយ្យ ទីឃទសានិ វត្ថានិ ធារេយ្យ យាវជីវំ អគារិយភូតោ អស្សាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៦៧) ន វត្តព្វំ គិហិស្ស អរហាតិ ។ អាមន្តា ។ ននុ យសោ កុលបុត្តោ ឧត្តិយោ គហបតិ សេតុ មាណវោ គិហិស្ស ព្យញ្ជនេន អរហត្តំ បត្តាតិ ។ អាមន្តា ។ ហញ្ចិ យសោ កុលបុត្តោ ឧត្តិយោ គហបតិ សេតុ មាណវោ គិហិស្ស ព្យញ្ជនេន អរហត្តំ បត្តា តេន វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

គិហិស្ស អរហាតិកថា ។

ទេ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

(៤៦៦) គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ ព្រះអរហន្ត សេពមេថុនធម្ម ញុំាងមេថុនធម្មឲ្យកើតឡើង នៅគ្រប់គ្រងដំណេកដែលចង្អៀតដោយកូន លាបព្រះព្រំខ្លឹមចន្ទន៍ដ៏ឧត្តម ទ្រទ្រង់ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាប ត្រេកអរចំពោះមាសនិងប្រាក់ ទទួលពពែនិងចៀម ទទួលមាន់និងជ្រូក ទទួលដំរី គោ សេះឈ្មោល សេះញី ទទួលទា ក្រួច ក្ងោក ចចាត ទ្រទ្រង់កួចសក់ដែលមានខ្ទង់មានពណ៌លឿង ទ្រទ្រង់សំពត់សមានជាយវែង នៅជាគ្រហស្ថ ដរាបអស់មួយជីវិតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៦៧) បុគ្គលមិនគួរនិយាយថា គ្រហស្ថ បានជាព្រះអរហន្តទេឬ ។ អើ ។ ក្រែងយសកុលបុត្រ ឧត្តិយគហបតី និងសេតុមាណព ដល់នូវព្រះអរហត្ត ដោយភេទនៃគ្រហស្ថឬ ។ អើ ។ បើ យសកុលបុត្រ ឧត្តិយគហបតិ និងសេតុមាណព ដល់នូវព្រះអរហត្ត ដោយភេទនៃគ្រហស្ថមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តដែរ ។

ចប់ គិហិអរហាតិកថា ។

ឧបបត្តិកថា

(៦២៨) សហ ឧប្បត្តិយា អរហាតិ ។ អាមន្តា ។ សហ ឧប្បត្តិយា សោតាបន្នោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦២៩) សហ ឧប្បត្តិយា អរហាតិ ។ អាមន្តា ។ សហ ឧប្បត្តិយា សកទាគាមី ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៣០) សហ ឧប្បត្តិយា អរហាតិ ។ អាមន្តា ។ សហ ឧប្បត្តិយា អនាគាមី ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៣១) សហ ឧប្បត្តិយា សោតាបន្នោ ន ហោតីតិ ។ អាមន្តា ។ ហញ្ចិ សហ ឧប្បត្តិយា សោតាបន្នោ ន ហោតិ នោ ច វត រេ វត្តព្វេ សហ ឧប្បត្តិយា អរហាតិ ។

ឧបបត្តិកថា

(៦២៨) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើង(១)ឬ ។ អើ ។ បុគ្គល បានជាសោតាបន្នៈ ជាមួយគ្នានឹងការកើតឡើង(២)ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦២៩) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល បានជាសកទាគាមី ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៣០) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល បានជាអនាគាមី ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៣១) បុគ្គល បានជាសោតាបន្នៈ មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គល បានជាសោតាបន្នៈ មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

---

១ សំដៅយកបុគ្គល ដែល កើតក្នុងសុទ្ធាវាស បានសម្រេចជាអរហន្ត ដំណាលគ្នា នឹងការកើតឡើងឬ ?

២ សំដៅយក ឧបបត្តិចិត្ត (ចិត្តកើតឡើងជាលោកិយៈ) ។

(៤៣៦) សហ ឧប្បត្តិយា សកទាគាមី ន ហោតីតិ ។ អាមន្តា ។ ហញ្ចិ សហ ឧប្បត្តិយា សកទាគាមី ន ហោតិ នោ វត រេ វត្តព្វេ សហ ឧប្បត្តិយា អរហាតិ ។

(៤៣៧) សហ ឧប្បត្តិយា អនាគាមី ន ហោតីតិ ។ អាមន្តា ។ ហញ្ចិ សហ ឧប្បត្តិយា អនាគាមី ន ហោតិ នោ វត រេ វត្តព្វេ សហ ឧប្បត្តិយា អរហាតិ ។

(៤៣៨) សហ ឧប្បត្តិយា អរហាតិ ។ អាមន្តា ។ សារីបុត្តោ ថេរោ សហ ឧប្បត្តិយា អរហាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មហាមោគ្គល្លានោ ថេរោ ។ បេ ។ មហាកស្សបោ ថេរោ ។ បេ ។ មហាកច្ចាយនោ ថេរោ ។ បេ ។ មហាកោដ្ឋិកោ ថេរោ ។ បេ ។ មហាបណ្ណកោ ថេរោ សហ ឧប្បត្តិយា អរហាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៣៩) សារីបុត្តោ ថេរោ ន សហ ឧប្បត្តិយា អរហាតិ ។ អាមន្តា ។ ហញ្ចិ សារីបុត្តោ ថេរោ ន សហ ឧប្បត្តិយា អរហា នោ វត រេ

(៤៣៦) បុគ្គល បានជាសកទាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គល បានជាសកទាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

(៤៣៧) បុគ្គល បានជាអនាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គល បានជាអនាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

(៤៣៨) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ព្រះសារីបុត្តត្ថេរ បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះមោគ្គល្លានត្ថេរ ។ បេ ។ ព្រះមហាកស្សបត្ថេរ ។ បេ ។ ព្រះមហាកច្ចាយនត្ថេរ ។ បេ ។ ព្រះមហាកោដ្ឋិកត្ថេរ ។ បេ ។ ព្រះមហាបណ្ណកត្ថេរ បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៣៩) ព្រះសារីបុត្តត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើព្រះសារីបុត្តត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន

វត្តព្វេ សហ ឧបបត្តិយា អរហាតិ ។

(៤៣៦) មហាមោគ្គល្លានោ ថេរោ ។បេ។ មហាកស្សបោ ថេរោ មហាកច្ចាយនោ ថេរោ មហាកោដ្ឋិកោ ថេរោ ។បេ។

(៤៣៧) មហាបណ្ណកោ ថេរោ ន សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ហញ្ចិ មហាបណ្ណកោ ថេរោ ន សហ ឧបបត្តិយា អរហា នោ វត រេ វត្តព្វេ សហ ឧបបត្តិយា អរហាតិ ។

(៤៣៨) សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ឧបបត្តេសិយេន ចិត្តេន អរហត្តំ សច្ឆិករោតិ លោកិយេន សាសវេន ។បេ។ សង្កិលេសិកេនាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៣៩) សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ឧបបត្តេសិយំ ចិត្តំ និយ្យានិកំ ខយគាមិ ពោធគាមិ អបចយគាមិ អនាសវំ ។បេ។ អសង្កិលេសិកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

(៤៣៦) ព្រះមហាមោគ្គល្លានត្ថេរ ។បេ។ ព្រះមហាកស្សបត្ថេរ ព្រះមហាកច្ចាយនត្ថេរ ព្រះមហាកោដ្ឋិកត្ថេរ ។បេ។

(៤៣៧) ព្រះមហាបណ្ណកត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើព្រះមហាបណ្ណកត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

(៤៣៨) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវព្រះអរហត្ត ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង (បដិសន្ធិចិត្ត) ជាលោកិយៈ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៣៩) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង ជានិយ្យានិកៈ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង ដល់នូវការមិនសន្សំ មិនមានអាសវៈ ។បេ។ មិនប្រកបដោយសេចក្តីសៅហ្មងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៦៦០] ននុ ឧប្បត្តេសិយំ ចិត្តំ អព្យាកតំ ន ខយគាមិ ន ពោធគាមិ ន អបចយគាមិ សាសវំ ។បេ។ សង្កិលេសិកន្តិ ។ អាមន្តា ។ ហញ្ចិ ឧប្បត្តេសិយំ ចិត្តំ អព្យាកតំ ន ខយគាមិ ន ពោធគាមិ ន អបចយគាមិ សាសវំ ។បេ។ សង្កិលេសិកំ នោ ច វត រេ វត្តព្វេ សហ ឧប្បត្តិយា អរហាតិ ។

[៦៦១] សហ ឧប្បត្តិយា អរហាតិ ។ អាមន្តា ។ ឧប្បត្តេសិយេន ចិត្តេន រាគំ បជហតិ ទោសំ បជហតិ មោហំ បជហតិ ។បេ។ អនោត្តប្បំ បជហតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៦២] សហ ឧប្បត្តិយា អរហាតិ ។ អាមន្តា ។ ឧប្បត្តេសិយំ ចិត្តំ មគ្គោ ។បេ។ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ។បេ។ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៦៦៣] សហ ឧប្បត្តិយា អរហាតិ ។

[៦៦០] ក្រែងចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង មិនមែនជាអព្យាក្រឹតៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អើ ។ បើចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង មិនមែនជាអព្យាក្រឹតៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំ ប្រកបដោយអាសវៈ ។បេ។ ប្រកបដោយសេចក្តីសៅហ្មង ម្នាលអ្នកដ៏ចំរើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[៦៦១] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល លះរាគៈ លះទោសៈ លះមោហៈ ។បេ។ លះអនោត្តប្បៈ ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៦៦២] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង ជាមគ្គ ។បេ។ ជាសតិប្បដ្ឋាន ជាសម្មប្បធាន ជាឥទ្ធិបាទ ជាឥន្ទ្រិយ ជាពលៈ ។បេ។ ជាពោជ្ឈង្គៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៦៦៣] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។

អាមន្តា ។ ឧបបត្តេសិយេន ចិត្តេន ទុក្ខំ បរិជានាតិ សមុទយំ បជហាតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេ-តីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៦៦) សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ចុតិចិត្តំ មគ្គចិត្តំ ឧបបត្តេសិយំ ចិត្តំ ផល-ចិត្តន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

ឧបបត្តិកថា ។

អនាសវកថា

(៦៦៨) អរហតោ សព្ពេ ធម្មា អនាសវាតិ ។ អាមន្តា ។ មគ្គោ ផលំ និព្ពានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ សកទាគាមិមគ្គោ សកទាគាមិផលំ អនាគាមិមគ្គោ អនាគាមិផលំ អរហត្តមគ្គោ អរហត្ត-ផលំ សតិបដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៦៩) អរហតោ សព្ពេ ធម្មា អនាសវាតិ ។ អាមន្តា ។ អរហតោ ចក្ខុំ អនាសវន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ អរហតោ ចក្ខុំ អនាសវន្តិ ។

បើ ។ បុគ្គល កំណត់ដឹងនូវទុក្ខសច្ច លះនូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៦៦) បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ បើ ។ ចុតិចិត្ត មគ្គចិត្ត ចិត្តដែលកំពុងស្វែងរកនូវការកើតឡើង ជាផលចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ ឧបបត្តិកថា ។

អនាសវកថា

(៦៦៨) ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ បើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ (របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ) ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៦៩) ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ បើ ។ ចក្ខុ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខុ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។

អារព្ភ ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ សោតា-
បត្តិផលំ ។បេ។ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ
។បេ។ អរហតោ សោតំ ។បេ។ អរហតោ ឃានំ
។បេ។ អរហតោ ជិវ្ហា ។បេ។ អរហតោ កាយោ
អនាសវោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៦៧) អរហតោ កាយោ អនាសវោតិ ។
អាមន្តា ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ
សោតាបត្តិផលំ ។បេ។ ពោជ្ឈង្គោតិ ។ ន ហេវំ
វត្តព្វេ ។បេ។

(៦៦៨) អរហតោ កាយោ អនាសវោតិ ។
អាមន្តា ។ អរហតោ កាយោ បគ្គហនិគ្គហុបគោ
ឆេទនភេទនុបគោ កាកេហិ គិជ្ឈេហិ កុលលេហិ
សាធារណោតិ ។ អាមន្តា ។ អនាសវោ ធម្មោ
បគ្គហនិគ្គហុបគោ ឆេទនភេទនុបគោ កាកេហិ
គិជ្ឈេហិ កុលលេហិ សាធារណោតិ ។ ន ហេវំ
វត្តព្វេ ។បេ។

(៦៦៩) អរហតោ កាយេ វិសំ កមេយ្យ
សត្ថំ កមេយ្យ អគ្គិ កមេយ្យាតិ ។ អាមន្តា ។

អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។
ពោជ្ឈង្គៈ (របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ) ឬ ។ អ្នកមិនគួរ
ពោលយ៉ាងនេះទេ ។បេ។ ត្រចៀក របស់ព្រះអរហន្ត ។បេ។
ច្រមុះ របស់ព្រះអរហន្ត ។បេ។ អណ្តាត របស់ព្រះអរហន្ត ។បេ។
កាយ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។បេ។

(៦៦៧) កាយ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។
អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។
ពោជ្ឈង្គៈ (របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ) ទេឬ ។ អ្នកមិន
គួរពោលយ៉ាងនេះទេ ។បេ។

(៦៦៨) កាយ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។
អើ ។ កាយ របស់ព្រះអរហន្ត គួរដល់នូវការផ្គងឡើងនិងការសង្កត់
សង្កិន គួរដល់នូវការដាច់និងការបែកធ្លាយ ជាសាធារណៈ ដល់ពួកក្អែក
ត្មាត ខ្លែងដែរឬ ។ អើ ។ ធម៌ មិនមានអាសវៈ គួរដល់នូវការផ្គងឡើង
និងការសង្កត់សង្កិន គួរដល់នូវការដាច់និងការបែកធ្លាយ ជាសាធារណៈ
ដល់ពួកក្អែក ត្មាត ខ្លែងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៦៩) ថ្នាំពិស គួរចូលទៅ គ្រឿងសស្ត្រា គួរមុត
ភ្លើង គួរឆេះ ចំពោះកាយ របស់ព្រះអរហន្តដែរឬ ។ អើ ។

អនាសវេ ធម្មេ វិសំ គាមេយ្យ សត្ថំ គាមេយ្យ អគ្គិ គាមេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៨០) លព្ភា អរហតោ កាយោ អន្ទុពន្ធនេន ពន្ធិតុំ រជ្ជុពន្ធនេន ពន្ធិតុំ សង្ខលិកាពន្ធនេន ពន្ធិតុំ គាមពន្ធនេន ពន្ធិតុំ និគមពន្ធនេន ពន្ធិតុំ នគរពន្ធនេន ពន្ធិតុំ ជនបទពន្ធនេន ពន្ធិតុំ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិតុន្តិ ។ អាមន្តា ។ លព្ភា អនាសវោ ធម្មោ អន្ទុពន្ធនេន ពន្ធិតុំ រជ្ជុពន្ធនេន ពន្ធិតុំ សង្ខលិកាពន្ធនេន ពន្ធិតុំ គាមពន្ធនេន និគមពន្ធនេន នគរពន្ធនេន ជនបទពន្ធនេន កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៨១) យទិ អរហា បុថុជ្ជនស្ស ចីវរំ ទេតិ អនាសវំ ហុត្វា សាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាសវំ ហុត្វា សាសវំ ហោតីតិ ។ អាមន្តា ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ អាមន្តា ។ មគ្គោ អនាសវោ ហុត្វា

ថ្នាំពិស គួរចូលទៅ គ្រឿងសស្ត្រា គួរមុត ភ្លើង គួរឆេះ ចំពោះធម៌ ដែលមិនមានអាសវៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៨០) កាយ របស់ព្រះអរហន្ត គួរដើម្បីចាប់ដោយចំណងគឺខ្នោះ ដើម្បីចាប់ដោយចំណងគឺខ្សែ ដើម្បីចាប់ដោយចំណងគឺច្រវាក់ ដើម្បីចាប់ដោយចំណងគឺស្រុក ដើម្បីចាប់ដោយចំណងគឺនិគម ដើម្បីចាប់ដោយចំណងគឺនគរ ដើម្បីចាប់ដោយចំណងគឺជនបទ ដើម្បីចាប់ដោយចំណងមានកជាគម្រប់ ៥ ដែរឬ ។ អើ ។ ធម៌ មិនមានអាសវៈ គួរដើម្បីចាប់ដោយចំណងគឺខ្នោះ ដើម្បីចាប់ដោយចំណងគឺខ្សែ ដើម្បីចាប់ដោយចំណងគឺច្រវាក់ ដោយចំណងគឺស្រុក ដោយចំណងគឺនិគម ដោយចំណងគឺនគរ ដោយចំណងគឺជនបទ ដើម្បីចាប់ដោយចំណងមានកជាគម្រប់ ៥ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៨១) បើព្រះអរហន្ត ឲ្យចីវរដល់បុថុជ្ជន (ចីវរនោះ) ជាវត្ថុមិនមានអាសវៈ តែប្រែកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (ចីវរ) ជាវត្ថុមិនមានអាសវៈ តែប្រែកបដោយអាសវៈ មានដែរឬ ។ អើ ។ ចីវរនោះឯង មិនមានអាសវៈទេ តែចីវរនោះ ប្រែកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចីវរនោះ មិនមានអាសវៈទេ តែចីវរនោះ ប្រែកបដោយអាសវៈ មានដែរឬ ។ អើ ។ មគ្គ ជាធម៌មិនមានអាសវៈ

សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ផលំ សតិបដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គា អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៩២) យទិ អរហា បុថុជ្ជនស្ស បិណ្ឌបាតំ ទេតិ សេនាសនំ ទេតិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេតិ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ អាមន្តា ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ អាមន្តា ។ មគ្គោ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ផលំ សតិបដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គា អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

តែប្រកបដោយអាសវៈ មានវៀរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានវៀរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៩២) បើព្រះអរហន្ត ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ដល់បុថុជ្ជន (បច្ច័យមានបិណ្ឌបាតជាដើមនោះ) ជាសភាពមិនមានអាសវៈ តែប្រកបដោយអាសវៈ មានវៀរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ (បច្ច័យមានបិណ្ឌបាតជាដើមនោះ) ជាសភាពមិនមានអាសវៈ តែប្រកបដោយអាសវៈ មានវៀរឬ ។ អើ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះឯង មិនមានអាសវៈទេ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ មានវៀរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បច្ច័យមានបិណ្ឌបាតជាដើមនោះឯង មិនមានអាសវៈទេ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ មានវៀរឬ ។ អើ ។ មគ្គ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានវៀរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានវៀរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៨៣) យទិ ពុទ្ធស្ស អរហតោ ចីវរំ ទេតិ សាសវំ ហុត្វា អនាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៨៤) សាសវំ ហុត្វា អនាសវំ ហោតីតិ ។ អាមន្តា ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ អាមន្តា ។ រាគោ សាសវោ ហុត្វា អនាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទោសោ មោហោ ។ បេ ។ អនោត្តប្បំ សាសវំ ហុត្វា អនាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ ប ។

(៤៨៥) យទិ ពុទ្ធស្ស អរហតោ បិណ្ឌបាតំ ទេតិ សេនាសនំ ទេតិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេតិ សាសវោ ហុត្វា អនាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៨៦) សាសវោ ហុត្វា អនាសវោ ហោតីតិ ។

(៤៨៣) បើបុគ្គល ឲ្យចីវរដល់ព្រះអរហន្ត (ចីវរនោះ) ជាវត្ថុប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៨៤) (ចីវរ) ជាវត្ថុប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អើ ។ ចីវរនោះឯង ប្រកបដោយអាសវៈ តែចីវរនោះ មិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចីវរនោះឯង ប្រកបដោយអាសវៈ តែចីវរនោះ មិនមានអាសវៈ មានដែរឬ ។ អើ ។ រាគៈ ជាធម៌ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទោសៈ មោហៈ ។ បេ ។ អនោត្តប្បៈ ជាធម៌ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៨៥) បើបុគ្គល ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ដល់ព្រះអរហន្ត (បច្ច័យមានបិណ្ឌបាតជាដើមនោះ) ជាសភាពប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៨៦) (បច្ច័យមានបិណ្ឌបាតជាដើមនោះ) ជាសភាពប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។

អាមន្តា ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ អាមន្តា ។ រាគោ សាសវោ ហុត្វា អនាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទោសោ ។ បេ ។ មោហោ ។ បេ ។ អនោត្តប្បំ សាសវំ ហុត្វា អនាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៥៧] ន វត្តព្វំ អរហតោ សព្វេ ធម្មា អនាសវាតិ ។ អាមន្តា ។ ននុ អរហា អនាសវោតិ ។ អាមន្តា ។ ហញ្ចិ អរហា អនាសវោ តេន វត រេ វត្តព្វេ អរហតោ សព្វេ ធម្មា អនាសវាតិ ។

អនាសវកថា ។

សមន្នាគតកថា

[៦៥៨] អរហា ចតូហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អរហា ចតូហិ ផស្សេហិ ចតូហិ វេទនាហិ ចតូហិ សញ្ញាហិ ចតូហិ ចេតនាហិ ចតូហិ ចិត្តេហិ ចតូហិ សទ្ធាហិ ចតូហិ វីរិយេហិ

អើ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ មិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះឯង ប្រកបដោយអាសវៈ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ មិនមានអាសវៈ មានដែរឬ ។ អើ ។ រាគៈ ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទោសៈ ។ បេ ។ មោហៈ ។ បេ ។ អនោត្តប្បៈ ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៥៧] បុគ្គលមិនគួរនិយាយថា ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនអាសវៈទេឬ ។ អើ ។ ក្រែងព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ បើព្រះអរហន្ត មិនមានអាសវៈទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេ ។

ចប់ អនាសវកថា ។

សមន្នាគតកថា

[៦៥៨] ព្រះអរហន្ត ប្រកបដោយផល ៤ ឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយផស្សៈ ៤ ដោយវេទនា ៤ ដោយសញ្ញា ៤ ដោយចេតនា ៤ ដោយចិត្ត ៤ ដោយសទ្ធា ៤ ដោយវីរិយៈ ៤

ចតូហិ សតីហិ ចតូហិ សមាធីហិ ចតូហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៥៩) អនាគាមី តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី តីហិ ផស្សេហិ ។បេ។ តីហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៦០) សកទាគាមី ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមី ទ្វីហិ ផស្សេហិ ។បេ។ ទ្វីហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៦១) អរហា សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សោតាបន្នោ សត្តក្ខត្តុបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។បេ។ អរហា សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។បេ។ អរហា អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហា អនាគាមី អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមីតិ ។ ន ហេវំ វត្តព្វេ ។បេ។

ដោយសតិ ៤ ដោយសមាធិ ៤ ដោយបញ្ញា ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៥៩) អនាគាមិបុគ្គល ប្រកបដោយផល ៣ ឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយផស្សៈ ៣ ។បេ។ ដោយបញ្ញា ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៦០) សកទាគាមិបុគ្គល ប្រកបដោយផល ២ ឬ ។ អើ ។ សកទាគាមិបុគ្គល ប្រកបដោយផស្សៈ ២ ។បេ។ ដោយបញ្ញា ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៦១) ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ព្រះអរហន្ត ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ព្រះអរហន្ត ជាសកទាគាមិបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ព្រះអរហន្ត ជាអនាគាមិបុគ្គល គឺអន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតៈ អកនិដ្ឋគាមីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៦៤) អនាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាគាមី សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៦៥) សកទាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមី សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៦៦) សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ អរហា សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហា សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៦៧) សកទាគាមិផលេន សមន្នាគតោ សកទាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អរហា សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហា សោ សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៦៤) អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ អនាគាមិបុគ្គល ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ អនាគាមិបុគ្គល ជាសកទាគាមិបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៦៥) សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ សកទាគាមិបុគ្គល ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៦៦) បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៦៧) បុគ្គល ប្រកបដោយសកទាគាមិផល គួរនិយាយថា សកទាគាមិបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៦) អនាគាមិផលេន សមន្នាគតោ អនាគាមីតិ ។ វត្តព្វោតិ ។ អាមន្តា ។ អរហា អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហា សោ អនាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៧) សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ អនាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អនាគាមី សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៨) សកទាគាមិផលេន សមន្នាគតោ សកទាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អនាគាមី សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អនាគាមី សោ សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៩) សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ សកទាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ សកទាគាមី សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៦) បុគ្គល ប្រកបដោយអនាគាមិផល គួរនិយាយថា អនាគាមិបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺអនាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៧) បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ អនាគាមិបុគ្គលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៨) បុគ្គល ប្រកបដោយសកទាគាមិផល គួរនិយាយថា សកទាគាមិបុគ្គលឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ អនាគាមិបុគ្គលនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៩) បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ សកទាគាមិបុគ្គលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧០] អរហា សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ន ច អរហា សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហា សោតាបត្តិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហា សោតាបត្តិផលេន សមន្នាគតោតិ ។

[៤៧១] អរហា សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ អបាយគមនិយំ រាគំ អបាយគមនិយំ ទោសំ អបាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៤៧២] អរហា សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ន ច អរហា សកទាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហា សកទាគាមិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហា សកទាគាមិផលេន សមន្នាគតោតិ ។

[៤៧០] ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលទេ ។

[៤៧១] ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ រាគៈ ដែលជាដំណើរទៅកាន់អបាយ ទោសៈ ដែលជាដំណើរទៅកាន់អបាយ និងមោហៈ ដែលជាដំណើរទៅកាន់អបាយ ហើយ ប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៤៧២] ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយសកទាគាមិផលទេ ។

(៤៧៣) អរហា សកទាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សកទាគាមិមគ្គំ វីតិវត្តោ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៧៤) អរហា អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហា អនាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហា អនាគាមិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហា អនាគាមិផលេន សមន្នាគតោតិ ។

(៤៧៥) អរហា អនាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហា អនាគាមិមគ្គំ វីតិវត្តោ អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៧៦) អនាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមី សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមី សោតាបត្តិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អនាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។

(៤៧៣) ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផល ហើយប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៧៤) ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយអនាគាមិផលទេ ។

(៤៧៥) ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផល ហើយប្រកបដោយអនាគាមិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏ស្រាលស្តើង ព្យាបាទដ៏ស្រាលស្តើង ហើយប្រកបដោយអនាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៧៦) អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលទេ ។

(៦៧៧) អនាគាមី សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ ។ បេ ។ អបាយគមនីយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៧៨) អនាគាមី សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមី សកទាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមី សកទាគាមិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អនាគាមី សកទាគាមិផលេន សមន្នាគតោតិ ។

(៦៧៩) អនាគាមី សកទាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី សកទាគាមិមគ្គំ វីតិវត្តោ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៧៧) អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផល ហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។ បេ ។ មោហៈ ដែលជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៧៨) អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលទេ ។

(៦៧៩) អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផល ហើយ ប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៨០] សកទាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ សកទាគាមី សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ សកទាគាមី សោតាបត្តិផលំ វីតិវត្តោ នោ ច វត រេ វត្តព្វេ សកទាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។

[៤៨១] សកទាគាមី សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមី សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ ។ បេ ។ អបាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៨២] ន វត្តព្វំ អរហា ចតូហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហតា ចត្តារិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ អរហតា ចត្តារិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ អរហា ចតូហិ ផលេហិ សមន្នាគតោតិ ។

[៤៨០] សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងសកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើសកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សកទាគាមិបុគ្គលប្រកបដោយសោតាបត្តិផលទេ ។

[៤៨១] សកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផល ហើយប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ សកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។ បេ ។ និងមោហៈ ដែលជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៨២] បុគ្គលមិនគួរនិយាយថា ព្រះអរហន្ត ប្រកបដោយផល ៤ ទេឬ ។ អើ ។ ក្រែងព្រះអរហន្ត បានចំពោះនូវផល ៤ ហើយ មិនសាបសូន្យចាកផល ៤ នោះទេឬ ។ អើ ។ បើព្រះអរហន្ត បានចំពោះនូវផល ៤ មិនសាបសូន្យចាកផល ៤ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះអរហន្ត ប្រកបដោយផល ៤ ដែរ ។

(៤៨៣) ន វត្តព្វំ អនាគាមី តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមិនា តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមិនា តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ អនាគាមី តីហិ ផលេហិ សមន្នាគតោតិ ។

(៤៨៤) ន វត្តព្វំ សកទាគាមី ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ សកទាគាមិនា ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ សកទាគាមិនា ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ សកទាគាមី ទ្វីហិ ផលេហិ សមន្នាគតោតិ ។

(៤៨៥) អរហតា ចត្តារិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អរហា ចតូហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អរហតា ចត្តារោ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ អរហា ចតូហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៨៣) បុគ្គលមិនគួរនិយាយថា អនាគាមិបុគ្គល ប្រកបដោយផល ៣ ទេឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល បានចំពោះនូវផល ៣ ហើយមិនសាបសូន្យចាកផលនោះទេឬ ។ អើ ។ បើអនាគាមិបុគ្គល បានចំពោះនូវផល ៣ ហើយមិនសាបសូន្យចាកផល ៣ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អនាគាមិបុគ្គល ប្រកបដោយផល ៣ ដែរ ។

(៤៨៤) បុគ្គលមិនគួរនិយាយថា សកទាគាមិបុគ្គល ប្រកបដោយផល ២ ទេឬ ។ អើ ។ ក្រែងសកទាគាមិបុគ្គល បានចំពោះនូវផល ២ ហើយមិនសាបសូន្យចាកផល ២ នោះទេឬ ។ អើ ។ បើសកទាគាមិបុគ្គល បានចំពោះនូវផល ២ ហើយមិនសាបសូន្យចាកផល ២ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សកទាគាមិបុគ្គល ប្រកបដោយផល ២ ដែរ ។

(៤៨៥) ព្រះអរហន្ត បានចំពោះនូវផល ៤ ហើយមិនសាបសូន្យចាកផល ៤ នោះទេឬ ។ ព្រះអរហន្ត ប្រកបដោយផល ៤ ឬ ។ អើ ។ ព្រះអរហន្ត បានចំពោះនូវមគ្គ ៤ ហើយមិនសាបសូន្យចាកមគ្គ ៤ នោះទេឬ ។ ព្រះអរហន្ត ប្រកបដោយមគ្គ ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៤៨៦] អនាគាមិនា តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អនាគាមី តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អនាគាមិនា តយោ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ អនាគាមី តីហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៤៨៧] សកទាគាមិនា ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ សកទាគាមី ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមិនា ទ្វេ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ សកទាគាមី ទ្វីហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

សមន្នាគតកថា ។

ឧបេក្ខាសមន្នាគតកថា

[៤៨៨] អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ អរហា ឆហិ ផស្សេហិ ឆហិ វេទនាហិ ឆហិ សញ្ញាហិ ។បេ។ ឆហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៤៨៦] អនាគាមិបុគ្គល បានចំពោះនូវផល ៣ ហើយមិនសាបសូន្យចាកផល ៣ នោះទេឬ ។ អនាគាមិបុគ្គល ប្រកបដោយផល ៣ ឬ ។ អើ ។ អនាគាមិបុគ្គល បានចំពោះនូវមគ្គ ៣ ហើយមិនសាបសូន្យចាកមគ្គ ៣ នោះទេឬ ។ អនាគាមិបុគ្គល ប្រកបដោយមគ្គ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៤៨៧] សកទាគាមិបុគ្គល បានចំពោះនូវផល ២ ហើយមិនសាបសូន្យចាកផល ២ នោះទេឬ ។ សកទាគាមិបុគ្គល ប្រកបដោយផល ២ ឬ ។ អើ ។ សកទាគាមិបុគ្គល បានចំពោះនូវមគ្គ ២ ហើយមិនសាបសូន្យចាកមគ្គ ២ នោះទេឬ ។ សកទាគាមិបុគ្គល ប្រកបដោយមគ្គ ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ សមន្នាគតកថា ។

ឧបេក្ខាសមន្នាគតកថា

[៤៨៨] ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយផស្សៈ ៦ ដោយវេទនា ៦ ដោយសញ្ញា ៦ ។បេ។ ដោយបញ្ញា ៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៨៩) អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ អរហា ចក្ខុនា រូបំ បស្សន្តោ សោតេន សទ្ទំ សុណាតិ ឃានេន គន្ធំ ឃាយតិ ជិវ្ហាយ រសំ សាយតិ កាយេន ផោដ្ឋព្វំ ផុសតិ មនសា ធម្មំ វិជានាតិ ។បេ។ មនសា ធម្មំ វិជានន្តោ ចក្ខុនា រូបំ បស្សតិ សោតេន សទ្ទំ សុណាតិ ឃានេន គន្ធំ ឃាយតិ ជិវ្ហាយ រសំ សាយតិ កាយេន ផោដ្ឋព្វំ ផុសតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៩០) អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ សតតំ សមិតំ អព្វោកិណ្ណំ ឆហិ ឧបេក្ខាហិ សមន្នាគតោ សមោហិតោ ឆ ឧបេក្ខាយោ បច្ចុបដ្ឋិតាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៩១) ន វត្តព្វំ អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហា ឆឡុបេក្ខោតិ ។ អាមន្តា ។ ហញ្ចិ អរហា ឆឡុបេក្ខោ តេន វត រេ វត្តព្វេ អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។

ឧបេក្ខាសមន្នាគតកថា ។

(៦៨៩) ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ ព្រះអរហន្ត កាលឃើញរូបដោយចក្ខុ រមែងឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្ដាត ពាល់ត្រូវផ្សព្វដោយកាយ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ។បេ។ កាលដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត រមែងឃើញរូបដោយចក្ខុ ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្ដាត ពាល់ត្រូវផ្សព្វដោយកាយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៩០) ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ (ព្រះអរហន្ត) ប្រកបដោយឧបេក្ខា ៦ មានចិត្តខ្ជាប់ខ្ជួន ទៀងទាត់ មិនរាយមាយ ចុះឧបេក្ខាទាំង ៦ តាំងឡើងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៩១) បុគ្គលមិនគួរនិយាយថា ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ទេឬ ។ អើ ។ ក្រែងព្រះអរហន្ត មានឧបេក្ខា ៦ ឬ ។ អើ ។ បើព្រះអរហន្ត មានឧបេក្ខា ៦ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ។

ចប់ ឧបេក្ខាសមន្នាគតកថា ។

ពោធិយា ពុទ្ធោតិកថា

(៤៩២) ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ ពោធិយា និរុទ្ធាយ វិគតាយ បដិប្បស្សទ្ធាយ អពុទ្ធោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៩៣) ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ អតីតាយ ពោធិយា ពុទ្ធោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៩៤) អតីតាយ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៩៥) តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ តាយ ពោធិយា ទុក្ខំ បរិជានាតិ សមុទយំ បជហតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៩៦) ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ អនាគតាយ ពោធិយា ពុទ្ធោតិ ។ ន ហេវំ វត្តព្វេ ។បេ។

ពោធិយា ពុទ្ធោតិកថា

(៤៩២) បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណ (ចតុម្មគ្គញ្ញាណ និងសព្វញ្ញុតញ្ញាណ) ឬ ។ អើ ។ បុគ្គល កាលបើពោធិញ្ញាណ រលត់ហើយ ទៅប្រាសហើយ ស្ងប់រម្ងាប់ហើយ មិនឈ្មោះជាព្រះពុទ្ធទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៩៣) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៩៤) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីតឬ ។ អើ ។ ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៩៥) ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ ព្រះពុទ្ធ កំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៩៦) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៩៧) អនាគតាយ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៨) តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៩) បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ អតីតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៥០០) បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ សមុទយំ បជហាតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេតីតិ ។ អាមន្តា ។ អតីតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩៧) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត ឬ ។ អើ ។ ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩៨) ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ ព្រះពុទ្ធ កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩៩) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៥០០) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន កំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ពោធិយា ពុទ្ធោតិកថា

(៨០១) បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ អនាគតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨០២) បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ អាមន្តា ។ អនាគតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨០៣) អតីតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨០៤) អតីតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ពោធិយា ពុទ្ធោតិកថា

(៨០១) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត ធ្វើនូវពោធិករណីយកិច្ចដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨០២) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨០៣) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨០៤) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨០៥) អនាគតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨០៦) អនាគតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨០៧) អតីតាយ ពោធិយា ពុទ្ធោ អនាគតាយ ពោធិយា ពុទ្ធោ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ តីហិ ពោធីហិ ពុទ្ធោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨០៨) តីហិ ពោធីហិ ពុទ្ធោតិ ។ អាមន្តា ។ សតតំ សមិតំ អព្វោកិណ្ណំ តីហិ ពោធីហិ សមន្នាគតោ សមោហិតោ តិស្សោ ពោធិយោ បច្ចុបដ្ឋិតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨០៥) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨០៦) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨០៧) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្នឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨០៨) បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណ ៣ ឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ប្រកបដោយពោធិញ្ញាណទាំង ៣ មានចិត្តខ្ជាប់ខ្ជួន ទៀងទាត់ មិនរាយមាយ ចុះពោធិញ្ញាណទាំង ៣ តាំងនៅប្រាកដ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨០៩) ន វត្តព្វំ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ ននុ ពោធិប្បដិលាភា ពុទ្ធោតិ ។ អាមន្តា ។ ហញ្ចិ ពោធិប្បដិលាភា ពុទ្ធោ តេន វត រេ វត្តព្វេ ពោធិយា ពុទ្ធោតិ ។

(៨១០) ពោធិប្បដិលាភា ពុទ្ធោតិ ។ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ ពោធិប្បដិលាភា ពោធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ពោធិយា ពុទ្ធោតិកថា ។

លក្ខណកថា

(៨១១) លក្ខណសមន្នាគតោ ពោធិសត្តោតិ ។ អាមន្តា ។ បទេសលក្ខណេហិ សមន្នាគតោ បទេសពោធិសត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨១២) លក្ខណសមន្នាគតោ ពោធិសត្តោតិ ។ អាមន្តា ។ តិភាគលក្ខណេហិ សមន្នាគតោ តិភាគពោធិសត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨១៣) លក្ខណសមន្នាគតោ ពោធិសត្តោតិ ។ អាមន្តា ។ ឧបឌ្ឍលក្ខណេហិ សមន្នាគតោ ឧបឌ្ឍពោធិសត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨០៩) បុគ្គលមិនគួរនិយាយថា បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណទេឬ ។ អើ ។ ក្រែងបុគ្គល ជាព្រះពុទ្ធ ព្រោះបានចំពោះនូវពោធិញ្ញាណឬ ។ អើ ។ បើបុគ្គល ជាព្រះពុទ្ធ ព្រោះបានចំពោះនូវពោធិញ្ញាណមែន ម្នាលអ្នកដ៏ចំរើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណទេ ។

(៨១០) បុគ្គល ជាព្រះពុទ្ធ ព្រោះបានចំពោះនូវពោធិញ្ញាណឬ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណឬ ។ អើ ។ ការត្រាស់ដឹង ព្រោះការបានចំពោះនូវពោធិញ្ញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ពោធិយា ពុទ្ធោតិកថា ។

លក្ខណកថា

(៨១១) ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ បទេសពោធិសត្វ ប្រកបដោយបទេសលក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨១២) ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ តិភាគពោធិសត្វ ប្រកបដោយតិភាគលក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨១៣) ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ ឧបឌ្ឍពោធិសត្វប្រកបដោយឧបឌ្ឍលក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨១៤) លក្ខណសមន្នាគតោ ពោធិសត្តោតិ ។ អាមន្តា ។ ចក្កវត្តិសត្តោ លក្ខណសមន្នាគតោ ចក្កវត្តិសត្តោ ពោធិសត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨១៥) ចក្កវត្តិសត្តោ លក្ខណសមន្នាគតោ ចក្កវត្តិសត្តោ ពោធិសត្តោតិ ។ អាមន្តា ។ យាទិសោ ពោធិសត្តស្ស បុព្វយោគោ បុព្វចរិយា ធម្មក្ខានំ ធម្មទេសនា តាទិសោ ចក្កវត្តិសត្តស្ស បុព្វយោគោ បុព្វចរិយា ធម្មក្ខានំ ធម្មទេសនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨១៦) យថា ពោធិសត្តស្ស ជាយមានស្ស ទេវា បឋមំ បដិគ្គណ្ហន្តិ បច្ឆា មនុស្សា ឯវមេវ ចក្កវត្តិសត្តស្ស ជាយមានស្ស ទេវា បឋមំ បដិគ្គណ្ហន្តិ បច្ឆា មនុស្សាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨១៧) យថា ពោធិសត្តស្ស ជាយមានស្ស ចត្តារោ ទេវបុត្តា បដិគ្គហេត្វា មាតុ បុរតោ ឋបេន្តិ អត្តមនា ទេវិ ហោហិ មហេសក្ខោ តេ បុត្តោ ឧប្បន្នោតិ ឯវមេវ ចក្កវត្តិសត្តស្ស ជាយមានស្ស ចត្តារោ ទេវបុត្តា បដិគ្គហេត្វា មាតុ បុរតោ ឋបេន្តិ

(៨១៤) ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ ចក្កវត្តិសត្វ ប្រកបដោយលក្ខណៈ ចុះចក្កវត្តិសត្វ ហៅថាពោធិសត្វឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨១៥) ចក្កវត្តិសត្វ ប្រកបដោយលក្ខណៈ ចុះចក្កវត្តិសត្វ ហៅថាពោធិសត្វឬ ។ អើ ។ បុព្វយោគៈ បុព្វចរិយា ការពោលធម៌ ការសំដែងធម៌ របស់ពោធិសត្វ យ៉ាងណា បុព្វយោគៈ បុព្វចរិយា ការពោលធម៌ ការសំដែងធម៌ របស់ចក្កវត្តិសត្វ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨១៦) កាលពោធិសត្វប្រសូត ពួកទេវតាទទួលមុន ពួកមនុស្សទទួលក្រោយ យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ពួកទេវតាទទួលមុន ពួកមនុស្សទទួលក្រោយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨១៧) កាលពោធិសត្វប្រសូត ទេវបុត្រទាំង ៤ ទទួលហើយតម្កល់ទុក ក្នុងទីចំពោះមុខនៃព្រះមាតាថា បពិត្រនាងទេវី ព្រះនាងចូរត្រេកអរ បុត្ររបស់នាង មានស័ក្តិធំ កើតហើយ យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ទេវបុត្រទាំង ៤ ទទួលហើយតម្កល់ទុក ក្នុងទីចំពោះមុខនៃព្រះមាតាថា

អត្តមនា ទេវ ហោហិ មហេសក្ខោ តេ បុត្តោ ឧប្បន្នោតិ ។ ឆ ហោរំ វត្តព្វ ។ បេ ។

(៨១៨) យទា ពោធិសត្តស្ស ជាយមានស្ស ទ្វេ ឧទកស្ស ធារា អន្តលិក្ខា បាតុភវន្តិ ឯកា សីតស្ស ឯកា ឧណ្ហស្ស យេន ពោធិសត្តស្ស ឧទកកិច្ចំ ករោន្តិ មាតុ ច ឯវមេវ ចក្កវត្តិសត្តស្ស ជាយមានស្ស ទ្វេ ឧទកស្ស ធារា អន្តលិក្ខា បាតុភវន្តិ ឯកា សីតស្ស ឯកា ឧណ្ហស្ស យេន ចក្កវត្តិសត្តស្ស ឧទកកិច្ចំ ករោន្តិ មាតុ ចាតិ ។ ឆ ហោរំ វត្តព្វ ។ បេ ។

(៨១៩) យទា សម្បតិជាតោ ពោធិសត្តោ សមេហិ បាទេហិ បតិដ្ឋហិត្វា ឧត្តរេន អភិមុខោ សត្តបទវីតិហារេន គច្ឆតិ សេតម្ហិ ឆត្តេ អនុធារិយមានេ សព្វា ច ទិសា វិលោកេតិ អាសភិញ្ច វាចំ ភាសតិ អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ឯវមេវ សម្បតិជាតោ ចក្កវត្តិសត្តោ

បពិត្រនាងទេវី ព្រះនាងចូរត្រេកអរចុះ បុត្ររបស់នាង មានស័ក្តិធំ កើតហើយ ក៏យ៉ាងនោះដែរ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨១៨) ពោធិសត្វប្រសូត ខ្សែទឹក ២ គឺខ្សែទឹកត្រជាក់ ១ ខ្សែទឹកក្តៅ ១ ធ្លាក់មកប្រាកដអំពីអាកាស ធ្វើកិច្ចជម្រះដោយទឹក ចំពោះព្រះពោធិសត្វផង ចំពោះព្រះមាតាផង យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ខ្សែទឹក ២ គឺខ្សែទឹកត្រជាក់ ១ ខ្សែទឹកក្តៅ ១ ធ្លាក់មកប្រាកដអំពីអាកាស ធ្វើកិច្ចជម្រះដោយទឹក ចំពោះចក្កវត្តិសត្វផង ចំពោះព្រះមាតាផង ក៏យ៉ាងនោះដែរ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨១៩) ព្រះពោធិសត្វប្រសូតមកភ្លាម ជាន់ដោយព្រះបាទដ៏ស្មើ មានមុខបែរទៅកាន់ទិសខាងជើង ឈានទៅ ៧ ជំហាន កាលពួកទេវតាបាំងស្វេតច្ឆត្រ ក៏រមិលមើលសព្វទិស បន្លឺឡើងនូវអាសភិវាចាថា អញជាបុគ្គលឆ្នើមរបស់លោក អញជាបុគ្គលច្បងរបស់លោក អញជាបុគ្គលប្រសើររបស់លោក នេះជាជាតិទីបំផុត (របស់អញ) ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ យ៉ាងណា ចក្កវត្តិសត្វប្រសូតមកភ្លាម

សមេហិ បាទេហិ បតិដ្ឋហិត្វា ឧត្តរេន អភិមុខោ សត្តបទវីតិហារេន គច្ឆតិ សេតម្ហិ ឆត្តេ អនុធារិយ-មានេ សព្វា ច ទិសា វិលោកេតិ អាសភិញ្ច វាចំ ភាសតិ អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨២០) យថា ពោធិសត្តស្ស ជាយមានស្ស មហតោ អាលោកស្ស មហតោ ឱភាសស្ស មហ-តោ ភូមិចាលស្ស បាតុភាវោ ហោតិ ឯវមេវ ចក្ក-វត្តិសត្តស្ស ជាយមានស្ស មហតោ អាលោកស្ស មហតោ ឱភាសស្ស មហតោ ភូមិចាលស្ស បាតុភា-វោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨២១) យថា ពោធិសត្តស្ស បកតិកាយោ សមន្តា ព្យាមំ ឱភាសតិ ឯវមេវ ចក្កវត្តិសត្តស្ស បកតិកាយោ សមន្តា ព្យាមំ ឱភាសតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ជាន់ដោយព្រះបាទដ៏ស្មើ មានមុខបែរទៅកាន់ទិសខាងជើង ឈានទៅ ៧ ជំហាន កាលពួកទេវតាបាំងស្វេតច្ឆត្រ ក៏រមិលមើលសព្វទិស បន្លឺឡើងនូវអាសភិវាចាថា អញជាបុគ្គលឆ្នើមរបស់លោក អញជាបុគ្គលច្បងរបស់លោក អញជាបុគ្គលប្រសើររបស់លោក នេះជាជាតិទីបំផុត (របស់អញ) ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨២០) កាលព្រះពោធិសត្វប្រសូត ការកើតឡើងប្រាកដ នៃពន្លឺដ៏ធំ នៃរស្មីដ៏ធំ នៃការកម្រើកញាប់ញ័រផែនដីខ្លាំង យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ការកើតឡើងប្រាកដ នៃពន្លឺដ៏ធំ នៃរស្មីដ៏ធំ នៃការកម្រើកញាប់ញ័រផែនដីខ្លាំង ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨២១) កាយប្រក្រតី របស់ពោធិសត្វ រមែងភ្លឺទៅមួយព្យាមដោយជុំវិញ យ៉ាងណា កាយប្រក្រតី របស់ចក្កវត្តិសត្វ រមែងភ្លឺទៅមួយព្យាមដោយជុំវិញ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨៦៦) យថា ពោធិសត្តោ មហាសុបិនំ បស្សិ ឯវមេវ ចក្កវត្តិសត្តោ មហាសុបិនំ បស្សតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨៦៧) ន វត្តព្វំ លក្ខណសមន្នាគតោ ពោធិសត្តោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ទ្វត្តិំសិមានិ **ភិក្ខវេ** មហាបុរិសស្ស មហាបុរិសលក្ខណានិ យេហិ សមន្នាគតស្ស មហាបុរិសស្ស ទ្វេវ គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ តស្សិមានិ សត្តរតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថិរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា សោ ឥមំ បឋវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន អភិវិជិយ អជ្ឈាវសតិ សចេ បន ខោ អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ

(៨៦៦) ព្រះពោធិសត្វ ឃើញមហាសុបិន យ៉ាងណា ចក្រពត្តិសត្វ ឃើញមហាសុបិន ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨៦៧) បុគ្គលមិនគួរនិយាយថា ព្រះពោធិសត្វ ប្រកបដោយលក្ខណៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាបុរស ប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ នេះ រមែងមានតែគតិ ២ យ៉ាងប៉ុណ្ណោះ មិនមែនខុសអំពីគតិ ២ យ៉ាងនោះទេ គឺថាបើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្ដេចចក្រពត្តិ ជាធម្មិកប្រកបដោយធម៌ ជាឥស្សរៈលើផែនដីដែលមានសមុទ្រទាំង ៤ ជាទីបំផុត ឈ្នះអស់សត្រូវទាំងខាងក្នុងខាងក្រៅ ដល់នូវភាពមាំមួនក្នុងជនបទ ប្រកបដោយកែវទាំង ៧ ប្រការ ឯកែវទាំង ៧ ប្រការ នេះ របស់ស្ដេចចក្រពត្តិនោះ គឺចក្រកែវ ១ ដំរីកែវ ១ សេះកែវ ១ មណីកែវ ១ ស្ត្រីកែវ ១ គហបតីកែវ ១ បរិនាយកកែវ ១ ទៀតជាគម្រប់ ៧ ព្រះរាជានោះ មានព្រះរាជបុត្រ ច្រើនជាងពាន់ ដែលជាអ្នកក្លៀវក្លា មានសភាពអង់អាច អាចញាំញីនូវសេនានៃស្ដេចដទៃបាន ព្រះរាជានោះ មានជ័យជំនះ នៅគ្រប់គ្រងផែនដីនេះដែលមានសាគរជាទីបំផុត ដោយធម៌ ដោយមិនមានគ្រឿងវាយដំ ដោយមិនមានគ្រឿងកាប់ចាក់ បើចេញចាកផ្ទះចូលទៅកាន់ផ្នួសវិញ នឹងបានជាអរហន្តសម្មាសម្ពុទ្ធ មាន

លោកេ វិវដ្ដច្ឆទោតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ លក្ខណសមន្នាគតោ ពោធិសត្តោតិ ។

លក្ខណកថា ។

និយាមោក្កន្តិកថា

(៨៦៤) ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ពោធិសត្តោ កស្សបស្ស ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៨៦៥) ពោធិសត្តោ កស្សបស្ស ភគវតោ សាវកោតិ ។ អាមន្តា ។ សាវកោ ហុត្វា ពុទ្ធោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៨៦៦) សាវកោ ហុត្វា ពុទ្ធោ ហោតីតិ ។ អាមន្តា ។ អនុស្សវិយោតិ ។ ន ហេវំ វត្តព្វេ ។បេ។

ដំបូលនៃកិលេសបើកហើយ ក្នុងលោក ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពោធិសត្វ ប្រកបដោយលក្ខណៈ (ដោយពិត) ។

ចប់ លក្ខណកថា ។

និយាមោក្កន្តិកថា

(៨៦៤) ព្រះពោធិសត្វ[1] មាននិយាមៈ[2] យាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ ព្រះពោធិសត្វ ជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៨៦៥) ព្រះពោធិសត្វ ជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ (ព្រះពោធិសត្វ) បានជាសាវ័កហើយ ទើបបានត្រាស់ជាព្រះពុទ្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៨៦៦) (ព្រះពោធិសត្វ) បានជាសាវ័កហើយ ទើបបានត្រាស់ជាព្រះពុទ្ធឬ ។ អើ ។ (បុគ្គលជាព្រះពុទ្ធ) ប្រកបដោយការស្តាប់តាមគេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

១ សំដៅយកពោធិសត្វ កាលកើតជាជោតិបាល បានបួសក្នុងសំណាក់ព្រះកស្សបមានព្រះភាគ ។ ២ ជាឈ្មោះនៃអរិយមគ្គ ។

(៤៦៧) អនុស្សវិយោតិ(១) ។ អាមន្តា ។ ននុ ភគវា សយម្ភូតិ ។ អាមន្តា ។ ហញ្ចិ ភគវា សយម្ភូ នោ វត រេ វត្តព្វេ អនុស្សវិយោតិ ។

(៤៦៨) ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ភគវា ពោធិយា មូលេ តីណេវ សាមញ្ញផលានិ អភិសម្ពុទ្ធោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៦៩) ននុ ភគវា ពោធិយា មូលេ ចត្តារិ សាមញ្ញផលានិ អភិសម្ពុទ្ធោតិ ។ អាមន្តា ។ ហញ្ចិ ភគវា ពោធិយា មូលេ ចត្តារិ សាមញ្ញផលានិ អភិសម្ពុទ្ធោ នោ វត រេ វត្តព្វេ ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។

(៤៧០) ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ពោធិសត្តោ ទុក្ករការិកំ អកាសីតិ ។

១ អដ្ឋកថាយំ អនុស្សវិកោតិ ទិស្សតិ ។

(៩៩៣) បឋវីកសិណំ សមាបត្តឹ សមាបន្នស្ស វិបាកេ ញាណំ តញ្ច កុសលន្តិ ? អាមន្តា ? អ-និច្ចេ និច្ចន្តិ វិបរិយេសោ សោ ច កុសលោតិ ? ន ហេវំ វត្តព្វេ ។បេ។ បឋវីកសិណំ សមាបត្តឹ សមាបន្នស្ស វិបាកេ ញាណំ តញ្ច កុសលន្តិ ? អាមន្តា ? ទុក្ខេ សុខន្តិ ។បេ។ អនត្តនិ អត្តាតិ ។បេ។ អសុភេ សុភន្តិ វិបរិយេសោ សោ ច កុ-សលោតិ ? ន ហេវំ វត្តព្វេ ។បេ។

(៩៩៤) បឋវីកសិណំ សមាបត្តឹ សមាបន្នស្ស វិបាកេ ញាណន្តិ ? អាមន្តា ? អរហា បឋវីក-សិណំ សមាបត្តឹ សមាបជ្ជេយ្យាតិ ? អាមន្តា ? ហញ្ចិ អរហា បឋវីកសិណំ សមាបត្តឹ សមាបជ្ជេ-យ្យ នោ វត រេ វត្តព្វេ បឋវីកសិណំ សមាបត្តឹ សមាបន្នស្ស វិបាកេ ញាណន្តិ ។

(៩៩៥) បឋវីកសិណំ សមាបត្តឹ សមាបន្នស្ស វិបាកេ ញាណំ អរហា បឋវីកសិណំ សមាបត្តឹ សមាបជ្ជេយ្យាតិ ? អាមន្តា ? អត្ថិ អរហតោ វិបរិ-យេសោតិ ? ន ហេវំ វត្តព្វេ ។បេ។

(៩៩៣) វិបរិតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណ-សមាបត្តិ (មាន) ចុះញាណនោះ ជាកុសលឬ ? អើ ? សេចក្ដីប្រកាន់ផ្ដុយ ជាទៀង គឺរបស់មិនទៀង ចុះសេចក្ដីប្រកាន់ផ្ដុយនោះ ជាកុសលឬ ? អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វិបរិតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ (មាន) ចុះញាណនោះ ជាកុសលឬ ? អើ ? សេចក្ដីប្រកាន់ផ្ដុយ ជាសុខ គឺរបស់ជាទុក្ខ ។បេ។ ជាខ្លួន គឺរបស់មិនមែនខ្លួន ។បេ។ ជាស្អាត គឺរបស់មិនស្អាត ចុះសេចក្ដីប្រកាន់ផ្ដុយនោះ ជាកុសលឬ ? អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៩៩៤) វិបរិតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណ-សមាបត្តិ (មាន) ឬ ? អើ ? ព្រះអរហន្ត ចូលកាន់បឋវីកសិណ-សមាបត្តិឬ ? អើ ? បើព្រះអរហន្ត ចូលកាន់បឋវីកសិណសមាបត្តិ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបរិតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មានទេ ។

(៩៩៥) វិបរិតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណ-សមាបត្តិ (មាន) ព្រះអរហន្ត ចូលកាន់បឋវីកសិណសមាបត្តិឬ ? អើ ? សេចក្ដីប្រកាន់ផ្ដុយ របស់ព្រះអរហន្ត មានដែរឬ ? អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៨៩៦) អត្ថិ អរហតោ វិបរិយេសោតិ ។ អាមន្តា ។ អត្ថិ អរហតោ សញ្ញាវិបរិយេសោ ចិត្តវិបរិយេសោ ទិដ្ឋិវិបរិយេសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨៩៧) នត្ថិ អរហតោ សញ្ញាវិបរិយេសោ ចិត្តវិបរិយេសោ ទិដ្ឋិវិបរិយេសោតិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ សញ្ញាវិបរិយេសោ ចិត្តវិបរិយេសោ ទិដ្ឋិវិបរិយេសោ នោ ច វត រេ វត្តព្វេ អត្ថិ អរហតោ វិបរិយេសោតិ ។

(៨៩៨) ន វត្តព្វំ បឋវីកសិណំ សមាបត្តិំ សមាបន្នស្ស វិបរីតេ ញាណន្តិ ។ អាមន្តា ។ បឋវីកសិណំ សមាបត្តិំ សមាបជ្ជន្តស្ស សព្វំ បឋវី ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ បឋវីកសិណំ សមាបត្តិំ សមាបន្នស្ស វិបរីតេ ញាណន្តិ ។

(៨៩៩) បឋវីកសិណំ សមាបត្តិំ សមាបន្នស្ស វិបរីតេ ញាណន្តិ ។ អាមន្តា ។ ននុ បឋវី អត្ថិ អត្ថិ ច កោចិ បឋវី បឋវិតោ សមាបជ្ជតីតិ ។ អាមន្តា ។ ហញ្ចិ បឋវី អត្ថិ អត្ថិ ច កោចិ

(៨៩៦) សេចក្តីប្រកាន់ខុស របស់ព្រះអរហន្ត មានឬ ។ អើ ។ សេចក្តីប្រកាន់ខុសដោយសញ្ញា សេចក្តីប្រកាន់ខុសដោយចិត្ត សេចក្តីប្រកាន់ខុសដោយទិដ្ឋិ របស់ព្រះអរហន្ត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨៩៧) សេចក្តីប្រកាន់ខុសដោយសញ្ញា សេចក្តីប្រកាន់ខុសដោយចិត្ត សេចក្តីប្រកាន់ខុសដោយទិដ្ឋិ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើសេចក្តីប្រកាន់ខុសដោយសញ្ញា សេចក្តីប្រកាន់ខុសដោយចិត្ត សេចក្តីប្រកាន់ខុសដោយទិដ្ឋិ របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីប្រកាន់ខុស របស់ព្រះអរហន្ត មានទេ ។

(៨៩៨) បុគ្គលមិនគួរនិយាយថា វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ (មាន) ទេឬ ។ អើ ។ បុគ្គលកាលចូលកាន់បឋវីកសិណសមាបត្តិ ។ ធម្មជាតិទាំងអស់ ទៅជាផែនដីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ វិបរីតញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មាន ។

(៨៩៩) វិបរីតញ្ញាណ របស់បុគ្គលចូលកាន់បឋវីកសិណសមាបត្តិ មានឬ ។ អើ ។ ក្រែងផែនដី មាន បុគ្គលទីមួយ ចូលកាន់ផែនដី ដោយផែនដី មានដែរឬ ។ អើ ។ បើផែនដី មាន បុគ្គលទីមួយ

បថវឹ បថវិតោ សមាបជ្ជតិ នោ ចេ វត រេ វត្តព្វេ បថវី-កសិណំ សមាបត្តឹ សមាបន្នស្ស វិបាកេ ញាណន្តិ ។

(៦០០) បថវី អត្ថិ បថវី បថវិតោ សមាបជ្ជន្តស្ស វិបាកំ ហោតីតិ ។ អាមន្តា ។ និព្វានំ អត្ថិ និព្វានំ និព្វានតោ សមាបជ្ជន្តស្ស វិបាកំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ ន វត្តព្វំ បថវី-កសិណំ សមាបត្តឹ សមាបន្នស្ស វិបាកេ ញាណន្តិ ។

វិបាកកថា ។

និយាមកថា

(៦០១) អនិយតស្ស និយាមគមនាយ អត្ថិ ញាណន្តិ ។ អាមន្តា ។ និយតស្ស អនិយាមគមនាយ អត្ថិ ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦០២) និយតស្ស អនិយាមគមនាយ នត្ថិ ញាណន្តិ ។ អាមន្តា ។ អនិយតស្ស និយាមគមនាយ នត្ថិ ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ចូលកាន់ផែនដី ដោយផែនដី មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបាកញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មានទេ ។

(៦០០) ផែនដី មាន វិបាកញ្ញាណ របស់បុគ្គលដែលចូលកាន់ផែនដី ដោយផែនដី មានដែរឬ ។ អើ ។ និព្វាន មាន វិបាកញ្ញាណ របស់បុគ្គលដែលចូលកាន់និព្វាន ដោយនិព្វាន មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា វិបាកញ្ញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មានទេ ។

ចប់ វិបាកកថា ។

និយាមកថា

(៦០១) ញាណ គឺដំណើរទៅកាន់និយាមៈគឺមគ្គ របស់បុគ្គលជាអនិយតៈ (បុថុជ្ជន) មានដែរឬ ។ អើ ។ ញាណ គឺដំណើរទៅកាន់អនិយាមៈ របស់បុគ្គលជានិយតៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦០២) ញាណ គឺដំណើរទៅកាន់អនិយាមៈ របស់បុគ្គលជានិយតៈ មិនមានទេឬ ។ អើ ។ ញាណ គឺដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦០៣] អនិយតស្ស និយាមគមនាយ អត្ថិ ញាណន្តិ ។ អាមន្តា ។ និយតស្ស និយាមគមនាយ អត្ថិ ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦០៤] និយតស្ស និយាមគមនាយ នត្ថិ ញាណន្តិ ។ អាមន្តា ។ អនិយតស្ស និយាមគមនាយ នត្ថិ ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦០៥] អនិយតស្ស និយាមគមនាយ អត្ថិ ញាណន្តិ ។ អាមន្តា ។ អនិយតស្ស អនិយាមគមនាយ អត្ថិ ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦០៦] អនិយតស្ស អនិយាមគមនាយ នត្ថិ ញាណន្តិ ។ អាមន្តា ។ អនិយតស្ស និយាមគមនាយ នត្ថិ ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦០៧] អនិយតស្ស និយាមគមនាយ អត្ថិ ញាណន្តិ ។ អាមន្តា ។ អនិយតស្ស និយាមគមនាយ អត្ថិ និយាមោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦០៣] ញាណ គឺដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មានដែរឬ ។ អើ ។ ញាណ គឺដំណើរទៅកាន់និយាមៈ របស់បុគ្គលជានិយតៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦០៤] ញាណ គឺដំណើរទៅកាន់និយាមៈ របស់បុគ្គលជានិយតៈ មិនមានទេឬ ។ អើ ។ ញាណ គឺការទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦០៥] ញាណ គឺដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មានដែរឬ ។ អើ ។ ញាណ គឺដំណើរទៅកាន់អនិយាមៈ របស់បុគ្គលជាអនិយតៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦០៦] ញាណ គឺដំណើរទៅកាន់អនិយាមៈ របស់បុគ្គលជាអនិយតៈ មិនមានទេឬ ។ អើ ។ ញាណ គឺដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦០៧] ញាណ គឺដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មានដែរឬ ។ អើ ។ និយាមៈ (មគ្គ) គឺដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦០៨] អនិយតស្ស និយាមគមនាយ អត្ថិ ញាណន្តិ ។ អាមន្តា ។ អនិយតស្ស និយាមគមនាយ អត្ថិ សតិប្បដ្ឋានា ។ បេ ។ សម្មប្បធានា ឥទ្ធិបាទា ឥន្ទ្រិយា ពលា ពោជ្ឈង្គាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦០៩] អនិយតស្ស និយាមគមនាយ នត្ថិ និយាមោតិ ។ អាមន្តា ។ ហញ្ចិ អនិយតស្ស និយាមគមនាយ នត្ថិ និយាមោ នោ ច វត រេ វត្តព្វេ អនិយតស្ស និយាមគមនាយ អត្ថិ ញាណន្តិ ។

[៦១០] អនិយតស្ស និយាមគមនាយ នត្ថិ សតិប្បដ្ឋានា ។ បេ ។ ពោជ្ឈង្គាតិ ។ អាមន្តា ។ ហញ្ចិ អនិយតស្ស និយាមគមនាយ នត្ថិ ពោជ្ឈង្គា នោ ច វត រេ វត្តព្វេ អនិយតស្ស និយាមគមនាយ អត្ថិ ញាណន្តិ ។

[៦១១] អនិយតស្ស និយាមគមនាយ អត្ថិ ញាណន្តិ ។ អាមន្តា ។ គោត្រភុនោ បុគ្គលស្ស សោតាបត្តិមគ្គេ ញាណំ អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦០៨) ញាណ គួរដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មានឬ ។ អើ ។ សតិប្បដ្ឋាន ។ បេ ។ សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ គួរដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦០៩) និយាមៈ (មគ្គ) គួរដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មិនមានទេឬ ។ អើ ។ បើនិយាមៈ គួរដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ គួរដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មានទេ ។

(៦១០) សតិប្បដ្ឋាន ។ បេ ។ ពោជ្ឈង្គៈ គួរដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មិនមានទេឬ ។ អើ ។ បើពោជ្ឈង្គៈ គួរដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ គួរដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មានទេ ។

(៦១១) ញាណ គួរដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអនិយតៈ មានឬ ។ អើ ។ ញាណ ក្នុងសោតាបត្តិមគ្គ របស់បុគ្គលជាគោត្រភូ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦១២] សោតាបត្តិផលសច្ឆិកិរិយាយ បដិ-
បន្នស្ស បុគ្គលស្ស សោតាបត្តិផលេ ញាណំ អត្ថីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិផលសច្ឆិកិរិ-
យាយ ។ បេ ។ អនាគាមិផលសច្ឆិកិរិយាយ ។ បេ ។
អរហត្តសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អរហត្តេ
ញាណំ អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦១៣] ន វត្តព្វំ អនិយតស្ស និយាមគមនាយ
អត្ថិ ញាណន្តិ ។ អាមន្តា ។ ននុ ភគវា ជានាតិ
អយំ បុគ្គលោ សម្មត្តនិយាមំ ឱក្កមិស្សតិ ភព្វោ
អយំ បុគ្គលោ ធម្មំ អភិសមេតុន្តិ ។ អាមន្តា ។
ហញ្ចិ ភគវា ជានាតិ អយំ បុគ្គលោ សម្មត្តនិយាមំ
ឱក្កមិស្សតិ ភព្វោ អយំ បុគ្គលោ ធម្មំ អភិសមេតុំ
តេន វត រេ វត្តព្វេ អនិយតស្ស និយាមគមនាយ
អត្ថិ ញាណន្តិ ។

និយាមកថា ។

បដិសម្ភិទាកថា

[៦១៤] សព្វំ ញាណំ បដិសម្ភិទាតិ ។ អាមន្តា ។

[៦១២] ញាណ ក្នុងសោតាបត្តិផល របស់បុគ្គលអ្នកប្រតិបត្តិ
ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ។ បេ ។
ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។ បេ ។ ញាណ ក្នុងព្រះអរហត្ត
របស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មានឬ ។ អ្នក
មិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦១៣] បុគ្គលមិនគួរនិយាយថា ញាណ ក្នុងដំណើរទៅកាន់
និយាមៈ របស់បុគ្គលជាអនិយតៈ មានទេឬ ។ អើ ។ ក្រែងព្រះមាន
ព្រះភាគ ទ្រង់ជ្រាបថា បុគ្គលនេះ នឹងឈានចុះកាន់សម្មត្តនិយាម
បុគ្គលនេះ គួរដើម្បីត្រាស់ដឹងនូវធម៌បានឬ ។ អើ ។ បើព្រះមាន
ព្រះភាគ ទ្រង់ជ្រាបថា បុគ្គលនេះ នឹងឈានចុះកាន់សម្មត្តនិយាម
បុគ្គលនេះ គួរដើម្បីត្រាស់ដឹងនូវធម៌បាន ម្នាលអ្នកដ៏ចម្រើន ព្រោះ
ហេតុនោះ អ្នកគួរពោលថា ញាណ ក្នុងដំណើរទៅកាន់និយាមៈ របស់
បុគ្គលជាអនិយតៈ មាន ។

ចប់ និយាមកថា

បដិសម្ភិទាកថា

[៦១៤] ញាណទាំងអស់ ឈ្មោះថាបដិសម្ភិទាឬ ។ អើ ។

សម្មុតិញាណំ បដិសម្ភិទាតិ ។ ន ហេវំ វត្តព្វេ ។បេ។ សម្មុតិញាណំ បដិសម្ភិទាតិ ។ អាមន្តា ។ យេ កេចិ សម្មតឹ ជានន្តិ សព្វេ តេ បដិសម្ភិទប្បត្តាតិ ។ ន ហេវំ វត្តព្វេ ។បេ។ សព្វំ ញាណំ បដិសម្ភិទាតិ ។ អាមន្តា ។ ចេតោបរិយាយេ ញាណំ បដិសម្ភិទាតិ ។ ន ហេវំ វត្តព្វេ ។បេ។ ចេតោបរិយាយេ ញាណំ បដិសម្ភិទាតិ ។ អាមន្តា ។ យេ កេចិ បរចិត្តំ ជានន្តិ សព្វេ តេ បដិសម្ភិទប្បត្តាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦១៨) សព្វំ ញាណំ បដិសម្ភិទាតិ ។ អាមន្តា ។ សព្វា បញ្ញា បដិសម្ភិទាតិ ។ ន ហេវំ វត្តព្វេ ។បេ។ សព្វា បញ្ញា បដិសម្ភិទាតិ ។ អាមន្តា ។ បឋវីកសិណំ សមាបត្តឹ សមាបន្នស្ស អត្ថិ បញ្ញា សា បញ្ញា បដិសម្ភិទាតិ ។ ន ហេវំ វត្តព្វេ ។បេ។ អាបោកសិណំ ។បេ។ តេជោកសិណំ ។បេ។ វាយោកសិណំ ។បេ។ នីលកសិណំ ។បេ។ បីតកសិណំ ។បេ។ លោហិតកសិណំ ។បេ។ ឱទាតកសិណំ ។បេ។ អាកាសានញ្ចាយតនំ

សម្មុតិញាណ (ការដឹងនូវសម្មតិ) ឈ្មោះថាបដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មុតិញាណ ឈ្មោះថាបដិសម្ភិទាឬ ។ អើ ។ ពួកជនណាមួយ ដឹងនូវសម្មតិ ពួកជនទាំងអស់នោះ ឈ្មោះថាដល់នូវបដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណទាំងអស់ ឈ្មោះថាបដិសម្ភិទាឬ ។ អើ ។ ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) ឈ្មោះថាបដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) ឈ្មោះថាបដិសម្ភិទាឬ ។ អើ ។ ពួកជនណាមួយ ដឹងនូវចិត្តនៃបុគ្គលដទៃ ពួកជនទាំងអស់នោះ ឈ្មោះថាដល់នូវបដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦១៨) ញាណទាំងអស់ ឈ្មោះថាបដិសម្ភិទាឬ ។ អើ ។ បញ្ញាទាំងអស់ ឈ្មោះថាបដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញាទាំងអស់ ឈ្មោះថាបដិសម្ភិទាឬ ។ អើ ។ បញ្ញារបស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មាន ចុះបញ្ញានោះ ឈ្មោះថាបដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញារបស់បុគ្គលដែលចូលកាន់អាបោកសិណ ។បេ។ តេជោកសិណ ។បេ។ វាយោកសិណ ។បេ។ នីលកសិណ ។បេ។ បីតកសិណ ។បេ។ លោហិតកសិណ ។បេ។ ឱទាតកសិណ ។បេ។ អាកាសានញ្ចាយតនៈ

។ បេ ។ វិញ្ញាណញ្ចាយតនំ ។ បេ ។ អាកិញ្ចញ្ញាយតនំ ។ បេ ។ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស ។ បេ ។ ទានំ ទទន្តស្ស ។ បេ ។ ចីវរំ ទទន្តស្ស ។ បេ ។ បិណ្ឌបាតំ ទទន្តស្ស ។ បេ ។ សេនាសនំ ទទន្តស្ស ។ បេ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទទន្តស្ស អត្ថិ បញ្ញា សា បញ្ញា បដិសម្ភិទាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦១៦) ន វត្តព្វំ សព្វំ ញាណំ បដិសម្ភិទាតិ ។ អាមន្តា ។ អត្ថិ លោកុត្តរា បញ្ញា សា បញ្ញា ន បដិសម្ភិទាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ សព្វំ ញាណំ បដិសម្ភិទាតិ ។

បដិសម្ភិទាកថា ។

សម្មុតិញាណកថា

(៦១៧) ន វត្តព្វំ សម្មុតិញាណំ សច្ចារម្មណញ្ញេវ ន អញ្ញារម្មណន្តិ ។ អាមន្តា ។ ននុ បថវីកសិណំ សមាបត្តិំ សមាបន្នស្ស អត្ថិ ញាណំ

។ បេ ។ វិញ្ញាណញ្ចាយតនៈ ។ បេ ។ អាកិញ្ចញ្ញាយតនៈ ។ បេ ។ នេវសញ្ញានាសញ្ញាយតនៈ ។ បេ ។ កាលឲ្យទាន ។ បេ ។ កាលឲ្យចីវរ ។ បេ ។ កាលឲ្យបិណ្ឌបាត ។ បេ ។ កាលឲ្យសេនាសនៈ ។ បេ ។ កាលឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ មាន ចុះបញ្ញានោះ ឈ្មោះថាបដិសម្ភិទាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦១៦) បុគ្គលមិនគួរនិយាយថា ញាណទាំងអស់ ឈ្មោះថាបដិសម្ភិទាទេឬ ។ អើ ។ បញ្ញា ជាលោកុត្តរៈ មាន ចុះបញ្ញានោះ មិនឈ្មោះថាបដិសម្ភិទាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ញាណទាំងអស់ ឈ្មោះថាបដិសម្ភិទាដែរ ។

ចប់ បដិសម្ភិទាកថា ។

សម្មុតិញាណកថា

(៦១៧) បុគ្គលមិនគួរនិយាយថា សម្មតិញាណ មានសច្ចៈជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេឬ ។ អើ ។ ក្រែងញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មាន ទាំង

បឋវីកសិណាយ សម្មតិសច្ចម្ហីតិ ។ អាមន្តា ។ ហញ្ចិ បឋវីកសិណំ សមាបត្តឹ សមាបន្នស្ស អត្ថិ ញាណំ បឋវីកសិណាយ សម្មតិសច្ចម្ហិ តេន វត រេ វត្តព្វេ សម្មតិញាណំ សច្ចារម្មណញ្ញេវ ន អញ្ញារម្មណន្តិ ។

(៦១៨) ន វត្តព្វំ សម្មតិញាណំ សច្ចារម្មណញ្ញេវ ន អញ្ញារម្មណន្តិ ។ អាមន្តា ។ ននុ អាបោកសិណំ ។បេ។ តេជោកសិណំ ។ បេ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទទន្តស្ស អត្ថិ ញាណំ គិលានប្បច្ចយភេសជ្ជបរិក្ខារេ ច សម្មតិសច្ចម្ហីតិ ។ អាមន្តា ។ ហញ្ចិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទទន្តស្ស អត្ថិ ញាណំ គិលានប្បច្ចយភេសជ្ជបរិក្ខារេ ច សម្មតិសច្ចម្ហិ តេន វត រេ វត្តព្វេ សម្មតិញាណំ សច្ចារម្មណញ្ញេវ ន អញ្ញារម្មណន្តិ ។

(៦១៩) សម្មតិញាណំ សច្ចារម្មណញ្ញេវ ន អញ្ញារម្មណន្តិ ។ អាមន្តា ។ តេន ញាណេន ទុក្ខំ បរិជានាតិ សមុទយំ បជហតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

សម្មតិញ្ញាណកថា ។

បឋវីកសិណ ក្នុងសម្មតិសច្ចៈ ក៏មានឬ ។ អើ ។ បើញាណ របស់បុគ្គលដែលចូលកាន់បឋវីកសិណសមាបត្តិ មាន ចំពោះបឋវីកសិណ ក្នុងសម្មតិសច្ចៈ ក៏មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សម្មតិញាណ មានសច្ចៈជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេ ។

(៦១៨) បុគ្គលមិនគួរនិយាយថា សម្មតិញាណ មានសច្ចៈជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេឬ ។ អើ ។ ក្រែងញាណ របស់បុគ្គលដែលចូលកាន់អាបោកសិណ ។បេ។ តេជោកសិណ ។បេ។ កាលឲ្យគិលានប្បច្ច័យភេសជ្ជបរិក្ខារ មាន ឯគិលានប្បច្ច័យភេសជ្ជបរិក្ខារ ក្នុងសម្មតិសច្ចៈ ក៏មានឬ ។ អើ ។ បើញាណ របស់បុគ្គលកាលឲ្យគិលានប្បច្ច័យភេសជ្ជបរិក្ខារ មាន ឯគិលានប្បច្ច័យភេសជ្ជបរិក្ខារ ក្នុងសម្មតិសច្ចៈ ក៏មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សម្មតិញាណ មានសច្ចៈជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេ ។

(៦១៩) សម្មតិញាណ មានសច្ចៈជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេឬ ។ អើ ។ បុគ្គល កំណត់ដឹងនូវទុក្ខ លះនូវសមុទយៈ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ ចម្រើននូវមគ្គ ដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ សម្មតិញ្ញាណកថា ។

ចិត្តារម្មណកថា

(៦៦០) ចេតោបរិយាយេ ញាណំ ចិត្តារម្មណា-ញ្ញេវ ន អញ្ញារម្មណន្តិ ។ អាមន្តា ។ ននុ អត្ថិ កោចិ សរាគំ ចិត្តំ សរាគំ ចិត្តន្តិ បជានាតីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ សរាគំ ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ នោ វត រេ វត្តព្វេ ចេតោបរិយាយេ ញាណំ ចិត្តារម្មណញ្ញេវ ន អញ្ញារម្មណន្តិ ។ ននុ អត្ថិ កោចិ វីតរាគំ ចិត្តំ វីតរាគំ ចិត្តន្តិ ។បេ។ សទោសំ ចិត្តំ ។បេ។ វីតទោសំ ចិត្តំ សមោហំ ចិត្តំ វីតមោហំ ចិត្តំ សង្ខិត្តំ ចិត្តំ វិក្ខិត្តំ ចិត្តំ មហគ្គតំ ចិត្តំ អមហគ្គតំ ចិត្តំ សឧត្តរំ ចិត្តំ អនុត្តរំ ចិត្តំ សមាហិតំ ចិត្តំ អសមាហិតំ ចិត្តំ

ចិត្តារម្មណកថា

(៦៦០) ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេឬ ។ អើ ។ ក្រែងបុគ្គលណាមួយ ដឹងច្បាស់នូវចិត្តដែលប្រកបដោយរាគៈ ថាចិត្តប្រកបដោយរាគៈដូច្នេះឬ ។ អើ ។ បើបុគ្គលណាមួយ ដឹងច្បាស់នូវចិត្តដែលប្រកបដោយរាគៈ ថាចិត្តប្រកបដោយរាគៈដូច្នេះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេ ។ ក្រែងបុគ្គលណាមួយ ដឹងច្បាស់នូវចិត្តដែលប្រាសចាករាគៈ ថាចិត្តប្រាសចាករាគៈ ។ បេ ។ នូវចិត្តដែលប្រកបដោយទោសៈ ។ បេ ។ នូវចិត្តដែលប្រាសចាកទោសៈ នូវចិត្តដែលប្រកបដោយមោហៈ នូវចិត្តដែលប្រាសចាកមោហៈ នូវចិត្តដែលរួញ នូវចិត្តដែលរាយមាយ នូវចិត្តដែលដល់នូវភាវៈជាធំ (គឺរូបាវចរៈនិងអរូបាវចរៈ) នូវចិត្តដែលមិនដល់នូវភាវៈជាធំ (គឺកាមាវចរៈ) នូវចិត្តដែលមានចិត្តដទៃប្រសើរជាង (គឺកាមាវចរៈ) នូវចិត្តដែលមិនមានចិត្តដទៃប្រសើរជាង (គឺរូបាវចរៈនិងអរូបាវចរៈ) នូវចិត្តដែលតាំងមាំ នូវចិត្តដែលមិនតាំងមាំ (គឺប្រាសចាកសមាធិទាំង២)

វិមុត្តំ ចិត្តំ ។ បេ ។ អវិមុត្តំ ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតី-
តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ អវិមុត្តំ ចិត្តំ
អវិមុត្តំ ចិត្តន្តិ បជានាតិ តេន វត រេ វត្តព្វេ ចេតោបរិ-
យាយេ ញាណំ ចិត្តារម្មណេញ្ញេវ ន អញ្ញារម្មណន្តិ ។

(៦៦១) ផស្សារម្មណេ ញាណំ វត្តព្វំ ចេតោ-
បរិយាយេ ញាណន្តិ ។ អាមន្តា ។ ហញ្ចិ ផស្សារម្ម-
ណេ ញាណំ វត្តព្វំ ចេតោបរិយាយេ ញាណំ តេន វត
រេ វត្តព្វេ ចេតោបរិយាយេ ញាណំ ចិត្តារម្មណេញ្ញេវ
ន អញ្ញារម្មណន្តិ ។ វេទនារម្មណេ ញាណំ ។ បេ ។
សញ្ញារម្មណេ ញាណំ ចេតនារម្មណេ ញាណំ ចិត្តា-
រម្មណេ ញាណំ សទ្ធារម្មណេ ញាណំ វីរិយារម្ម-
ណេ ញាណំ សតារម្មណេ ញាណំ សមាធារម្មណេ
ញាណំ បញ្ញារម្មណេ ញាណំ ។ បេ ។ រាគារម្មណេ
ញាណំ ។ បេ ។ ទោសារម្មណេ ញាណំ ។ បេ ។

នូវចិត្តដែលរួចស្រឡះ ។ បេ ។ នូវចិត្តដែលមិនទាន់រួចស្រឡះ ថាចិត្ត
មិនទាន់រួចស្រឡះដូច្នេះ មានដែរឬ ។ អើ ។ បើបុគ្គលណាមួយ ដឹង
ច្បាស់នូវចិត្តដែលមិនទាន់រួចស្រឡះ ថាចិត្តមិនទាន់រួចស្រឡះដូច្នេះ មាន
ដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ ក្នុងការកំណត់ដឹង
នូវចិត្ត (នៃបុគ្គលដទៃ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃជា
អារម្មណ៍ទេ ។

(៦៦១) ញាណ ក្នុងអារម្មណ៍គឺផស្សៈ បុគ្គលគួរនិយាយថា
ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) ឬ ។ អើ ។ បើ
ញាណ ក្នុងអារម្មណ៍គឺផស្សៈ បុគ្គលគួរនិយាយថា ញាណ ក្នុងការ
កំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា
ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) មានចិត្តជាអារម្មណ៍
មិនមែនមានធម៌ដទៃជាអារម្មណ៍ទេ ។ ញាណ ក្នុងអារម្មណ៍គឺវេទនា
។ បេ ។ ញាណ ក្នុងអារម្មណ៍គឺសញ្ញា ញាណ ក្នុងអារម្មណ៍គឺចេតនា
ញាណ ក្នុងអារម្មណ៍គឺចិត្ត ញាណ ក្នុងអារម្មណ៍គឺសទ្ធៈ ញាណ
ក្នុងអារម្មណ៍គឺវីរិយៈ ញាណ ក្នុងអារម្មណ៍គឺសតិ ញាណ ក្នុង
អារម្មណ៍គឺសមាធិ ញាណ ក្នុងអារម្មណ៍គឺបញ្ញា ។ បេ ។ ញាណ
ក្នុងអារម្មណ៍គឺរាគៈ ។ បេ ។ ញាណ ក្នុងអារម្មណ៍គឺទោសៈ ។ បេ ។

អនោត្តប្បារម្មណេ ញាណំ វត្តព្វំ ចេតោបរិយាយេ ញាណន្តិ ។ អាមន្តា ។ ហញ្ចិ អនោត្តប្បារម្មណេ ញាណំ វត្តព្វំ ចេតោបរិយាយេ ញាណំ នោ វត រេ វត្តព្វេ ចេតោបរិយាយេ ញាណំ ចិត្តារម្មណញ្ញេវ ន អញ្ញារម្មណន្តិ ។

(៦៦២) ផស្សារម្មណេ ញាណំ ន វត្តព្វំ ចេតោបរិយាយេ ញាណន្តិ ។ អាមន្តា ។ ផស្សបរិយាយេ ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនារម្មណេ ញាណំ ។ បេ ។ សញ្ញារម្មណេ ញាណំ ។ បេ ។ អនោត្តប្បារម្មណេ ញាណំ ន វត្តព្វំ ចេតោបរិយាយេ ញាណន្តិ ។ អាមន្តា ។ អនោត្តប្បបរិយាយេ ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ញាណ ក្នុងអារម្មណ៍គឺអនោត្តប្បៈ បុគ្គលគួរនិយាយថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) ឬ ។ អើ ។ បើញាណ ក្នុងអារម្មណ៍គឺអនោត្តប្បៈ បុគ្គលគួរនិយាយថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេ ។

(៦៦២) ញាណ ក្នុងអារម្មណ៍គឺផស្សៈ បុគ្គលមិនគួរនិយាយថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) ទេឬ ។ អើ ។ ញាណ ក្នុងការកំណត់ដឹងនូវផស្សៈ (មាន) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ញាណ ក្នុងអារម្មណ៍គឺវេទនា ។ បេ ។ ញាណ ក្នុងអារម្មណ៍គឺសញ្ញា ។ បេ ។ ញាណ ក្នុងអារម្មណ៍គឺអនោត្តប្បៈ បុគ្គលមិនគួរនិយាយថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) ទេឬ ។ អើ ។ ញាណ ក្នុងការកំណត់ដឹងនូវអនោត្តប្បៈ (មាន) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦២៣) ន វត្តព្វំ ចេតោបរិយាយេ ញាណំ ចិត្តារម្មណន្តេវ ន អញ្ញារម្មណន្តិ ។ អាមន្តា ។ ននុ ចេតោបរិយាយេ ញាណន្តិ ។ អាមន្តា ។ ហញ្ចិ ចេតោបរិយាយេ ញាណំ តេន វត រេ វត្តព្វេ ចេតោបរិយាយេ ញាណំ ចិត្តារម្មណន្តេវ ន អញ្ញារម្មណន្តិ ។

ចិត្តារម្មណកថា ។

អនាគតញ្ញាណកថា

(៦២៤) អនាគតេ ញាណំ អត្ថីតិ ។ អាមន្តា ។ អនាគតំ មូលតោ ជានាតិ ហេតុតោ ជានាតិ និទាន‐តោ ជានាតិ សម្ភវតោ ជានាតិ បភវតោ ជានាតិ សមុដ្ឋានតោ ជានាតិ អាហារតោ ជានាតិ អារម្មណតោ ជានាតិ បច្ចយតោ ជានាតិ សមុទយតោ ជានាតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦២៥) អនាគតេ ញាណំ អត្ថីតិ ។ អាមន្តា ។

(៦២៣) បុគ្គលមិនគួរនិយាយថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេឬ ។ អើ ។ ក្រែងញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ មាន) ឬ ។ អើ ។ បើញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ មាន) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ញាណ ក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) មានចិត្តជាអារម្មណ៍ មិនមែនមានធម៌ដទៃជាអារម្មណ៍ទេ ។

ចប់ ចិត្តារម្មណកថា ។

អនាគតញ្ញាណកថា

(៦២៤) ញាណ ក្នុងអនាគត មានឬ ។ អើ ។ បុគ្គលដឹងអនាគតដោយមូល ដឹងដោយហេតុ ដឹងដោយនិទាន ដឹងដោយសម្ភវៈ (ហេតុជាដែនកើតព្រម) ដឹងដោយបភវៈ (ហេតុជាដែនកើតទូទៅ) ដឹងដោយសមុដ្ឋាន ដឹងដោយអាហារ ដឹងដោយអារម្មណ៍ ដឹងដោយបច្ច័យ ដឹង (អនាគត) ដោយសមុទយៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦២៥) ញាណ ក្នុងអនាគត មានឬ ។ អើ ។

អនាគតំ ហេតុប្បច្ចយតំ ជានាតិ អារម្មណប្បច្ចយតំ ជានាតិ អធិបតិប្បច្ចយតំ ជានាតិ អនន្តរប្បច្ចយតំ ជានាតិ សមនន្តរប្បច្ចយតំ ជានាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៤៦) អនាគតេ ញាណំ អត្ថីតិ ។ អាមន្តា ។ គោត្រភុនោ បុគ្គលស្ស សោតាបត្តិមគ្គេ ញាណំ អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស សោតាបត្តិផលេ ញាណំ អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិផលសច្ឆិកិរិយាយ ។ បេ ។ អនាគាមិផលសច្ឆិកិរិយាយ ។ បេ ។ អរហត្តសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អរហត្តេ ញាណំ អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៤៧) ន វត្តព្វំ អនាគតេ ញាណំ អត្ថីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បាដលិបុត្តស្ស ខោ អានន្ទ តយោ អន្តរាយា ភវិស្សន្តិ អគ្គិតោ វា ឧទកតោ វា មិថុភេទា វាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អនាគតេ ញាណំ អត្ថីតិ ។

អនាគតញ្ញាណកថា ។

បុគ្គល ដឹងនូវភាពនៃហេតុប្បច្ច័យ ដឹងនូវភាពនៃអារម្មណប្បច្ច័យ ដឹងនូវភាពនៃអធិបតិប្បច្ច័យ ដឹងនូវភាពនៃអនន្តរប្បច្ច័យ ដឹងនូវភាពនៃសមនន្តរប្បច្ច័យជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៤៦) ញាណ ក្នុងអនាគត មានឬ ។ អើ ។ ញាណក្នុងសោតាបត្តិមគ្គ របស់បុគ្គលជាគោត្រភូ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ញាណ ក្នុងសោតាបត្តិផល របស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ។ បេ ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។ បេ ។ ញាណ ក្នុងអរហត្ត របស់បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៤៧) បុគ្គលមិនគួរនិយាយថា ញាណ ក្នុងអនាគត មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ អន្តរាយទាំងឡាយ ៣ យ៉ាងគឺ អន្តរាយអំពីភ្លើង ១ អន្តរាយអំពីទឹក ១ អន្តរាយអំពីការបែកបាក់គ្នានៃជនពីរនាក់ ១ នៃក្រុងបាដលិបុត្ត នឹងមាន ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ញាណ ក្នុងអនាគត មាន ។

ចប់ អនាគតញ្ញាណកថា ។

បច្ចុប្បន្នញាណកថា

(៦២៨) បច្ចុប្បន្នំ ញាណំ អត្ថីតិ ។ អាមន្តា ។ តេន ញាណេន តំ ញាណំ ជានាតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ តេន ញាណេន តំ ញាណំ ជានាតីតិ ។ អាមន្តា ។ តេន ញាណេន តំ ញាណំ ញាណន្តិ ជានាតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ តេន ញាណេន តំ ញាណំ ញាណន្តិ ជានាតីតិ ។ អាមន្តា ។ តំ ញាណំ តស្ស ញាណស្ស អារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ តំ ញាណំ តស្ស ញាណស្ស អារម្មណន្តិ ។ អាមន្តា ។ តេន ផស្សេន តំ ផស្សំ ផុសតិ តាយ វេទនាយ តំ វេទនំ វេទេតិ តាយ សញ្ញាយ តំ សញ្ញំ សញ្ជានាតិ តាយ ចេតនាយ តំ ចេតនំ ចេតេតិ តេន ចិត្តេន តំ ចិត្តំ ចិន្តេតិ តេន វិតក្កេន តំ វិតក្កំ វិតក្កេតិ តេន វិចារេន តំ វិចារំ វិចារេតិ តាយ បីតិយា តំ បីតឹ បិយាយតិ តាយ សតិយា តំ សតឹ សរតិ តាយ បញ្ញាយ តំ បញ្ញំ បជានាតិ តេន ខគ្គេន តំ ខគ្គំ ឆិន្ទតិ

បច្ចុប្បន្នញាណកថា

(៦២៨) ញាណ ក្នុងបច្ចុប្បន្ន មានឬ ។ អើ ។ បុគ្គល ដឹងនូវញាណនោះ ដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ដឹងនូវញាណនោះ ដោយញាណនោះឬ ។ អើ ។ បុគ្គល ដឹងនូវញាណនោះ ដោយញាណនោះ ថាជាញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ដឹងនូវញាណនោះ ដោយញាណនោះ ថាជាញាណឬ ។ អើ ។ ញាណនោះ ជាអារម្មណ៍របស់ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណនោះ ជាអារម្មណ៍របស់ញាណនោះឬ ។ អើ ។ បុគ្គល ពាល់ត្រូវនូវផស្សៈនោះ ដោយផស្សៈនោះ ទទួលនូវវេទនានោះ ដោយវេទនានោះ សំគាល់នូវសញ្ញានោះ ដោយសញ្ញានោះ ត្រិះរិះនូវចេតនានោះ ដោយចេតនានោះ គិតនូវចិត្តនោះ ដោយចិត្តនោះ ត្រិះរិះនូវវិតក្កៈនោះ ដោយវិតក្កៈនោះ ពិចារណានូវវិចារៈនោះ ដោយវិចារៈនោះ រីករាយនូវបីតិនោះ ដោយបីតិនោះ រលឹកនូវសតិនោះ ដោយសតិនោះ ដឹងច្បាស់នូវបញ្ញានោះ ដោយបញ្ញានោះ កាត់នូវព្រះខ័ននោះ ដោយព្រះខ័ននោះ

តេន ផរសុនា តំ ផរសុំ តច្ឆតិ តាយ កុឋារិយា តំ កុឋារឹ តច្ឆតិ តាយ វាសិយា តំ វាសឹ តច្ឆតិ តាយ សូចិយា តំ សូចឹ សិព្វេតិ តេន អង្គុលគ្គេន តំ អង្គុលគ្គំ បរាមសតិ តេន នាសិកគ្គេន តំ នាសិ-កគ្គំ បរាមសតិ តេន មត្ថកេន តំ មត្ថកំ បរាមសតិ តេន គូថេន តំ គូថំ ធោវតិ តេន មុត្តេន តំ មុត្តំ ធោវតិ តេន ខេឡេន តំ ខេឡំ ធោវតិ តេន បុព្វេន តំ បុព្វំ ធោវតិ តេន លោហិតេន តំ លោហិតំ ធោវតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៤៩) ន វត្តព្វំ បច្ចុប្បន្នំ ញាណំ អត្ថីតិ ។ អាមន្តា ។ ននុ សព្វសង្ខារេ អនិច្ចតោ ទិដ្ឋេ តម្បិ ញាណំ អនិច្ចតោ ទិដ្ឋំ ហោតីតិ ។ អាមន្តា ។ ហញ្ចិ សព្វសង្ខារេ អនិច្ចតោ ទិដ្ឋេ តម្បិ ញាណំ អនិច្ចតោ ទិដ្ឋំ ហោតិ តេន វត រេ វត្តព្វេ បច្ចុប្បន្នំ ញាណំ អត្ថីតិ ។

បច្ចុប្បន្នញ្ញាណកថា ។

ប្រាសនូវប៉ូថៅនោះ ដោយប៉ូថៅនោះ ចាំងនូវដឹងនោះ ដោយដឹងនោះ កាប់នូវកាំបិតនោះ ដោយកាំបិតនោះ ដេរនូវម្ជុលនោះ ដោយម្ជុលនោះ ស្ទាបអង្អែលនូវចុងម្រាមនោះ ដោយចុងម្រាមនោះ ស្ទាបអង្អែលនូវចុងច្រមុះនោះ ដោយចុងច្រមុះនោះ ស្ទាបអង្អែលនូវក្បាលនោះ ដោយក្បាលនោះ លាងនូវលាមកនោះ ដោយលាមកនោះ លាងនូវមូត្រនោះ ដោយមូត្រនោះ លាងនូវទឹកមាត់នោះ ដោយទឹកមាត់នោះ លាងនូវខ្ទុះនោះ ដោយខ្ទុះនោះ លាងនូវឈាមនោះ ដោយឈាមនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៤៩) បុគ្គលមិនគួរនិយាយថា ញាណ ក្នុងបច្ចុប្បន្ន មានទេឬ ។ អើ ។ កាលបុគ្គលឃើញនូវសង្ខារទាំងពួង ដោយសភាពជារបស់មិនទៀង ក្រែងឃើញនូវញាណនោះ ដោយសភាពជារបស់មិនទៀងដែរឬ ។ អើ ។ បើកាលបុគ្គលឃើញនូវសង្ខារទាំងពួង ដោយសភាពជារបស់មិនទៀង ឃើញនូវញាណនោះ ដោយសភាពជារបស់មិនទៀង ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ញាណក្នុងបច្ចុប្បន្ន មាន ។

ចប់ បច្ចុប្បន្នញ្ញាណកថា ។

ផលញាណកថា

[៦៣០] សាវកស្ស ផលេ ញាណំ អត្ថីតិ ។ អាមន្តា ។ សាវកោ ផលស្សកតំ បញ្ញាបេតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ សាវកស្ស ផលេ ញាណំ អត្ថីតិ ។ អាមន្តា ។ អត្ថិ សាវកស្ស ផលបរោបរិយត្តំ ឥន្ទ្រិយបរោបរិយត្តំ បុគ្គលបរោបរិយត្តន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ សាវកស្ស ផលេ ញាណំ អត្ថីតិ ។ អាមន្តា ។ អត្ថិ សាវកស្ស ខន្ធបញ្ញត្តិ អាយតនបញ្ញត្តិ ធាតុបញ្ញត្តិ សច្ចបញ្ញត្តិ ឥន្ទ្រិយបញ្ញត្តិ បុគ្គលបញ្ញត្តីតិ ។ ន ហេវំ វត្តព្វេ ។បេ។ សាវកស្ស ផលេ ញាណំ អត្ថីតិ ។ អាមន្តា ។ សាវកោ ជិនោ សត្ថា សម្មាសម្ពុទ្ធោ សព្ពញ្ញូ សព្ពទស្សាវី ធម្មស្សាមី ធម្មប្បដិសរណោតិ ។ ន ហេវំ វត្តព្វេ ។បេ។ សាវកស្ស ផលេ ញាណំ អត្ថីតិ ។ អាមន្តា ។ សាវកោ អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោតិ ។ ន ហេវំ វត្តព្វេ ។បេ។

ផលញាណកថា

[៦៣០] ញាណ ក្នុងផល របស់សាវ័ក មានឬ ។ អើ ។ សាវ័ក បញ្ញត្តនូវផលជារបស់ខ្លួនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ ក្នុងផល របស់សាវ័ក មានឬ ។ អើ ។ ការកំណត់ដឹងនូវផលដ៏ក្លានិងទន់ ការកំណត់ដឹងនូវឥន្ទ្រិយដ៏ក្លានិងទន់ ការកំណត់ដឹងនូវបុគ្គលដ៏ក្លានិងទន់ របស់សាវ័ក មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ ក្នុងផល របស់សាវ័ក មានឬ ។ អើ ។ ការបញ្ញត្តនូវខន្ធ ការបញ្ញត្តនូវអាយតនៈ ការបញ្ញត្តនូវធាតុ ការបញ្ញត្តនូវសច្ចៈ ការបញ្ញត្តនូវឥន្ទ្រិយ ការបញ្ញត្តនូវបុគ្គល របស់សាវ័ក មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ ក្នុងផល របស់សាវ័ក មានឬ ។ អើ ។ សាវ័ក ជាអ្នកឈ្នះមារ ជាគ្រូ ជាអ្នកត្រាស់ដឹងឯង ដឹងសព្វ ឃើញសព្វ ជាម្ចាស់នៃធម៌ ជាអ្នកមានធម៌ជាទីពឹងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ញាណ ក្នុងផល របស់សាវ័ក មានឬ ។ អើ ។ សាវ័ក ញុំាងមគ្គដែលមិនទាន់កើតឡើងឲ្យកើតឡើង ញុំាងមគ្គដែលមិនទាន់កើតព្រម ឲ្យកើតព្រម និយាយបំភោះមគ្គដែលគេមិនទាន់និយាយ ដឹងនូវមគ្គ ជ្រាបច្បាស់នូវមគ្គ ឈ្លាសវៃក្នុងមគ្គ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

តស្ស ឧទ្ទានំ

(៦៣១) ន វត្តព្វំ សាវកស្ស ផលេ ញាណំ អត្ថីតិ ។ អាមន្តា ។ សាវកោ អញ្ញាណីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ សាវកស្ស ផលេ ញាណំ អត្ថីតិ ។

ផលញ្ញាណកថា ។

បញ្ចមោ វគ្គោ ។

តស្ស ឧទ្ទានំ

វិមុត្តិញាណំ វិមុត្តំ សេក្ខស្ស អសេក្ខំ ញាណំ វិបរីតេ ញាណំ អដ្ឋមកស្ស និយាមគមនាយ អត្ថិ ញាណំ សព្វំ ញាណំ បដិសម្ភិទាតិ សម្មុតិញាណំ ចេតោបរិយាយេ ញាណំ អនាគតេ ញាណំ បច្ចុប្បន្នេ ញាណំ សាវកស្ស ផលេ ញាណន្តិ ។

មហាបណ្ណាសកោ ។

សត្តុបលទ្ធិ ឧបហារោ ពលំ គិហិស្ស អរហា ច វិមុត្តិបញ្ចមំ ។

ឧទ្ទាននៃបញ្ចមវគ្គ

(៦៣១) បុគ្គលមិនគួរនិយាយថា ញាណក្នុងផល របស់សាវក មានឬ ។ អើ ។ សាវក មិនមានញាណទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ញាណក្នុងផល របស់សាវក មាន ។

ចប់ ផលញ្ញាណកថា ។

ចប់ បញ្ចមវគ្គ ។

ឧទ្ទាននៃបញ្ចមវគ្គនោះគឺ

និយាយអំពីវិមុត្តិញាណ ឈ្មោះថាវិមុត្ត ១ អសេក្ខញ្ញាណ របស់សេក្ខបុគ្គល ១ វិបរីតញ្ញាណ ១ ញាណក្នុងដំណើរទៅកាន់និយាមៈ របស់បុគ្គលជាអដ្ឋមកៈ មាន ១ ញាណទាំងពួង ឈ្មោះជាបដិសម្ភិទា ១ សម្មុតិញ្ញាណ ១ ញាណក្នុងការកំណត់ដឹងនូវចិត្ត (នៃបុគ្គលដទៃ) ១ ញាណក្នុងអនាគត ១ ញាណក្នុងបច្ចុប្បន្ន ១ ញាណក្នុងផល របស់សាវក ១ ។

ចប់ មហាបណ្ណាសកៈ ។

វគ្គនិយាយពីបុគ្គលបានឈ្មោះថាសត្វជាដើម ១ វគ្គនិយាយពីទេវតាជាពួកនៃមារនាំយករបស់ដែលមិនស្អាតឡើងដល់ព្រះអរហន្ត ១ វគ្គនិយាយពីកម្លាំងនៃព្រះតថាគតជាដើម ១ វគ្គនិយាយពីគ្រហស្ថបានសម្រេចជាព្រះអរហន្ត ១ និងវគ្គនិយាយពីវិមុត្តិ ១ ទៀតជាគម្រប់ ៥ ។

និយាមកថា

(៦៣២) និយាមោ អសង្ខតោតិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយនំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៣៣) និយាមោ អសង្ខតោ និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ទ្វេ លេណានិ ទ្វេ សរណានិ ទ្វេ បរាយនានិ ទ្វេ អច្ចុតានិ ទ្វេ អមតានិ ទ្វេ និព្វានានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ និព្វានានីតិ ។ អាមន្តា ។ អត្ថិ ទ្វិន្នំ និព្វានានំ ឧច្ចនីចតា ហីនប្បណីតតា ឧក្កំសាវកំសោ សីមា វា ភេទោ វា រាជិ វា អន្តរិកា វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៣៤) និយាមោ អសង្ខតោតិ ។ អាមន្តា ។ អត្ថិ កេចិ និយាមំ ឱក្កមន្តិ បដិលភន្តិ ឧប្បាទេន្តិ សមុប្បាទេន្តិ ឧដ្ឋាបេន្តិ សមុដ្ឋាបេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ ជនេន្តិ សញ្ជនេន្តីតិ ។ អាមន្តា ។

និយាមកថា

(៦៣២) និយាមៈ (អរិយមគ្គ) ជាអសង្ខតៈឬ ។ អើ ។ ព្រះនិព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៣៣) និយាមៈ ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ទីជ្រកកោន មានពីរ ទីការពារ មានពីរ ទីប្រព្រឹត្តទៅក្នុងខាងមុខ មានពីរ ទីមិនច្យុត មានពីរ ទីមិនស្លាប់ មានពីរ និព្វាន មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និព្វាន មានពីរឬ ។ អើ ។ ភាពខ្ពស់និងទាប ភាពថោកទាបនិងឧត្តម ឧក្រិដ្ឋនិងថោកទាប ដែនក្តី ការបែកធ្លាយក្តី ការប្រេះធាក្តី ការវិនាសទៅក្តី នៃនិព្វានទាំងពីរ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៣៤) និយាមៈ ជាអសង្ខតៈឬ ។ អើ ។ បុគ្គលពួកខ្លះ ឈានចុះកាន់និយាមៈ បានចំពោះនូវនិយាមៈ ញ៉ាំងនិយាមៈ ឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យផុះឡើង ឲ្យផុះផាលឡើង មានដែរឬ ។ អើ ។

អត្ថិ កេចិ អសង្ខតំ និក្ខមន្តិ បដិលភន្តិ ឧប្បាទេន្តិ សមុប្បាទេន្តិ ឧដ្ឋាបេន្តិ សមុដ្ឋាបេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ ជនេន្តិ សញ្ជនេន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ ។

[៦៣៨] និយាមោ អសង្ខតោតិ ។ អាមន្តា ។ មគ្គោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។ មគ្គោ សង្ខតោតិ ។ អាមន្តា ។ និយាមោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។ សោតាបត្តិនិយាមោ អសង្ខតោតិ ។ អាមន្តា ។ សោតាបត្តិមគ្គោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។ សោតាបត្តិមគ្គោ សង្ខតោតិ ។ អាមន្តា ។ សោតាបត្តិនិយាមោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។ សកទាគាមិនិយាមោ ។បេ ។ អនាគាមិនិយាមោ ។បេ ។ អរហត្តនិយាមោ អសង្ខតោតិ ។ អាមន្តា ។ អរហត្តមគ្គោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។ អរហត្តមគ្គោ សង្ខតោតិ ។ អាមន្តា ។ អរហត្តនិយាមោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

បុគ្គលពួកខ្លះ ឈានចុះកាន់អសង្ខតៈ បានចំពោះទៅអសង្ខតៈ ញុំាងអសង្ខតៈ ឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យផុះឡើង ឲ្យផុះផាលឡើង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។

[៦៣៨] និយាមៈ ជាអសង្ខតៈឬ ។ អើ ។ មគ្គ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ មគ្គ ជាសង្ខតៈឬ ។ អើ ។ និយាមៈ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ សោតាបត្តិនិយាមៈ ជាអសង្ខតៈឬ ។ អើ ។ សោតាបត្តិមគ្គ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ សោតាបត្តិមគ្គ ជាសង្ខតៈឬ ។ អើ ។ សោតាបត្តិនិយាមៈ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ សកទាគាមិនិយាមៈ ។បេ ។ អនាគាមិនិយាមៈ ។បេ ។ អរហត្តនិយាមៈ ជាអសង្ខតៈឬ ។ អើ ។ អរហត្តមគ្គ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ អរហត្តមគ្គ ជាសង្ខតៈឬ ។ អើ ។ អរហត្តនិយាមៈ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។

(៦៣៦) សោតាបត្តិនិយាមោ អសង្ខតោ ។ បេ ។ អរហត្តនិយាមោ អសង្ខតោ និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ បញ្ច អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បញ្ច អសង្ខតានីតិ ។ អាមន្តា ។ បញ្ច តាណានិ ។ បេ ។ អន្តរិកា ភតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៣៧) និយាមោ អសង្ខតោតិ ។ អាមន្តា ។ មិច្ឆត្តនិយាមោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មិច្ឆត្តនិយាមោ សង្ខតោតិ ។ អាមន្តា ។ សម្មត្តនិយាមោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៣៨) ន វត្តព្វំ និយាមោ អសង្ខតោតិ ។ អាមន្តា ។ និយាមេ ឧប្បន្នេ និរុទ្ធេ អនិយតោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ និយាមោ អសង្ខតោតិ ។ មិច្ឆត្តនិយាមេ ឧប្បន្នេ និរុទ្ធេ អនិយតោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ មិច្ឆត្តនិយាមោ អសង្ខតោតិ ។

និយាមកថា ។

(៦៣៦) សោតាបត្តិនិយាម ជាអសង្ខតៈ ។ បេ ។ អរហត្តនិយាម ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មាន ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មាន ៥ ឬ ។ អើ ។ ទីពឹង មាន ៥ ។ បេ ។ ការវិនាសទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៣៧) និយាមៈ ជាអសង្ខតៈឬ ។ អើ ។ មិច្ឆត្តនិយាម ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មិច្ឆត្តនិយាម ជាសង្ខតៈឬ ។ អើ ។ សម្មត្តនិយាម ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៣៨) បុគ្គលមិនគួរនិយាយថា និយាមៈ ជាអសង្ខតៈទេ ឬ ។ អើ ។ កាលនិយាមៈ កើតឡើងហើយរលត់ទៅវិញ ឈ្មោះថាមិនទៀងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ និយាមៈ ជាអសង្ខតៈ ។ កាលមិច្ឆត្តនិយាម កើតឡើងហើយរលត់ទៅវិញ ឈ្មោះថាមិនទៀងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ មិច្ឆត្តនិយាម ជាអសង្ខតៈវៃ ។

ចប់ និយាមកថា ។

។ បេ ។ សញ្ញា ចេតនា រាគោ ទោសោ មោហោ មានោ ទិដ្ឋិ វិចិកិច្ឆា ថីនំ ឧទ្ធច្ចំ អហិរិកំ ។ បេ ។ អនោត្តប្បំ អកុសលំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ អកុសលេន ចិត្តេន សមុដ្ឋិតំ វចីកម្មំ រូបំ អកុសលំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨១៩) អកុសលេន ចិត្តេន សមុដ្ឋិតំ វចីកម្មំ រូបំ អកុសលំ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ អកុសលេន ចិត្តេន សមុដ្ឋិតោ ផស្សោ អកុសលោ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អកុសលេន ចិត្តេន សមុដ្ឋិតំ វចីកម្មំ រូបំ អកុសលំ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ អកុសលេន ចិត្តេន សមុដ្ឋិតា វេទនា ។ បេ ។ សញ្ញា ចេតនា រាគោ ទោសោ មោហោ មានោ ទិដ្ឋិ វិចិកិច្ឆា ថីនំ ឧទ្ធច្ចំ អហិរិកំ ។ បេ ។ អនោត្តប្បំ អកុសលំ

។ បេ ។ សញ្ញា ចេតនា រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ ។ បេ ។ អនោត្តប្បៈ តាំងឡើងដោយអកុសលចិត្ត ជាអកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងទុក ចំពោះអនោត្តប្បៈនោះ មានឬ ។ អើ ។ រូប ជាវចីកម្ម តាំងឡើង ដោយអកុសលចិត្ត ជាអកុសល ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងទុក ចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨១៩) រូប ជាវចីកម្ម តាំងឡើង ដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ផស្សៈ តាំងឡើង ដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងទុក ចំពោះផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប ជាវចីកម្ម តាំងឡើង ដោយអកុសលចិត្ត ជាអកុសល មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ វេទនា ។ បេ ។ សញ្ញា ចេតនា រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ ។ បេ ។ អនោត្តប្បៈ តាំងឡើង ដោយអកុសលចិត្ត ជាអកុសល

ន ហេវំ វត្តព្វេ ។ បេ ។ អវិជ្ជាបច្ចយា សង្ខារា សង្ខតា-
តិ ។ អាមន្តា ។ បដិច្ចសមុប្បាទោ សង្ខតោតិ ។ ន
ហេវំ វត្តព្វេ ។ បេ ។ បដិច្ចសមុប្បាទោ អសង្ខតោតិ ។
អាមន្តា ។ សង្ខារប្បច្ចយា វិញ្ញាណំ អសង្ខតន្តិ ។
ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារប្បច្ចយា វិញ្ញាណំ
សង្ខតន្តិ ។ អាមន្តា ។ បដិច្ចសមុប្បាទោ សង្ខតោតិ ។
ន ហេវំ វត្តព្វេ ។ បេ ។ បដិច្ចសមុប្បាទោ អសង្ខតោ-
តិ ។ អាមន្តា ។ វិញ្ញាណប្បច្ចយា នាមរូបំ អសង្ខតន្តិ ។
ន ហេវំ វត្តព្វេ ។ បេ ។ វិញ្ញាណប្បច្ចយា នាមរូបំ
សង្ខតន្តិ ។ អាមន្តា ។ បដិច្ចសមុប្បាទោ សង្ខតោ
តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បដិច្ចសមុប្បាទោ
អសង្ខតោតិ ។ អាមន្តា ។ ជាតិប្បច្ចយា ជរាមរណំ
អសង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ជាតិប្បច្ចយា
ជរាមរណំ សង្ខតន្តិ ។ អាមន្តា ។ បដិច្ចសមុប្បាទោ
សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៤១) ន វត្តព្វំ បដិច្ចសមុប្បាទោ អសង្ខ-
តោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារទាំងឡាយ (កើតមាន)
ព្រោះអវិជ្ជាជាបច្ច័យ ជាសង្ខតៈឬ ។ អើ ។ បដិច្ចសមុប្បាទ ជា
សង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បដិច្ចសមុប្បាទ
ជាអសង្ខតៈឬ ។ អើ ។ វិញ្ញាណ (កើតមាន) ព្រោះសង្ខារ
ជាបច្ច័យ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
វិញ្ញាណ (កើតមាន) ព្រោះសង្ខារជាបច្ច័យ ជាសង្ខតៈឬ ។ អើ ។
បដិច្ចសមុប្បាទ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
បដិច្ចសមុប្បាទ ជាអសង្ខតៈឬ ។ អើ ។ នាមរូប (កើតមាន) ព្រោះ
វិញ្ញាណជាបច្ច័យ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
នាមរូប (កើតមាន) ព្រោះវិញ្ញាណជាបច្ច័យ ជាសង្ខតៈឬ ។ អើ ។
បដិច្ចសមុប្បាទ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
បដិច្ចសមុប្បាទ ជាអសង្ខតៈឬ ។ អើ ។ ជរានិងមរណៈ (កើត
មាន) ព្រោះជាតិជាបច្ច័យ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះ
ទេ ។ បេ ។ ជរានិងមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ជា
សង្ខតៈឬ ។ អើ ។ បដិច្ចសមុប្បាទ ជាសង្ខតៈឬ ។ អ្នកមិន
គួរពោលយ៉ាងនេះទេ ។ បេ ។

(៦៤១) បុគ្គល មិនគួរនិយាយថា បដិច្ចសមុប្បាទ ជា
អសង្ខតៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ជាតិប្បច្ចយា ភិក្ខវេ ជរាមរណំ ឧប្បាទា វា តថាគតានំ អនុប្បាទា វា តថាគតានំ ឋិតា វ សា ធាតុ ធម្មដ្ឋិតតា ធម្មនិយាមតា ឥទប្បច្ចយតា តំ តថាគតោ អភិសម្ពុជ្ឈតិ អភិសមេតិ អភិសម្ពុជ្ឈិត្វា អភិសមេត្វា អាចិក្ខតិ ទេសេតិ បញ្ញបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានីករោតិ បស្សថាតិ ចាហ ជាតិប្បច្ចយា ភិក្ខវេ ជរាមរណំ ភវប្បច្ចយា ភិក្ខវេ ជាតិ ។បេ។ អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា ឧប្បាទា វា តថាគតានំ អនុប្បាទា វា តថាគតានំ ឋិតា វ សា ធាតុ ។បេ។ បស្សថាតិ ចាហ អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា ឥតិ ខោ ភិក្ខវេ យា តត្រ តថតា អវិតថតា អនញ្ញថតា ឥទប្បច្ចយតា អយំ វុច្ចតិ ភិក្ខវេ បដិច្ចសមុប្បាទោតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បដិច្ចសមុប្បាទោ អសង្ខតោតិ ។

ម្នាលភិក្ខុទាំងឡាយ ជរានិងមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ការកើតឡើងនៃតថាគតទាំងឡាយក្តី ការមិនកើតឡើងនៃតថាគតទាំងឡាយក្តី ក៏ធាតុនោះ ភាពនៃការឋិតនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ ភាពនៃឥទប្បច្ច័យ នោះ រមែងតាំងនៅជាធម្មតា តថាគត ត្រាស់ដឹងច្បាស់ យល់ច្បាស់ នូវហេតុមានធាតុជាដើមនោះ លុះត្រាស់ដឹងច្បាស់ យល់ច្បាស់ហើយ ទើបប្រាប់ សំដែង បញ្ញត្ត តែងតាំង បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសថា អ្នកទាំងឡាយ ចូរមើលចុះ ម្នាលភិក្ខុទាំងឡាយ ជរានិងមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ម្នាលភិក្ខុទាំងឡាយ ជាតិ (កើតមាន) ព្រោះភពជាបច្ច័យ ។បេ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ការកើតឡើងនៃតថាគតទាំងឡាយក្តី ការមិនកើតឡើងនៃតថាគតទាំងឡាយក្តី ក៏ធាតុនោះ រមែងតាំងនៅជាធម្មតា ។បេ។ ប្រកាសថា អ្នកទាំងឡាយ ចូរមើលចុះ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួល ភាពនៃឥទប្បច្ច័យ ណា ក្នុងធម៌ទាំងនោះថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិច្ចសមុប្បាទ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បដិច្ចសមុប្បាទ ជាអសង្ខតៈ ។

(៦៤២) អវិជ្ជាបច្ចយា សង្ខារាតិ យា តត្ថ ធម្មដ្ឋិតតា ធម្មនិយាមតា អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។បេ។ អន្តរិកា វាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៤៣) អវិជ្ជាបច្ចយា សង្ខារាតិ យា តត្ថ ធម្មដ្ឋិតតា ធម្មនិយាមតា អសង្ខតា សង្ខារបច្ចយា វិញ្ញាណន្តិ យា តត្ថ ធម្មដ្ឋិតតា ធម្មនិយាមតា អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ តីណិ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។បេ។ តីណិ អសង្ខតានីតិ ។ អាមន្តា ។ តីណិ តាណានិ ។បេ។ អន្តរិកា វាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៤២) បណ្ដាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ ណា ជា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈមានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។បេ។ ការវិនាសទៅក្ដីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៤៣) បណ្ដាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ ណា ជា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ជាអសង្ខតៈ បណ្ដាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ ណា ជា វិញ្ញាណ (កើតមាន) ព្រោះសង្ខារជាបច្ច័យ ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈមានបីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មានបីឬ ។ អើ ។ ទីពឹង មានបី ។បេ។ ការវិនាសទៅក្ដីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៤៤) អវិជ្ជាបច្ចយា សង្ខារាតិ យា តត្ថ ធម្មដ្ឋិតតា ធម្មនិយាមតា អសង្ខតា សង្ខារបច្ចយា វិញ្ញាណន្តិ យា តត្ថ ធម្មដ្ឋិតតា ធម្មនិយាមតា អសង្ខតា ។បេ។ ជាតិបច្ចយា ជរាមរណន្តិ យា តត្ថ ធម្មដ្ឋិតតា ធម្មនិយាមតា អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វាទស អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទ្វាទស អសង្ខតានីតិ ។ អាមន្តា ។ ទ្វាទស តាណានិ ទ្វាទស លេណានិ ។បេ។ អន្តរិកា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។បេ។

បដិច្ចសមុប្បាទកថា ។

សច្ចកថា

(៦៤៥) ចត្តារិ សច្ចានិ អសង្ខតានីតិ ។ អាមន្តា ។ ចត្តារិ តាណានិ ចត្តារិ លេណានិ ចត្តារិ សរណានិ ចត្តារិ បរាយណានិ ចត្តារិ អច្ចុតានិ ចត្តារិ អមតានិ ចត្តារិ និព្វានានីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ចត្តារិ និព្វានានីតិ ។ អាមន្តា ។ អត្ថិ ចតុន្នំ និព្វានានំ ឧច្ចនីចតា ហីនប្បណីតតា ឧក្កំសាវកំសោ សីមា វា ភេទោ វា រាជិ វា

(៦៤៤) បណ្តាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ ណា ជា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ជាអសង្ខតៈ បណ្តាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ ណា ជា វិញ្ញាណ (កើតមាន) ព្រោះសង្ខារជាបច្ច័យ ជាអសង្ខតៈ ។បេ។ បណ្តាធម៌ទាំងនោះ ភាពនៃការតាំងនៅនៃធម៌ ភាពនៃការកំណត់នូវធម៌ ណា ជា ជរានិងមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មាន ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ១២ ឬ ។ អើ ។ ទីពឹង មាន ១២ ទីជ្រកកោន មាន ១២ ។បេ។ ការវិនាសទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ បដិច្ចសមុប្បាទកថា ។

សច្ចកថា

(៦៤៥) សច្ចៈ ៤ ជាអសង្ខតៈឬ ។ អើ ។ ទីពឹង ៤ ទីជ្រកកោន ៤ ទីការពារ ៤ ទីប្រព្រឹត្តទៅខាងមុខ ៤ ទីមិនច្យុត ៤ ទីមិនស្លាប់ ៤ និព្វាន ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និព្វាន មាន ៤ ឬ ។ អើ ។ ភាពខ្ពស់និងទាប ភាពថោកទាបនិងឧត្តម ឧក្រិដ្ឋនិងថោកទាប ដែនក្តី ការបែកធ្លាយក្តី ការប្រេះឆាក្តី

អន្តរិកា គតិ ។ ន ហេវំ វត្តព្វេ ។បេ ។

(៦៨៦) ទុក្ខសច្ចំ អសង្ខតន្តិ ។ អាមន្តា ។ ទុក្ខំ អសង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។បេ ។ ទុក្ខសច្ចំ អសង្ខតន្តិ ។ អាមន្តា ។ កាយិកំ ទុក្ខំ ចេតសិកំ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសា អសង្ខតាតិ ។ ន ហេវំ វត្តព្វេ ។បេ ។ សមុទយសច្ចំ អសង្ខតន្តិ ។ អាមន្តា ។ សមុទយោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។ សមុទយសច្ចំ អសង្ខតន្តិ ។ អាមន្តា ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា អសង្ខតាតិ ។ ន ហេវំ វត្តព្វេ ។បេ ។ មគ្គសច្ចំ អសង្ខតន្តិ ។ អាមន្តា ។ មគ្គោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។ មគ្គសច្ចំ អសង្ខតន្តិ ។ អាមន្តា ។ សម្មាទិដ្ឋិ ។បេ ។ សម្មាសមាធិ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

(៦៨៧) ទុក្ខំ សង្ខតន្តិ ។ អាមន្តា ។ ទុក្ខសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។បេ ។ កាយិកំ ទុក្ខំ ចេតសិកំ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សង្ខតាតិ ។ អាមន្តា ។

ការចន្លោះទៅក្តី នៃគតិទាំង ៥ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។

(៦៨៦) ទុក្ខសច្ច ជាអសង្ខតៈឬ ។ អើ ។ ទុក្ខ ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ ទុក្ខសច្ច ជាអសង្ខតៈឬ ។ អើ ។ ទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ សមុទយសច្ច ជាអសង្ខតៈឬ ។ អើ ។ សមុទយៈ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ សមុទយសច្ច ជាអសង្ខតៈឬ ។ អើ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ មគ្គសច្ច ជាអសង្ខតៈឬ ។ អើ ។ មគ្គ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ មគ្គសច្ច ជាអសង្ខតៈឬ ។ អើ ។ សម្មាទិដ្ឋិ ។បេ ។ សម្មាសមាធិ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។

(៦៨៧) ទុក្ខ ជាសង្ខតៈឬ ។ អើ ។ ទុក្ខសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ ទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត ជាសង្ខតៈឬ ។ អើ ។

ទុក្ខសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយោ សង្ខតោតិ ។ អាមន្តា ។ សមុទយសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា សង្ខតាតិ ។ អាមន្តា ។ សមុទយសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មគ្គោ សង្ខ-តោតិ ។ អាមន្តា ។ មគ្គសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ សង្ខតោតិ ។ អាមន្តា ។ មគ្គសច្ចំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៤៨] និរោធសច្ចំ អសង្ខតំ និរោធោ អសង្ខ-តោតិ ។ អាមន្តា ។ ទុក្ខសច្ចំ អសង្ខតំ ទុក្ខំ អសង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធសច្ចំ អសង្ខតំ និរោធោ អសង្ខតោតិ ។ អាមន្តា ។ សមុ-ទយសច្ចំ អសង្ខតំ សមុទយោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរោធសច្ចំ អសង្ខតំ និរោធោ អសង្ខតោតិ ។ អាមន្តា ។ មគ្គសច្ចំ អសង្ខតំ មគ្គោ អសង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ទុក្ខសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សមុទយៈ ជាសង្ខតៈឬ ។ អើ ។ សមុទយសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ជាសង្ខតៈឬ ។ អើ ។ សមុទយសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គ ជាសង្ខតៈឬ ។ អើ ។ មគ្គសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មា-សមាធិ ជាសង្ខតៈឬ ។ អើ ។ មគ្គសច្ច ជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៤៨] និរោធសច្ច ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ ទុក្ខសច្ច ជាអសង្ខតៈ ទុក្ខ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ សមុទយសច្ច ជាអសង្ខតៈ សមុទយៈ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាអសង្ខតៈដែរឬ ។ អើ ។ មគ្គសច្ច ជាអសង្ខតៈ មគ្គ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៤៩] ទុក្ខសច្ចំ អសង្ខតំ ទុក្ខំ សង្ខតន្តិ ។ អាមន្តា ។ និរោធសច្ចំ អសង្ខតំ និរោធោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយសច្ចំ អសង្ខតំ សមុទយោ សង្ខតោតិ ។ អាមន្តា ។ និរោធសច្ចំ អសង្ខតំ និរោធោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មគ្គសច្ចំ អសង្ខតំ មគ្គោ សង្ខតោតិ ។ អាមន្តា ។ និរោធសច្ចំ អសង្ខតំ និរោធោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៥០] ន វត្តព្វំ ចត្តារិ សច្ចានិ អសង្ខតានីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ចត្តារិមានិ ភិក្ខវេ តថានិ អវិតថានិ អនញ្ញថានិ ។ កតមានិ ចត្តារិ ។ ឥទំ ទុក្ខន្តិ ភិក្ខវេ តថមេតំ អវិតថមេតំ អនញ្ញថមេតំ ។ បេ ។ អយំ ទុក្ខសមុទយោតិ ។ បេ ។ អយំ ទុក្ខនិរោធោតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ ឥមានិ ខោ ភិក្ខវេ ចត្តារិ តថានិ អវិតថានិ អនញ្ញថានីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ចត្តារិ សច្ចានិ អសង្ខតានីតិ ។

សច្ចកថា ។

[៦៤៩] ទុក្ខសច្ច ជាអសង្ខតៈ ទុក្ខ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សមុទយសច្ច ជាអសង្ខតៈ សមុទយៈ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គសច្ច ជាអសង្ខតៈ មគ្គ ជាសង្ខតៈដែរឬ ។ អើ ។ និរោធសច្ច ជាអសង្ខតៈ និរោធ ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៥០] បុគ្គលមិនគួរនិយាយថា សច្ចៈទាំង ៤ ជាអសង្ខតៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួល នោះ មាន ៤ យ៉ាង ។ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួលថា នេះ ជាទុក្ខ ១ ។ បេ ។ ថា នេះ ជាទុក្ខសមុទយៈ ១ ។ បេ ។ ថា នេះ ជាទុក្ខនិរោធ ១ ។ បេ ។ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួលថា នេះ ជាទុក្ខនិរោធគាមិនីបដិបទា ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត សេចក្តីមិនប្រែប្រួល មាន ៤ យ៉ាង នេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សច្ចៈទាំង ៤ ជាអសង្ខតៈ ។

ចប់ សច្ចកថា ។

អារុប្បកថា

[៦៨១] អាកាសានញ្ចាយតនំ អសង្ខតន្តិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយណំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អាកាសានញ្ចាយតនំ អសង្ខតំ និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា ភតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អាកាសានញ្ចាយតនំ អសង្ខតន្តិ ។ អាមន្តា ។ អាកាសានញ្ចាយតនំ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អសង្ខតំ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អាកាសានញ្ចាយតនូបគំ កម្មន្តិ ។ អាមន្តា ។ អត្ថិ អសង្ខតូបគំ កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អាកាសានញ្ចាយតនូបគា សត្តាតិ ។ អាមន្តា ។ អត្ថិ អសង្ខតូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អារុប្បកថា

[៦៨១] អាកាសានញ្ចាយតនៈ ជាអសង្ខតឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អាកាសានញ្ចាយតនៈ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។ បេ ។ ការវែកាសទៅក្ដីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អាកាសានញ្ចាយតនៈ ជាអសង្ខតៈឬ ។ អើ ។ អាកាសានញ្ចាយតនៈ គឺជាភព ជាគតិ ជាសត្តាវាសៈ ជាសំសារ ជាកំណើត ជាវិញ្ញាណដ្ឋិតិ ជាការបានចំពោះនូវអត្តភាពឬ ។ អើ ។ អសង្ខតៈ គឺជាភព ជាគតិ ជាសត្តាវាសៈ ជាសំសារ ជាកំណើត ជាវិញ្ញាណដ្ឋិតិ ជាការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម ដែលចូលទៅកាន់អាកាសានញ្ចាយតនៈ មានឬ ។ អើ ។ កម្ម ដែលចូលទៅកាន់អសង្ខតៈ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វដែលចូលទៅកាន់អាកាសានញ្ចាយតនៈ មានឬ ។ អើ ។ ពួកសត្វដែលចូលទៅកាន់អសង្ខតៈ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៨២) អាកាសានញ្ចាយតនេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ អាមន្តា ។ អសង្ខតេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៨៣) អាកាសានញ្ចាយតនេ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ អាមន្តា ។ អសង្ខតេ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អាកាសានញ្ចាយតនំ ចតុវោការភវោតិ ។ អាមន្តា ។ អសង្ខតំ ចតុវោការភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៨៤) ន វត្តព្វំ ចត្តារោ អារុប្បា អសង្ខតាតិ ។ អាមន្តា ។ ននុ ចត្តារោ អារុប្បា អនេញ្ជា វុត្តា ភគវតាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារោ អារុប្បា អនេញ្ជា វុត្តា ភគវតា តេន វត រេ វត្តព្វេ ចត្តារោ អារុប្បា អសង្ខតាតិ ។

អារុប្បកថា ។

(៦៨២) ពួកសត្វ រមែងកើត ចាស់ ស្លាប់ ច្យុត កើតឡើង ក្នុងអាកាសានញ្ចាយតនៈឬ ។ អើ ។ ពួកសត្វ រមែងកើត ចាស់ ស្លាប់ ច្យុត កើតឡើង ក្នុងអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៨៣) វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអាកាសានញ្ចាយតនៈឬ ។ អើ ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អាកាសានញ្ចាយតនៈ គឺចតុវោការភពឬ ។ អើ ។ អសង្ខតៈ គឺចតុវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៨៤) បុគ្គលមិនគួរនិយាយថា អារុប្បៈ ៤ ជាអសង្ខតៈឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អារុប្បៈ ៤ ជាធម៌មិនញាប់ញ័រឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អារុប្បៈ ៤ ជាធម៌មិនញាប់ញ័រ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អារុប្បៈ ៤ ជាអសង្ខតៈ ។

ចប់ អារុប្បកថា ។

និរោធសមាបត្តិកថា

[៦៨៨] និរោធសមាបត្តិ អសង្ខតាតិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយនំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ និរោធសមាបត្តិ អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។បេ។ អន្តរិកា វាតិ ។ ន ហេវំ វត្តព្វេ ។បេ។ និរោធសមាបត្តិ អសង្ខតាតិ ។ អាមន្តា ។ អត្ថិ កេចិ និរោធំ សមាបជ្ជន្តិ បដិលភន្តិ ឧប្បាទេន្តិ សមុប្បាទេន្តិ ឧដ្ឋាបេន្តិ សមុដ្ឋាបេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ ជនេន្តិ សញ្ជនេន្តីតិ ។ អាមន្តា ។ អត្ថិ កេចិ អសង្ខតំ សមាបជ្ជន្តិ បដិលភន្តិ ឧប្បាទេន្តិ សមុប្បាទេន្តិ ឧដ្ឋាបេន្តិ សមុដ្ឋាបេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ ជនេន្តិ សញ្ជនេន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ។ និរោធា វោទានំ វុដ្ឋានំ បញ្ញាយតីតិ ។ អាមន្តា ។ អសង្ខតា វោទានំ វុដ្ឋានំ បញ្ញាយតីតិ ។ ន ហេវំ វត្តព្វេ

និរោធសមាបត្តិកថា

[៦៨៨] និរោធសមាបត្តិ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធសមាបត្តិ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។បេ។ ការវែមាស ទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធសមាបត្តិ ជាអសង្ខតៈឬ ។ អើ ។ មានបុគ្គលពួកខ្លះ ចូលកាន់និរោធ បានចំពោះនូវនិរោធ ញុំាងនិរោធ ឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យផុះឡើង ឲ្យផុះផុលឡើងឬ ។ អើ ។ មានបុគ្គលពួកខ្លះ ចូលកាន់អសង្ខតៈ បានចំពោះនូវអសង្ខតធម៌ ញុំាងអសង្ខតធម៌ ឲ្យកើតឡើង ឲ្យកើតឡើងព្រម ឲ្យតាំងឡើង ឲ្យតាំងឡើងព្រម ឲ្យលូតឡើង ឲ្យលាស់ឡើង ឲ្យផុះឡើង ឲ្យផុះផុលឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការផូរផង់ ការចេញ ព្រោះនិរោធ រមែងប្រាកដឬ ។ អើ ។ ការផូរផង់ ការចេញ ព្រោះអសង្ខតៈ រមែងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ

។បេ។ និរោធំ សមាបជ្ជន្តស្ស បឋមំ និរុជ្ឈតិ វចី-
សង្ខារោ តតោ កាយសង្ខារោ តតោ ចិត្តសង្ខារោតិ ។
អាមន្តា ។ អសន្តំ សមាបជ្ជន្តស្ស បឋមំ និរុជ្ឈតិ
វចីសង្ខារោ តតោ កាយសង្ខារោ តតោ ចិត្តសង្ខារោ-
តិ ។ ន ហេវំ វត្តព្វេ ។បេ។ និរោធា វុដ្ឋហន្តស្ស
បឋមំ ឧប្បជ្ជតិ ចិត្តសង្ខារោ តតោ កាយសង្ខារោ
តតោ វចីសង្ខារោតិ ។ អាមន្តា ។ អសន្តា វុដ្ឋ-
ហន្តស្ស បឋមំ ឧប្បជ្ជតិ ចិត្តសង្ខារោ តតោ កាយ-
សង្ខារោ តតោ វចីសង្ខារោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៨៦) និរោធា វុដ្ឋិតំ តយោ ផស្សា ផុសន្តិ
សុញ្ញតោ ផស្សោ អនិមិត្តោ ផស្សោ អប្បណិហិតោ
ផស្សោតិ ។ អាមន្តា ។ អសន្តា វុដ្ឋិតំ តយោ
ផស្សា ផុសន្តិ សុញ្ញតោ ផស្សោ អនិមិត្តោ ផស្សោ
អប្បណិហិតោ ផស្សោតិ ។ ន ហេវំ វត្តព្វេ ។បេ។

។បេ។ កាលបុគ្គលចូលកាន់និរោធ វចីសង្ខាររលត់មុន តទៅ ទើប
កាយសង្ខាររលត់ តទៅ ទើបចិត្តសង្ខាររលត់ឬ ។ អើ ។ កាល
បុគ្គលចូលកាន់អសន្តៈ វចីសង្ខាររលត់មុន តទៅ ទើបកាយសង្ខារ
រលត់ តទៅ ទើបចិត្តសង្ខាររលត់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ
។បេ។ កាលបុគ្គលចេញចាកនិរោធ ចិត្តសង្ខារកើតឡើងមុន តទៅ
ទើបកាយសង្ខារកើត តទៅ ទើបវចីសង្ខារកើតឬ ។ អើ ។ កាល-
បុគ្គលចេញចាកអសន្តៈ ចិត្តសង្ខារកើតឡើងមុន តទៅ ទើបកាយ-
សង្ខារកើត តទៅ ទើបវចីសង្ខារកើតឬ ។ អ្នកមិនគួរពោលយ៉ាងនេះ
ទេ ។បេ។

(៦៨៦) ផស្សៈ ៣ គឺ សុញ្ញតផស្សៈ ១ អនិមិត្តផស្សៈ ១
អប្បណិហិតផស្សៈ ១ រមែងពាល់ត្រូវ នូវបុគ្គលដែលចេញអំពីនិរោធឬ ។
អើ ។ ផស្សៈ ៣ គឺ សុញ្ញតផស្សៈ ១ អនិមិត្តផស្សៈ ១ អប្បណិហិត-
ផស្សៈ ១ រមែងពាល់ត្រូវ នូវបុគ្គលដែលចេញអំពីអសន្តៈឬ ។ អ្នកមិន
គួរពោលយ៉ាងនេះទេ ។បេ។

[៦៥៧] និរោធា វុដ្ឋហន្តស្ស វិវេកនិន្នំ ចិត្តំ ហោតិ វិវេកបោណំ វិវេកបព្ភារន្តិ ។ អាមន្តា ។ អសង្ខតា វុដ្ឋហន្តស្ស វិវេកនិន្នំ ចិត្តំ ហោតិ វិវេកបោណំ វិវេកបព្ភារន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៥៨] ន វត្តព្វំ និរោធសមាបត្តិ អសង្ខតាតិ ។ អាមន្តា ។ អសង្ខតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ និរោធសមាបត្តិ អសង្ខតាតិ ។

និរោធសមាបត្តិកថា ។

អាកាសកថា

[៦៥៩] អាកាសោ អសង្ខតោតិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយណំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៦០] អាកាសោ អសង្ខតោ និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា ភតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៥៧] ចិត្ត របស់បុគ្គលដែលចេញអំពីនិរោធ ទោរទៅកាន់វិវេក ឈមទៅកាន់វិវេក ផ្អៀងទៅកាន់វិវេកដែរឬ ។ អើ ។ ចិត្ត របស់បុគ្គលដែលចេញអំពីអសង្ខតៈ ទោរទៅកាន់វិវេក ឈមទៅកាន់វិវេក ផ្អៀងទៅកាន់វិវេកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៥៨] បុគ្គលមិនគួរនិយាយថា និរោធសមាបត្តិ ជាអសង្ខតៈទេឬ ។ អើ ។ និរោធសមាបត្តិ ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ និរោធសមាបត្តិ ជាអសង្ខតៈ ។

ចប់ និរោធសមាបត្តិកថា ។

អាកាសកថា

[៦៥៩] អាកាស ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រកកោន ជាទីការពារ ជាទីប្រព្រឹត្តទៅខាងមុខ ជាទីមិនច្យុត ជាទីមិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៦០] អាកាស ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មាន ២ ឬ ។ អើ ។ ទីពឹង មាន ២ ។ បេ ។ ការវិនាស ទៅក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៦១] អាកាសោ អសង្ខតោតិ ។ អាមន្តា ។ អត្ថិ កេចិ អនាកាសំ អាកាសំ ករោន្តីតិ ។ អាមន្តា ។ អត្ថិ កេចិ សង្ខតំ អសង្ខតំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៦២] អត្ថិ កេចិ អាកាសំ អនាកាសំ ករោន្តីតិ ។ អាមន្តា ។ អត្ថិ កេចិ អសង្ខតំ សង្ខតំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៦៣] អាកាសេ បក្ខិនោ គច្ឆន្តិ ចន្ទិមសុរិយា គច្ឆន្តិ តារការូបានិ គច្ឆន្តិ ឥទ្ធឹ វិកុព្វន្តិ ពាហុំ ចាលេន្តិ ចាណឹ ចាលេន្តិ លេឌ្ឌុំ ខិបន្តិ លគុឡំ ខិបន្តិ ឥទ្ធឹ ខិបន្តិ ឧសុំ ខិបន្តីតិ ។ អាមន្តា ។ អសង្ខតេ បក្ខិនោ គច្ឆន្តិ ចន្ទិមសុរិយា គច្ឆន្តិ តារការូបានិ គច្ឆន្តិ ឥទ្ធឹ វិកុព្វន្តិ ពាហុំ ចាលេន្តិ ចាណឹ ចាលេន្តិ លេឌ្ឌុំ ខិបន្តិ លគុឡំ ខិបន្តិ ឥទ្ធឹ ខិបន្តិ ឧសុំ ខិបន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៦១] អាកាស ជាអសង្ខតៈឬ ។ អើ ។ មាន បុគ្គលពួកខ្លះ ធ្វើនូវទីមិនមែនជាអាកាស ឲ្យជាអាកាសឬ ។ អើ ។ មាន បុគ្គលពួកខ្លះ ធ្វើនូវសង្ខតៈ ឲ្យជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៦២] មាន បុគ្គលពួកខ្លះ ធ្វើនូវអាកាស ឲ្យទៅជាមិនមែនអាកាសឬ ។ អើ ។ មាន បុគ្គលពួកខ្លះ ធ្វើនូវអសង្ខតៈ ឲ្យជាសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៦៣] ពួកសត្វស្លាប តែងហើរទៅ ព្រះចន្ទ្រនិងព្រះអាទិត្យ តែងចរទៅ ពួកផ្កាយ តែងចរទៅ ពួកជន តែងសម្តែងឫទ្ធិ តែងញ៉ាំងដើមដៃឲ្យកម្រើក ញ៉ាំងបាតដៃឲ្យកម្រើក បោះដុំដី បោះដំបង បោះឫទ្ធិ បោះកូនសរ នៅក្នុងអាកាសបានឬ ។ អើ ។ ពួកសត្វស្លាប តែងហើរទៅ ព្រះចន្ទ្រនិងព្រះអាទិត្យ តែងចរទៅ ពួកផ្កាយ តែងចរទៅ ពួកជន តែងសម្តែងឫទ្ធិ តែងញ៉ាំងដើមដៃឲ្យកម្រើក ញ៉ាំងបាតដៃឲ្យកម្រើក បោះដុំដី បោះដំបង បោះឫទ្ធិ បោះកូនសរ នៅក្នុងអសង្ខតៈបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៤) អាកាសំ បរិភេន្តា ឃរំ ករោន្តិ កោដ្ឋំ ករោន្តីតិ ។ អាមន្តា ។ អសង្ខតំ បរិភេន្តា ឃរំ ករោន្តិ កោដ្ឋំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៥) ឧទបានេ ខញ្ញមានេ អនាកាសោ អាកាសោ ហោតីតិ ។ អាមន្តា ។ សង្ខតំ អសង្ខតំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៦) តុច្ឆឧទបានេ បូរិយមានេ តុច្ឆកោដ្ឋេ បូរិយមានេ តុច្ឆកុម្ភិយា បូរិយមានាយ អាកាសោ អន្តរធាយតីតិ ។ អាមន្តា ។ អសង្ខតំ អន្តរធាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៧) ន វត្តព្វំ អាកាសោ អសង្ខតោតិ ។ អាមន្តា ។ អាកាសោ សង្ខតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អាកាសោ អសង្ខតោតិ ។

អាកាសកថា ។

(៦៦៤) ពួកជន បិទបាំងនូវអាកាស ហើយធ្វើផ្ទះតាំងឡាយ ធ្វើជង្រុកតាំងឡាយបានឬ ។ អើ ។ ពួកជន បិទបាំង នូវអសង្ខតៈ ហើយធ្វើផ្ទះតាំងឡាយ ធ្វើជង្រុកតាំងឡាយបានឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

(៦៦៥) កាលអណ្តូង ដែលគេជីក កាកាស ទៅជាមិនមែន អាកាសឬ ។ អើ ។ សង្ខតៈ ទៅជាអសង្ខតៈឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

(៦៦៦) កាលអណ្តូងទទេ ដែលគេដាក់ទឹកពេញ កាលជង្រុកទទេ ដែលគេដាក់ស្រូវពេញ កាលក្អមទទេ ដែលគេដាក់ទឹកពេញ អាកាស រមែងបាត់ឬ ។ អើ ។ អសង្ខតៈ រមែងបាត់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៧) បុគ្គលមិនគួរនិយាយថា អាកាស ជាអសង្ខតៈឬ ។ អើ ។ អាកាស ជាអសង្ខតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អាកាស ជាអសង្ខតៈ ។

ចប់ អាកាសកថា ។

អាកាសោ សនិទស្សនោតិកថា

(៦៦៨) អាកាសោ សនិទស្សនោតិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ នីលំ បីតកំ លោហិតកំ ឱទាតំ ចក្ខុវិញ្ញេយ្យំ ចក្ខុស្មឹ បដិហញ្ញតិ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៦៩) អាកាសោ សនិទស្សនោតិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៧០) ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ តេន វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច អាកាសញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

អាកាសសនិទស្សនោតិកថា

(៦៦៨) អាកាស ជាសនិទស្សនៈ (ប្រកបដោយការមើលឃើញ) ឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគប្បីដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៦៩) អាកាស ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៧០) ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវអាកាសផងទេ ។

(២៧១) ន វត្តព្វំ អាកាសោ សនិទស្សនោតិ ។ អាមន្តា ។ ននុ បស្សសិ ទ្វិន្នំ រុក្ខានំ អន្តរំ ទ្វិន្នំ ថម្ភានំ អន្តរំ តាឡច្ឆិទ្ទំ វាតបានច្ឆិទ្ទន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ ទ្វិន្នំ រុក្ខានំ អន្តរំ ទ្វិន្នំ ថម្ភានំ អន្តរំ តាឡច្ឆិទ្ទំ វាតបានច្ឆិទ្ទំ តេន វត រេ វត្តព្វេ អាកាសោ សនិទស្សនោតិ ។

អាកាសោ សនិទស្សនោតិកថា ។

បឋវីធាតុ សនិទស្សនាត្យាទិកថា

(២៧២) បឋវីធាតុ សនិទស្សនាតិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ នីលំ បីតកំ លោហិតកំ ឱទាតំ ចក្ខុវិញ្ញេយ្យំ ចក្ខុស្មឹ បដិហញ្ញតិ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៧៣) បឋវីធាតុ សនិទស្សនាតិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច បឋវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៧១) បុគ្គលមិនគួរនិយាយថា អាកាស ជាសនិទស្សនៈទេ ឬ ។ អើ ។ ក្រែងអ្នក ឃើញ នូវចន្លោះនៃដើមឈើពីរ នូវចន្លោះនៃសសរពីរ នូវប្រហោងនៃគូទសោ នូវប្រហោងនៃបង្អួចដែរឬ ។ អើ ។ បើអ្នក ឃើញ នូវចន្លោះនៃដើមឈើពីរ នូវចន្លោះនៃសសរពីរ នូវប្រហោងនៃគូទសោ នូវប្រហោងនៃបង្អួចដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាកាស ជាសនិទស្សនៈដែរ ។

ចប់ អាកាសសនិទស្សនោតិកថា ។

បឋវីធាតុសនិទស្សនាត្យាទិកថា

(២៧២) បឋវីធាតុ ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគប្បីដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៧៣) បឋវីធាតុ ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៧៤) ចក្ខុញ្ច បដិច្ច បថវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច បថវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ តេន វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច បថវីធាតុញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

(៦៧៥) ន វត្តព្វំ បថវីធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ ភូមិំ បាសាណំ បព្វតន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ ភូមិំ បាសាណំ បព្វតំ តេន វត រេ វត្តព្វេ បថវីធាតុ សនិទស្សនាតិ ។បេ។ ន វត្តព្វំ អាបោធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ ឧទកន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ ឧទកំ តេន វត រេ វត្តព្វេ អាបោធាតុ សនិទស្សនាតិ ។បេ។ ន វត្តព្វំ តេជោធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ អគ្គិំ ជលន្តន្តិ ។ អាមន្តា ។

(៦៧៤) ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវបឋវីធាតុផងទេ ។

(៦៧៥) បុគ្គលមិនគួរនិយាយថា បឋវីធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញផែនដី ថ្ម ភ្នំ ដែរឬ ។ អើ ។ បើអ្នក ឃើញផែនដី ថ្ម ភ្នំដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បឋវីធាតុ ជាសនិទស្សនៈដែរ ។បេ។ បុគ្គលមិនគួរនិយាយថា អាបោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញទឹកដែរឬ ។ អើ ។ បើអ្នក ឃើញទឹកដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាបោធាតុ ជាសនិទស្សនៈដែរ ។បេ។ បុគ្គលមិនគួរនិយាយថា តេជោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញភ្លើងកំពុងឆេះដែរឬ ។ អើ ។

ហញ្ចិ បស្សសិ អគ្គិំ ជលន្តំ តេន វត រេ វត្តព្វេ តេជោធាតុ សនិទស្សនាតិ ។បេ។ ន វត្តព្វំ វាយោធាតុ សនិទស្សនាតិ ។ អាមន្តា ។ ននុ បស្សសិ វាតេន រុក្ខេ សញ្ចាលិយមានេតិ ។ អាមន្តា ។ ហញ្ចិ បស្សសិ វាតេន រុក្ខេ សញ្ចាលិយមានេ តេន វត រេ វត្តព្វេ វាយោធាតុ សនិទស្សនាតិ ។បេ។

បឋវីធាតុ សនិទស្សនាត្យាទិកថា ។

ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា

(៦៧៦) ចក្ខុន្ទ្រិយំ សនិទស្សនន្តិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ ។បេ។ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៧៧) ចក្ខុន្ទ្រិយំ សនិទស្សនន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦៧៨) ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។

បើអ្នក ឃើញភ្លើងកំពុងឆេះដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា តេជោធាតុ ជាសនិទស្សនៈដែរ ។បេ។ បុគ្គលមិនគួរនិយាយថា វាយោធាតុ ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នកឃើញដើមឈើ ដែលរញ្ជួយដោយខ្យល់ដែរឬ ។ អើ ។ បើអ្នកឃើញដើមឈើ ដែលរញ្ជួយដោយខ្យល់ដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វាយោធាតុ ជាសនិទស្សនៈដែរ ។បេ។

ចប់ បឋវីធាតុសនិទស្សនាត្យាទិកថា ។

ចក្ខុន្ទ្រិយំ សនិទស្សនន្តិអាទិកថា

(៦៧៦) ចក្ខុន្ទ្រិយ ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ។បេ។ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៧៧) ចក្ខុន្ទ្រិយ ជាសនិទស្សនៈឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៧៨) ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។

ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ តេន វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច ចក្ខុន្ទ្រិយញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

(៦៧៩) ន វត្តព្វំ បញ្ចិន្ទ្រិយានិ សនិទស្សនានីតិ។ អាមន្តា ។ ននុ បស្សតិ ចក្ខុំ សោតំ ឃានំ ជិវ្ហំ កាយន្តិ ។ អាមន្តា ។ ហញ្ចិ បស្សតិ ចក្ខុំ សោតំ ឃានំ ជិវ្ហំ កាយំ តេន វត រេ វត្តព្វេ បញ្ចិន្ទ្រិយានិ សនិទស្សនានីតិ ។ បេ ។

បញ្ចិន្ទ្រិយំ សនិទស្សនន្តិអាទិកថា ។

កាយកម្មំ សនិទស្សនន្តិកថា

(៦៨០) កាយកម្មំ សនិទស្សនន្តិ ។ អាមន្តា ។ រូបំ រូបាយតនំ រូបធាតុ នីលំ បីតកំ លោហិតកំ ឱទាតំ ចក្ខុវិញ្ញេយ្យំ ចក្ខុស្មឹ បដិហញ្ញតិ ចក្ខុស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាយកម្មំ សនិទស្សនន្តិ ។ អាមន្តា ។

ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវចក្ខុន្ទ្រិយផងទេ ។

(៦៧៩) បុគ្គលមិនគួរនិយាយថា បញ្ចិន្ទ្រិយ (ឥន្ទ្រិយ ៥) ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយដែរឬ ។ អើ ។ បើអ្នកឃើញភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បញ្ចិន្ទ្រិយ ជាសនិទស្សនៈដែរ ។ បេ ។

ចប់ បញ្ចិន្ទ្រិយំ សនិទស្សនន្តិអាទិកថា ។

កាយកម្មំ សនិទស្សនន្តិកថា

(៦៨០) កាយកម្ម ជាសនិទស្សនៈឬ ។ អើ ។ រូប រូបាយតនៈ រូបធាតុ ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ដែលបុគ្គលគួរដឹងបានដោយចក្ខុ រមែងប៉ះពាល់ក្នុងចក្ខុ មកកាន់គន្លងនៃចក្ខុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាយកម្ម ជាសនិទស្សនៈឬ ។ អើ ។

ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ តេន វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច កាយកម្មញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

(៦៨១) ន វត្តព្វំ កាយកម្មំ សនិទស្សនន្តិ ។ អាមន្តា ។ ននុ បស្សសិ អភិក្កមន្តំ បដិក្កមន្តំ អាលោកេន្តំ វិលោកេន្តំ សម្មិញ្ជេន្តំ បសារេន្តន្តិ ។ អាមន្តា ។ ហញ្ចិ បស្សសិ អភិក្កមន្តំ បដិក្កមន្តំ អាលោកេន្តំ វិលោកេន្តំ សម្មិញ្ជេន្តំ បសារេន្តំ តេន វត រេ វត្តព្វេ កាយកម្មំ សនិទស្សនន្តិ ។

កាយកម្មំ សនិទស្សនន្តិកថា ។

ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផង ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផងឬ ។ អើ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវរូបទាំងឡាយផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ នូវចក្ខុផង នូវកាយកម្មផងទេ ។

(៦៨១) បុគ្គលមិនគួរនិយាយថា កាយកម្ម ជាសនិទស្សនៈទេឬ ។ អើ ។ ក្រែងអ្នក ឃើញបុគ្គលដែលកំពុងដើរទៅមុខ ថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេងៗ បត់អវយវៈ លាអវយវៈដែរឬ ។ អើ ។ បើអ្នក ឃើញបុគ្គលដែលកំពុងដើរទៅមុខ ថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេងៗ បត់អវយវៈ លាអវយវៈដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាយកម្ម ជាសនិទស្សនៈដែរ ។

ចប់ កាយកម្មំ សនិទស្សនន្តិកថា ។

បរិវាតុ សនិទស្សនាតិអាទី កថា

កាយកម្មំ សនិទស្សនន្តិ បរិយោសានកថា ។

ឆដ្ឋោ វគ្គោ ។

តស្ស ឧទ្ទានំ

និយាមោ អសង្ខតោ បដិច្ចសមុប្បាទោ

អសង្ខតោ ចត្តារិ សច្ចានិ អសង្ខតានិ

ចត្តារោ អារុប្បា អសង្ខតា និរោធ-

សមាបត្តិ អសង្ខតា អាកាសោ អសង្ខតោ

អាកាសោ សនិទស្សនោ ចត្តារោ មហាភូតា

បញ្ចិន្ទ្រិយានិ តថេវ កាយកម្មន្តិ ។

និយាយពីបរិវាតុសនិទស្សនៈជាដើម

និងកាយកម្មសនិទស្សនៈជាទីបំផុត ។

ចប់ ឆដ្ឋវគ្គ ។

ឧទ្ទាន នៃឆដ្ឋវគ្គនោះ គឺ

និយាយអំពី និយាមៈ ជាអសង្ខតៈ ១ បដិច្ចសមុប្បាទ ជាអសង្ខតៈ ១ សច្ចៈទាំង ៤ ជាអសង្ខតៈ ១ អារុប្បៈ ៤ ជាអសង្ខតៈ ១ និរោធសមាបត្តិ ជាអសង្ខតៈ ១ អាកាស ជាអសង្ខតៈ ១ អាកាស ជាសនិទស្សនៈ ១ មហាភូតរូប ៤ ជាសនិទស្សនៈ ១ បញ្ចិន្ទ្រិយ ជាសនិទស្សនៈ ១ កាយកម្ម ជាសនិទស្សនៈ ១ ។

---

(៨៦៦) អមតំ អារព្ភ មោហោ ឧប្បជ្ជតីតិ ។ អាមន្តា ។ អមតំ មោហដ្ឋានិយំ អញ្ញាណករណំ អចក្ខុករណំ បញ្ញានិរោធិយំ វិឃាតបក្ខិយំ អនិព្ពានសំវត្តនិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អមតំ ន មោហដ្ឋានិយំ ន អញ្ញាណករណំ ន អចក្ខុករណំ បញ្ញាវុឌ្ឍិយំ អវិឃាតបក្ខិយំ និព្ពានសំវត្តនិយន្តិ ។ អាមន្តា ។ ហញ្ចិ អមតំ ន មោហដ្ឋានិយំ ន អញ្ញាណករណំ ។ បេ ។ និព្ពានសំវត្តនិយំ នោ ច វត រេ វត្តព្វេ អមតំ អារព្ភ មោហោ ឧប្បជ្ជតីតិ ។

(៨៦៧) រូបំ អារព្ភ សញ្ញោជនា ឧប្បជ្ជន្តិ រូបំ សញ្ញោជនិយំ គន្ថនិយំ ។ បេ ។ សង្កិលេសិកន្តិ ។ អាមន្តា ។ អមតំ អារព្ភ សញ្ញោជនា ឧប្បជ្ជន្តិ អមតំ សញ្ញោជនិយំ គន្ថនិយំ ។ បេ ។ សង្កិលេសិកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨៦៨) រូបំ អារព្ភ រាគោ ឧប្បជ្ជតិ រូបំ រាគដ្ឋានិយំ រជនិយំ កាមនិយំ មទនិយំ

(៨៦៦) មោហៈ ប្រារព្ធនូវអមតៈ ទើបកើតឡើងឬ ។ អើ ។ (បើដូច្នោះ) អមតៈ ជាទីតាំងនៃមោហៈ ជាទីធ្វើមិនឲ្យមានញាណ ជាទីធ្វើមិនឲ្យមានចក្ខុ ជាទីតាំងនៃការរលត់បញ្ញា ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីនិព្វានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង អមតៈ មិនជាទីតាំងនៃមោហៈ មិនជាទីធ្វើមិនឲ្យមានញាណ មិនជាទីធ្វើមិនឲ្យមានចក្ខុ ជាទីតាំងនៃសេចក្តីចម្រើនបញ្ញា មិនជាចំណែកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីនិព្វានឬ ។ អើ ។ ប្រសិនបើ អមតៈ មិនជាទីតាំងនៃមោហៈ មិនជាទីធ្វើឲ្យមានញាណ ។ បេ ។ ប្រព្រឹត្តទៅដើម្បីនិព្វានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មោហៈ ប្រារព្ធនូវអមតៈ ទើបកើតឡើងទេ ។

(៨៦៧) សញ្ញោជនៈ ប្រារព្ធនូវរូប ទើបកើតឡើង រូប ជាទីតាំងនៃសញ្ញោជនៈ ជាទីតាំងនៃគន្ថៈ ។ បេ ។ គួរដល់សេចក្តីសៅហ្មងឬ ។ អើ ។ សញ្ញោជនៈ ប្រារព្ធនូវអមតៈ ទើបកើតឡើង អមតៈ ជាទីតាំងនៃសញ្ញោជនៈ ជាទីតាំងនៃគន្ថៈ ។ បេ ។ គួរដល់សេចក្តីសៅហ្មងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨៦៨) រាគៈ ប្រារព្ធនូវរូប ទើបកើតឡើង រូប ជាទីតាំងនៃរាគៈ ជាទីតាំងនៃតម្រេក ជាទីតាំងនៃសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីស្រវឹង

(៦៨៦) រូបាយតនំ ។បេ។ សទ្ទាយតនំ ។បេ។ គន្ធាយតនំ ។បេ។ រសាយតនំ ។បេ។ ផោដ្ឋព្វាយតនំ កតមក្ខន្ធគណនំ គច្ឆតីតិ ។ រូបក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ ផោដ្ឋព្វាយតនំ រូបក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ ផោដ្ឋព្វាយតនំ រូបក្ខន្ធេន សង្គហិតន្តិ ។

(៦៨៨) សុខា វេទនា កតមក្ខន្ធគណនំ គច្ឆតីតិ ។ វេទនាក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ សុខា វេទនា វេទនាក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ សុខា វេទនា វេទនាក្ខន្ធេន សង្គហិតាតិ ។ ទុក្ខា វេទនា ។បេ។ អទុក្ខមសុខា វេទនា កតមក្ខន្ធគណនំ គច្ឆតីតិ ។ វេទនាក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ អទុក្ខមសុខា វេទនា វេទនាក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ អទុក្ខមសុខា វេទនា វេទនាក្ខន្ធេន សង្គហិតាតិ ។

(៦៨៦) អាយតនៈគឺរូប ។បេ។ អាយតនៈគឺសំឡេង ។បេ។ អាយតនៈគឺក្លិន ។បេ។ អាយតនៈគឺរស ។បេ។ អាយតនៈគឺសម្ផស្ស ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយរូបក្ខន្ធ ។ បើអាយតនៈគឺសម្ផស្ស ដល់នូវការរាប់ដោយរូបក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាយតនៈគឺសម្ផស្ស សង្គ្រោះ ដោយរូបក្ខន្ធ ។

(៦៨៨) សុខវេទនា ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយវេទនាខន្ធ ។ បើសុខវេទនា ដល់នូវការរាប់ដោយវេទនាខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សុខវេទនា សង្គ្រោះ ដោយវេទនាខន្ធ ។ ទុក្ខវេទនា ។បេ។ អទុក្ខមសុខវេទនា ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយវេទនាខន្ធ ។ បើអទុក្ខមសុខវេទនា ដល់នូវការរាប់ដោយវេទនាខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អទុក្ខមសុខវេទនា សង្គ្រោះ ដោយវេទនាខន្ធ ។

[៦៨៦] ចក្ខុសម្ផស្សជា សញ្ញា កតមក្ខន្ធគណនំ គច្ឆតីតិ ។ សញ្ញាខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ ចក្ខុសម្ផស្សជា សញ្ញា សញ្ញាខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ ចក្ខុសម្ផស្សជា សញ្ញា សញ្ញាខន្ធេន សង្គហិតាតិ ។ សោតសម្ផស្សជា សញ្ញា ។បេ។ មនោសម្ផស្សជា សញ្ញា កតមក្ខន្ធគណនំ គច្ឆតីតិ ។ សញ្ញាខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ មនោសម្ផស្សជា សញ្ញា សញ្ញាខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ មនោសម្ផស្សជា សញ្ញា សញ្ញាខន្ធេន សង្គហិតាតិ ។

[៦៨៧] ចក្ខុសម្ផស្សជា ចេតនា ។បេ។ មនោសម្ផស្សជា ចេតនា កតមក្ខន្ធគណនំ គច្ឆតីតិ ។ សង្ខារក្ខន្ធគណនំ គច្ឆតីតិ ។ ហញ្ចិ មនោសម្ផស្សជា ចេតនា សង្ខារក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ មនោសម្ផស្សជា ចេតនា សង្ខារក្ខន្ធេន សង្គហិតាតិ ។

៦៧៣

សង្គហិតកថា

[៦៨៦] សញ្ញា កើតអំពីចក្ខុសម្ផស្ស ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយសញ្ញាខន្ធ ។ បើសញ្ញា កើតអំពីចក្ខុសម្ផស្ស ដល់នូវការរាប់ដោយសញ្ញាខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សញ្ញា កើតអំពីចក្ខុសម្ផស្ស សង្គ្រោះដោយសញ្ញាខន្ធ ។ សញ្ញា កើតអំពីសោតសម្ផស្ស ។បេ។ សញ្ញា កើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយសញ្ញាខន្ធ ។ បើសញ្ញា កើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយសញ្ញាខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សញ្ញា កើតអំពីមនោសម្ផស្ស សង្គ្រោះដោយសញ្ញាខន្ធ ។

[៦៨៧] ចេតនា កើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនា កើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយសង្ខារក្ខន្ធ ។ បើចេតនា កើតអំពីមនោសម្ផស្ស ដល់នូវការរាប់ដោយសង្ខារក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកគួរពោលថា ចេតនា កើតអំពីមនោសម្ផស្ស សង្គ្រោះដោយសង្ខារក្ខន្ធ ។

(៦៨៨) ចក្ខុវិញ្ញាណំ ។ បេ ។ មនោវិញ្ញាណំ កតមេន ខន្ធេន សង្គហំ គច្ឆតីតិ ។ វិញ្ញាណក្ខន្ធេន សង្គហំ គច្ឆតីតិ ។ ហញ្ចិ មនោវិញ្ញាណំ វិញ្ញាណក្ខន្ធេន សង្គហំ គច្ឆតិ តេន វត រេ វត្តព្វេ មនោវិញ្ញាណំ វិញ្ញាណក្ខន្ធេន សង្គហិតន្តិ ។ យថា ទាមេន វា យោត្តេន វា ទ្វេ ពលិពទ្ទា សង្គហិតា សិក្កាយ បិណ្ឌបាតោ សង្គហិតោ សោ គន្ទុលេន សង្គហិតោ ឯវមេវ តេ ធម្មា តេហិ ធម្មេហិ សង្គហិតាតិ ។ ហញ្ចិ ទាមេន វា យោត្តេន វា ទ្វេ ពលិពទ្ទា សង្គហិតា សិក្កាយ បិណ្ឌបាតោ សង្គហិតោ សោ គន្ទុលេន សង្គហិតោ តេន វត រេ វត្តព្វេ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សង្គហិតាតិ ។

សង្គហិតកថា ។

សម្បយុត្តកថា

(៦៨៩) អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សម្បយុត្តាតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សហគតា សហជាតា សំសដ្ឋា

(៦៨៨) ចក្ខុវិញ្ញាណ ។ បេ ។ មនោវិញ្ញាណ ដល់នូវការរាប់ដោយខន្ធណា ។ ដល់នូវការរាប់ដោយវិញ្ញាណក្ខន្ធ ។ បើមនោវិញ្ញាណ ដល់នូវការរាប់ដោយវិញ្ញាណក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា មនោវិញ្ញាណ សង្គ្រោះ ដោយវិញ្ញាណក្ខន្ធ ។ គោបម្រើពីរ សង្គ្រោះ ដោយខ្សែទាម ឬដោយពួរ បិណ្ឌបាត សង្គ្រោះ (ដាក់បញ្ចូល) ក្នុងសាឡែក ឯសាឡែកនោះ សង្គ្រោះ ដោយឈើពុន យ៉ាងណា ធម៌ទាំងនោះ សង្គ្រោះ ដោយធម៌ទាំងនោះ ក៏យ៉ាងនោះដែរ ។ បើគោបម្រើពីរ សង្គ្រោះ ដោយខ្សែទាម ឬដោយពួរ បិណ្ឌបាត សង្គ្រោះ (ដាក់បញ្ចូល) ក្នុងសាឡែក ឯសាឡែកនោះ សង្គ្រោះ ដោយឈើពុន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកធម៌នីមួយ សង្គ្រោះ ដោយពួកធម៌នីមួយ មានដែរ ។

ចប់ សង្គហិតកថា ។

សម្បយុត្តកថា

(៦៨៩) ពួកធម៌នីមួយ ប្រកបដោយពួកធម៌នីមួយ មានឬ ។ អើ ។ ក្រែងពួកធម៌នីមួយ ប្រព្រឹត្តទៅមួយអន្លើ កើតមួយអន្លើ ច្រឡំព្រម

ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណាតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សហគតា សហជាតា សំសដ្ឋា ឯកុប្បាទា ឯក-និរោធា ឯកវត្ថុកា ឯការម្មណា តេន វត រេ វត្តព្វេ អត្ថិ កេចិ ធម្មា កេហិចិ ធម្មេហិ សម្បយុត្តាតិ ។

(៦៩០) វេទនាក្ខន្ធោ សញ្ញាក្ខន្ធេន សហជា-តោតិ ។ អាមន្តា ។ ហញ្ចិ វេទនាក្ខន្ធោ សញ្ញាក្ខន្ធេន សហជាតោ តេន វត រេ វត្តព្វេ វេទនាក្ខន្ធោ សញ្ញា-ក្ខន្ធេន សម្បយុត្តោតិ ។ វេទនាក្ខន្ធោ សង្ខារក្ខន្ធេន វិញ្ញាណក្ខន្ធេន សហជាតោតិ ។ អាមន្តា ។ ហញ្ចិ វេទនាក្ខន្ធោ វិញ្ញាណក្ខន្ធេន សហជាតោ តេន វត រេ វត្តព្វេ វេទនាក្ខន្ធោ វិញ្ញាណក្ខន្ធេន សម្បយុត្តោតិ ។ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ វេទនា-ក្ខន្ធេន សញ្ញាក្ខន្ធេន សង្ខារក្ខន្ធេន សហជាតោតិ ។ អាមន្តា ។ ហញ្ចិ វិញ្ញាណក្ខន្ធោ សង្ខារក្ខន្ធេន សហជាតោ តេន វត រេ វត្តព្វេ វិញ្ញាណក្ខន្ធោ សង្ខារក្ខន្ធេន សម្បយុត្តោតិ ។ យថា តិលម្ហិ តេលំ អនុគតំ អនុបវិដ្ឋំ ឧច្ឆុម្ហិ រសោ អនុគតោ អនុបវិដ្ឋោ

កើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយពួកធម៌មួយៗ ។ អើ ។ បើពួកធម៌មួយ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ច្រឡំព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយពួកធម៌មួយ មាន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌មួយ ប្រកបដោយពួកធម៌មួយ មិនមានទេ ។

(៦៩០) វេទនាខន្ធ កើតជាមួយ នឹងសញ្ញាខន្ធឬ ។ អើ ។ បើវេទនាខន្ធ កើតជាមួយ នឹងសញ្ញាខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វេទនាខន្ធ ប្រកបដោយសញ្ញាខន្ធ (មាន) ។ វេទនាខន្ធ កើតជាមួយ នឹងសង្ខារក្ខន្ធ នឹងវិញ្ញាណក្ខន្ធឬ ។ អើ ។ បើវេទនាខន្ធ កើតជាមួយ នឹងវិញ្ញាណក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វេទនាខន្ធ ប្រកបដោយវិញ្ញាណក្ខន្ធ (មាន) ។ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ កើតជាមួយ នឹងវេទនាខន្ធ នឹងសញ្ញាខន្ធ នឹងសង្ខារក្ខន្ធឬ ។ អើ ។ បើវិញ្ញាណក្ខន្ធ កើតជាមួយ នឹងសង្ខារក្ខន្ធ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិញ្ញាណក្ខន្ធ ប្រកបដោយសង្ខារក្ខន្ធ (មាន) ។ ប្រេងល្ង ឋិតនៅស៊ប់ ចូលទៅស៊ប់ ក្នុងគ្រាប់ល្ង រសអំពៅ ឋិតនៅស៊ប់ ចូលទៅស៊ប់ ក្នុងដើមអំពៅ យ៉ាងណា

ឯវមេវ តេ ធម្មា តេហិ ធម្មេហិ អនុគតា អនុបវិដ្ឋាតិ ។ ន ហេវំ វត្តព្វេ ។បេ។

សម្បយុត្តកថា ។

ចេតសិកកថា

(៦៤១) នត្ថិ ចេតសិកោ ធម្មោតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ ធម្មា ចិត្តេន សហគតា សហជាតា សំសដ្ឋា សម្បយុត្តា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណាតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ ធម្មា ចិត្តេន សហគតា សហជាតា សំសដ្ឋា សម្បយុត្តា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណា តេន វត រេ វត្តព្វេ នត្ថិ ចេតសិកោ ធម្មោតិ ។

(៦៤២) ផស្សោ ចិត្តេន សហជាតោតិ ។ អាមន្តា ។ ហញ្ចិ ផស្សោ ចិត្តេន សហជាតោ តេន វត រេ វត្តព្វេ ផស្សោ ចេតសិកោតិ ។ វេទនា ។បេ។ សញ្ញា ចេតនា ។បេ។ សទ្ធា វីរិយំ សតិ សមាធិ បញ្ញា រាគោ ទោសោ មោហោ ។បេ។ អនោត្តប្បំ ចិត្តេន សហជាតន្តិ ។ អាមន្តា ។

ធម៌ទាំងនោះ ជិតទៅស៊ប់ ចូលទៅស៊ប់ ដោយធម៌ទាំងនោះ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ សម្បយុត្តកថា ។

ចេតសិកកថា

(៦៤១) ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មិនមានឬ ។ អើ ។ ក្រែងពួកធម៌ខ្លះ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ច្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្ត មានដែរឬ ។ អើ ។ បើពួកធម៌ខ្លះ ប្រព្រឹត្តទៅជាមួយ កើតជាមួយ ច្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្ត មាន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេ ។

(៦៤២) ផស្សៈ កើតជាមួយនឹងចិត្តឬ ។ អើ ។ បើផស្សៈ កើតជាមួយនឹងចិត្ត (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ផស្សៈ ជាចេតសិក ។ វេទនា ។បេ។ សញ្ញា ចេតនា ។បេ។ សទ្ធា វីរិយៈ សតិ សមាធិ បញ្ញា រាគៈ ទោសៈ មោហៈ ។បេ។ អនោត្តប្បៈ កើតជាមួយនឹងចិត្តឬ ។ អើ ។

ហញ្ចិ អនោត្តប្បំ ចិត្តេន សហជាតំ តេន វត រេ វត្តព្វេ អនោត្តប្បំ ចេតសិកន្តិ ។ ចិត្តេន សហជាតាតិ កត្វា ចេតសិកាតិ ។ អាមន្តា ។ ផស្សេន សហជាតាតិ កត្វា ផស្សិកាតិ ។ អាមន្តា ។ ចិត្តេន សហជាតាតិ កត្វា ចេតសិកាតិ ។ អាមន្តា ។ វេទនាយ ។បេ។ សញ្ញាយ ចេតនាយ សទ្ធាយ វីរិយេន សតិយា សមាធិនា បញ្ញាយ រាគេន ទោសេន មោហេន ។បេ។ អនោត្តប្បេន សហជាតាតិ កត្វា អនោត្តប្បិកាតិ ។ អាមន្តា ។ នត្ថិ ចេតសិកោ ធម្មោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

ចិត្តមិទំ ចេតសិកា ច ធម្មា
អនត្តតោ សំវិទិតស្ស ហោន្តិ
ហីនប្បណីតំ តទុភយេ វិទិត្វា
សម្មទ្ទសោ វេទិ បលោកធម្មន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ ចេតសិកោ ធម្មោតិ ។

បើអនោត្តប្បៈ កើតជាមួយនឹងចិត្ត (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អនោត្តប្បៈ ជាចេតសិក ។ ពួកធម៌ ជាចេតសិក ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងចិត្តឬ ។ អើ ។ ពួកធម៌ ប្រព្រឹត្តទៅក្នុងផស្សៈ ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងផស្សៈឬ ។ អើ ។ ពួកធម៌ ជាចេតសិក ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងចិត្តឬ ។ អើ ។ ពួកធម៌ នឹងវេទនា ។បេ។ នឹងសញ្ញា នឹងចេតនា នឹងសទ្ធា នឹងវីរិយៈ នឹងសតិ នឹងសមាធិ នឹងបញ្ញា នឹងរាគៈ នឹងទោសៈ នឹងមោហៈ ។បេ។ ពួកធម៌ ប្រព្រឹត្តទៅក្នុងអនោត្តប្បៈ ព្រោះធ្វើសេចក្តីចូលចិត្តថា កើតជាមួយនឹងអនោត្តប្បៈឬ ។ អើ ។ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ចិត្តនេះក្តី ចេតសិកធម៌ទាំងឡាយក្តី របស់បុគ្គលដែលដឹង
ច្បាស់ ដោយអនត្តលក្ខណៈ កើតប្រាកដ បុគ្គលឃើញ
ដោយប្រពៃ នូវធម៌ ដ៏ថោកទាបនិងប្រសើរ ក៏ព្រោះដឹង
ច្បាស់ នូវធម៌ទាំងពីរនោះ ទើបទទួលលោកធម៌ (ធម៌ដែល
បាក់បែកប្រុះប្រោយទៅ)

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មាន ។

(៦៤៣) នត្ថិ ចេតសិកោ ធម្មោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ កេវដ្ដ ភិក្ខុ បរសត្តានំ បរៈ បុគ្គលានំ ចិត្តម្បិ អាទិសតិ ចេតសិកម្បិ អាទិសតិ វិតក្កិតម្បិ អាទិសតិ វិចារិតម្បិ អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ ចេតសិកោ ធម្មោតិ ។

ចេតសិកកថា ។

ទានកថា

(៦៤៤) ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ លព្ភា ចេតសិកោ ធម្មោ បរេសំ ទាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា ចេតសិកោ ធម្មោ បរេសំ ទាតុន្តិ ។ អាមន្តា ។ លព្ភា ផស្សោ បរេសំ ទាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា វេទនា ។ បេ ។ សញ្ញា ចេតនា សទ្ធា វីរិយំ សតិ សមាធិ ។ បេ ។ បញ្ញា បរេសំ ទាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៤៣) ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកេវដ្ដៈ ភិក្ខុក្នុងធម្មវិន័យនេះ តែងសម្ដែងបញ្ជាក់ចិត្តផង សម្ដែងបញ្ជាក់ធម៌ដែលប្រព្រឹត្តទៅក្នុងចិត្តផង សម្ដែងបញ្ជាក់ធម៌ដែលខ្លួនត្រិះរិះហើយផង សម្ដែងបញ្ជាក់ធម៌ដែលខ្លួនពិចារណាហើយផង ដល់ពួកសត្វដទៃ ដល់ពួកបុគ្គលដទៃថា ចិត្តរបស់អ្នកយ៉ាងនេះខ្លះ ចិត្តរបស់អ្នក មានប្រការយ៉ាងនេះខ្លះ ចិត្តរបស់អ្នក ដូច្នេះខ្លះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត មាន ។

ចប់ ចេតសិកកថា ។

ទានកថា

(៦៤៤) ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាទានឬ ។ អើ ។ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អើ ។ ផស្សៈ ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ចេតនា សទ្ធា វីរិយៈ សតិ សមាធិ ។ បេ ។ បញ្ញា ដែលបុគ្គលបាន ដើម្បីឲ្យដល់បុគ្គលដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ទានកថា

[៦៩៨] ន វត្តព្វំ ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ ទានំ អនិដ្ឋផលំ អកន្តផលំ អមនុញ្ញផលំ សេចនកផលំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ ទានំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ អាមន្តា ។ ហញ្ចិ ទានំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកំ តេន វត រេ វត្តព្វេ ចេតសិកោ ធម្មោ ទានន្តិ ។ ទានំ ឥដ្ឋផលំ វុត្តំ ភគវតា ចីវរំ ទានន្តិ ។ អាមន្តា ។ ចីវរំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ទានំ ឥដ្ឋផលំ វុត្តំ ភគវតា បិណ្ឌបាតោ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ទានន្តិ ។ អាមន្តា ។ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ឥដ្ឋផលោ កន្តផលោ មនុញ្ញផលោ អសេចនកផលោ សុខុទ្រយោ សុខវិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

ទានកថា

[៦៩៨] បុគ្គលមិនគួរនិយាយថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាទានទេឬ ។ អើ ។ ទាន មានផលមិនជាទីប្រាថ្នា មានផលមិនជាទីត្រេកអរ មានផលមិនជាទីគាប់ចិត្ត មានផលប្រឡូកប្រឡំ ចម្រើនដោយទុក្ខ មានវិបាកជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អើ ។ បើទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខ(យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាទាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា ចុះចីវរ ជាទានឬ ។ អើ ។ ចីវរ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទាន មានផលជាទីប្រាថ្នា ចុះបិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ជាទានឬ ។ អើ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៦៩៦) ន វត្តព្វំ ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

សទ្ធា ហិរិយំ កុសលញ្ច ទានំ
ធម្មា ឯតេ សប្បុរិសានុយាតា
ឯតំ ហិ មគ្គំ ទិវិយំ វទន្តិ
ឯតេន ហិ គច្ឆតិ ទេវលោកន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ចេតសិកោ ធម្មោ ទានន្តិ ។

(៦៩៧) ន វត្តព្វំ ចេតសិកោ ធម្មោ ទានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិមានិ ភិក្ខវេ ទានានិ មហាទានានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ បោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កិយន្តិ ន សង្កិយិស្សន្តិ អប្បដិក្កុដ្ឋានិ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ អរិយសាវកោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ បាណាតិបាតា បដិវិរតោ ភិក្ខវេ អរិយសាវកោ អបរិមាណានំ សត្តានំ អភយំ ទេតិ អវេរំ ទេតិ អព្យាបជ្ឈំ ទេតិ

(៦៩៦) បុគ្គលមិនគួរនិយាយថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាទានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

សទ្ធា ហិរិ និងកុសល ហៅថាទាន ធម៌ទាំងនុ៎ះ ជាទីប្រព្រឹត្តទៅរឿយៗនៃសប្បុរស ព្រោះថា អ្នកប្រាជ្ញទាំងឡាយ រមែងពោលនូវធម៌នុ៎ះ ថាជាផ្លូវគួរប្រាជ្ញា ព្រោះបុគ្គល ទៅកាន់ទេវលោក ដោយផ្លូវនុ៎ះ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ជាក់ជាទាន ។

(៦៩៧) បុគ្គលមិនគួរនិយាយថា ធម៌ ប្រព្រឹត្តទៅក្នុងចិត្ត ជាក់ជាទានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទាន ៥ យ៉ាងនេះ ជាមហាទាន ដែលបណ្ឌិតដឹងថាជាទានប្រសើរ ដឹងថាមានមកអស់កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិតមិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះបង់ នឹងមិនលះបង់ ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់ចោលឡើយ ។ ទាន ទាំង ៥ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ក្នុងសាសនានេះ ជាអ្នកលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក វៀរស្រឡះចាកបាណាតិបាតហើយ ឈ្មោះថាឲ្យអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្តីមិនព្យាបាទ ដល់សត្វទាំងឡាយមានប្រមាណមិនបាន

អបរិមាណានំ សត្តានំ អភយំ ទត្វា អវេរំ ទត្វា អព្យាបជ្ឈំ ទត្វា អបរិមាណស្ស អភយស្ស អវេរស្ស អព្យាបជ្ឈស្ស ភាគី ហោតិ ឥទំ ភិក្ខវេ បឋមំ ទានំ មហាទានំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ បោរាណំ អសង្កិណ្ណំ អសង្កិណ្ណបុព្វំ ន សង្កិយតិ ន សង្កិយិស្សតិ អប្បដិកុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ បុន ចបរំ ភិក្ខវេ អរិយសាវកោ អទិន្នាទានំ បហាយ ។បេ។ កាមេសុ មិច្ឆាចារំ បហាយ ។បេ។ មុសាវាទំ បហាយ ។បេ។ សុរាមេរយមជ្ជប្បមា-ទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិ-វិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ភិក្ខវេ អរិយសាវកោ អបរិមាណានំ សត្តានំ អភយំ ទេតិ អវេរំ ទេតិ អព្យាបជ្ឈំ ទេតិ អបរិមាណានំ សត្តានំ អភយំ ទត្វា អវេរំ ទត្វា អព្យាបជ្ឈំ ទត្វា

លុះឲ្យអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្ដីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែកដោយសេចក្ដីមិនមានភ័យ មិនមានពៀរ មិនមានព្យាបាទ មានប្រមាណមិនបាន ម្នាលភិក្ខុទាំងឡាយ នេះ ជាទានទី ១ ជាមហាទាន ដែលបណ្ឌិតដឹងថាជាទានប្រសើរ ដឹងថាមានមកអស់ កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិតមិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះបោល ទំនងមិនលះបោល ដែលសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់ចោលឡើយ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក លះបង់នូវអទិន្នាទាន ។បេ។ លះបង់នូវការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ។បេ។ លះបង់នូវមុសាវាទ ។បេ។ លះបង់នូវហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ជាអ្នកវៀរស្រឡះ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ម្នាលភិក្ខុទាំង-ឡាយ អរិយសាវក វៀរស្រឡះ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យហើយ ឈ្មោះថា ឲ្យនូវអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្ដីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឲ្យនូវអភ័យ ឲ្យនូវការមិនមានពៀរ ឲ្យនូវសេចក្ដីមិនព្យាបាទ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ

អបរិមាណស្ស អភយស្ស អវេរស្ស អព្យាបជ្ឈស្ស ភាគី ហោតិ ឥទំ ភិក្ខវេ បញ្ចមំ ទានំ មហាទានំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ បោរាណំ អសង្កិណ្ណំ អសង្កិណ្ណបុព្វំ ន សង្កិយតិ ន សង្កិយិស្សតិ អប្បដិក្កុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ឥមានិ ខោ ភិក្ខវេ បញ្ច ទានានិ មហាទានានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ បោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កិយន្តិ ន សង្កិយិស្សន្តិ អប្បដិក្កុដ្ឋានិ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ចេតសិកោ ធម្មោ ទានន្តិ ។

(៦៩៨) ន វត្តព្វំ ទេយ្យធម្មោ ទានន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធេកច្ចោ អន្នំ ទេតិ បានំ ទេតិ វត្ថំ ទេតិ យានំ ទេតិ មាលំ ទេតិ គន្ធំ ទេតិ វិលេបនំ ទេតិ សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ទេយ្យធម្មោ ទានន្តិ ។

រមែងជាអ្នកមានចំណែក ដោយការមិនមានភ័យ មិនមានពៀរ មិនមានព្យាបាទ មានប្រមាណមិនបាន ម្នាលភិក្ខុទាំងឡាយ នេះ ជាទានទី ៥ ជាមហាទាន ដែលបណ្ឌិតដឹងថាជាទានប្រសើរ ដឹងថាមានមកអស់កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិត មិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះបោល នឹងមិនលះបោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់ចោលឡើយ ម្នាលភិក្ខុទាំងឡាយ ទាន ៥ យ៉ាងនេះឯង ជាមហាទាន ដែលបណ្ឌិត ដឹងថាជាទានប្រសើរ ដឹងថាមានមក អស់កាលយូរហើយ ដឹងថាជាវង្សរបស់សប្បុរស ជារបស់នៃបុរសក្នុងកាលមុន ដែលបណ្ឌិត មិនដែលលះបង់ មិនធ្លាប់លះបង់ រមែងមិនលះបោល នឹងមិនលះបោល ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ មិនបោះបង់ចោលឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត បានជាទាន ។

(៦៩៨) បុគ្គលមិនគួរនិយាយថា ទេយ្យធម៌ ជាទានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យបាយ ឲ្យទឹក ឲ្យសំពត់ ឲ្យយាន ឲ្យផ្កាកម្រង ឲ្យគ្រឿងក្រអូប ឲ្យគ្រឿងលាប ឲ្យទីដេក ឲ្យទីសំណាក់អាស្រ័យ ឲ្យគ្រឿងប្រទីប ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទេយ្យធម៌ បានជាទាន ។

(៦៩៩) ទេយ្យធម្មោ ផលតីតិ ។ អាមន្តា ។ ទេយ្យធម្មោ ឥដ្ឋផលោ កន្តផលោ មនុញ្ញផលោ អសេចនកផលោ សុខុទ្រយោ សុខវិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។ ចាគំ ឥដ្ឋផលំ វុត្តំ ភគវតា ចីវរំ ផលតីតិ ។ អាមន្តា ។ ចីវរំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ចាគំ ឥដ្ឋផលំ វុត្តំ ភគវតា បិណ្ឌបាតោ ចាគំ សេនាសនំ ចាគំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ផលតីតិ ។ អាមន្តា ។ គិលានប្បច្ចយភេសជ្ជបរិក្ខារោ ឥដ្ឋផលោ កន្តផលោ មនុញ្ញផលោ អសេចនកផលោ សុខុទ្រយោ សុខវិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។ តេន ហិ ន វត្តព្វំ ទេយ្យធម្មោ ផលតីតិ ។

ទានកថា ។

បរិភោគមយបុញ្ញកថា

(៧០០) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។

៦៨៣

បរិភោគមយបុញ្ញកថា

(៦៩៩) ទេយ្យធម៌ ឈ្មោះថាជាផលឬ ។ អើ ។ ទេយ្យធម៌ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ចាគ មានផលជាទីប្រាថ្នា (យ៉ាងនេះ) ចុះចីវរ ជាផលឬ ។ អើ ។ ចីវរ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ចាគ មានផលជាទីប្រាថ្នា (យ៉ាងនេះ) ចុះ បិណ្ឌបាត ជាចាគ សេនាសនៈ ជាចាគ គិលានប្បច្ចយភេសជ្ជបរិក្ខារ ជាផលដែរឬ ។ អើ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ ចម្រើនដោយសុខ មានវិបាកជាសុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ទេយ្យធម៌ ជាផលទេ ។

ចប់ ទានកថា ។

បរិភោគមយបុញ្ញកថា

(៧០០) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។

បរិភោគមយោ ផស្សោ វឌ្ឍតិ វេទនា វឌ្ឍតិ សញ្ញា វឌ្ឍតិ ចេតនា វឌ្ឍតិ ចិត្តំ វឌ្ឍតិ សទ្ធា វឌ្ឍតិ វីរិយំ វឌ្ឍតិ សតិ វឌ្ឍតិ សមាធិ វឌ្ឍតិ បញ្ញា វឌ្ឍតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧០១) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។ លតា វិយ វឌ្ឍតិ មាលុវា វិយ វឌ្ឍតិ រុក្ខោ វិយ វឌ្ឍតិ តិណំ វិយ វឌ្ឍតិ មុញ្ជបុញ្ជោ វិយ វឌ្ឍតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧០២) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។ ទាយកោ ទានំ ទត្វា ន សមន្នាហរតិ ហោតិ បុញ្ញន្តិ ។ អាមន្តា ។ អនាវជ្ជន្តស្ស ហោតិ អនាភោគស្ស ហោតិ អសមន្នាហរន្តស្ស ហោតិ អមនសិការោន្តស្ស ហោតិ អចេតយន្តស្ស ហោតិ អបត្ថយន្តស្ស ហោតិ អប្បណិទហន្តស្ស ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ អាវជ្ជន្តស្ស ហោតិ អាភោគស្ស ហោតិ សមន្នាហរន្តស្ស ហោតិ មនសិការោន្តស្ស ហោតិ ចេតយន្តស្ស ហោតិ បត្ថយន្តស្ស ហោតិ បណិទហន្តស្ស ហោតីតិ ។

ផស្សៈ សម្រេចដោយការបរិភោគ តែងចម្រើន វេទនា តែងចម្រើន សញ្ញា តែងចម្រើន ចេតនា តែងចម្រើន ចិត្ត តែងចម្រើន សទ្ធា តែងចម្រើន វីរិយៈ តែងចម្រើន សតិ តែងចម្រើន សមាធិ តែងចម្រើន បញ្ញា តែងចម្រើនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៧០១) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ បុណ្យ តែងចម្រើន ដូចជាវល្លិ (ទៀងដើមឈើ) ចម្រើនដូចជាគូលែជ ចម្រើនដូចជាដើមឈើ ចម្រើនដូចជាស្មៅ ចម្រើនដូចជាបាច់នៃស្មៅយាប្លង់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៧០២) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ទាយក ឲ្យទាន មិនពិចារណាទេ បុណ្យ មានដែរឬ ។ អើ ។ បុណ្យ របស់បុគ្គល កាលមិននឹកនា មិនអើពើ មិនពិចារណា មិនធ្វើទុកក្នុងចិត្ត មិនគិត មិនប្រាថ្នា មិនតាំងចិត្តមាំ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងបុណ្យ របស់បុគ្គល កាលនឹកនា អើពើ ពិចារណា ធ្វើទុកក្នុងចិត្ត គិត ប្រាថ្នា តាំងចិត្តមាំ មានឬ ។

អាមន្តា ។ ហញ្ចិ អាវជ្ជន្តស្ស ហោតិ អាភោគស្ស
ហោតិ សមន្នាហរន្តស្ស ហោតិ មនសិករោន្តស្ស
ហោតិ ចេតយន្តស្ស ហោតិ បត្ថយន្តស្ស ហោតិ
បណិទហន្តស្ស ហោតិ នោ វត រេ វត្តព្វេ បរិភោគ-
មយំ បុញ្ញំ វឌ្ឍតីតិ ។

(៧០៣) បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។
ទាយកោ ទានំ ទត្វា កាមវិតក្កំ វិតក្កេតិ ព្យាបាទ-
វិតក្កំ វិតក្កេតិ វិហឹសាវិតក្កំ វិតក្កេតិ ហោតិ បុញ្ញន្តិ ។
អាមន្តា ។ ទ្វិន្នំ ផស្សានំ ។បេ។ ទ្វិន្នំ ចិត្តានំ
សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទ្វិន្នំ
ផស្សានំ ។បេ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។
អាមន្តា ។ កុសលាកុសលា សាវជ្ជានវជ្ជា ហីនប្ប-
ណីតា កណ្ហសុក្កសប្បដិភាគា ធម្មា សម្មុខីភាវំ
អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ។ កុសលាកុសលា
សាវជ្ជានវជ្ជា ហីនប្បណីតា កណ្ហសុក្កសប្បដិភាគា
ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។ អាមន្តា ។ ននុ
វុត្តំ ភគវតា ចត្តារិមានិ ភិក្ខវេ សុវិទូរវិទូរានិ ។
កតមានិ ចត្តារិ ។ នភញ្ច ភិក្ខវេ បឋវី ច

អើ ។ បើបុណ្យ របស់បុគ្គល កាលនឹកនា អើពើ ពិចារណា ធ្វើទុកក្នុងចិត្ត គិត ប្រាថ្នា តំកល់ចិត្តមាំ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនទេ ។

(៧០៣) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ទាយក ឲ្យទាន ហើយត្រិះរិះនូវកាមវិតក្កៈ ត្រិះរិះនូវព្យាបាទវិតក្កៈ ត្រិះរិះនូវវិហឹសាវិតក្កៈ បុណ្យ មានដែរឬ ។ អើ ។ ការប្រជុំចុះ នៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការប្រជុំចុះ នៃផស្សៈទាំងពីរ ។បេ។ នៃចិត្តទាំងពីរ មានឬ ។ អើ ។ ពួកធម៌ ជាកុសលនិងអកុសល មានទោសនិងមិនមានទោស ថោកទាបនិងឧត្តម មានចំណែកខ្មៅនិងចំណែកស មកកាន់ភាវៈចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ពួកធម៌ជាកុសលនិងអកុសល មានទោសនិងមិនមានទោស ថោកទាបនិងឧត្តម មានចំណែកខ្មៅនិងចំណែកស មកកាន់ភាវៈចំពោះមុខឬ ។ អើ ។ តែក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតឆ្ងាយក្រៃលែងណាស់នេះ មាន ៤ យ៉ាង ។ ធម្មជាតឆ្ងាយក្រៃលែងណាស់ ទាំង ៤ នោះ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មេឃនិងប្រឹថពី

ឥទំ បឋមំ សុវិទូរវិទូរំ ឱរិមញ្ច ភិក្ខវេ តីរំ សមុទ្ទស្ស
បារិមញ្ច តីរំ ឥទំ ទុតិយំ សុវិទូរវិទូរំ យតោ ច ភិក្ខវេ
វេរោចនោ អព្ភុទេតិ យត្ថ ច អត្ថមេតិ ឥទំ តតិយំ
សុវិទូរវិទូរំ សតញ្ច ភិក្ខវេ ធម្មោ អសតញ្ច ធម្មោ ឥទំ
ចតុត្ថំ សុវិទូរវិទូរំ ឥមានិ ខោ ភិក្ខវេ ចត្តារិ សុវិទូរ-
វិទូរានីតិ

នភញ្ច ទូរេ បថវី ច ទូរេ
បារំ សមុទ្ទស្ស តទាហុ ទូរេ
យតោ ច វេរោចនោ អព្ភុទេតិ
បភង្ករោ យត្ថ ច អត្ថមេតិ
តតោ ហវេ ទូរតរំ វទន្តិ
សតញ្ច ធម្មំ អសតញ្ច ធម្មំ
អព្យាយិកោ ហោតិ សតំ សមាគមោ
យាវម្បិ តិដ្ឋេយ្យ តថេវ ហោតិ
ខិប្បំ ហិ វេតិ អសតំ សមាគមោ
តស្មា សតំ ធម្មោ អសព្ភិ អារកាតិ

នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ១ ម្នាលភិក្ខុទាំងឡាយ ត្រើយ
ខាងអាយ និងត្រើយខាងនាយនៃសមុទ្រ នេះ ជាធម្មជាតឆ្ងាយក្រៃលែង
ណាស់ទី ២ ម្នាលភិក្ខុទាំងឡាយ ព្រះអាទិត្យ រះឡើងអំពីទិសណា និង
អស្តង្គតទៅក្នុងទិសណា នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ៣ ម្នាល
ភិក្ខុទាំងឡាយ ធម៌ទាំងឡាយរបស់ពួកសប្បុរស និងធម៌ទាំងឡាយរបស់
ពួកអសប្បុរស នេះ ជាធម្មជាតឆ្ងាយក្រៃលែងណាស់ទី ៤ ម្នាលភិក្ខុទាំង-
ឡាយ ធម្មជាតឆ្ងាយក្រៃលែងណាស់ មាន ៤ យ៉ាងនេះឯង

ពពក (ឋិតនៅក្នុងទីឆ្ងាយ) ប្រឹថពី (ក៏ឋិតនៅ) ក្នុងទីឆ្ងាយក្ដី
ក្ដី (អ្នកប្រាជ្ញ ពោល) នូវត្រើយសមុទ្រនោះ ថាឆ្ងាយ
ព្រះអាទិត្យ រះឡើងអំពីទីណា ព្រះអាទិត្យ អស្តង្គតទៅក្នុងទី
ណា អ្នកប្រាជ្ញ ពោលនូវទីនោះ ថាជាទីឆ្ងាយក្រៃលែងអំពីទី
នោះទៀត បុគ្គលអ្នកសំដែង នូវធម៌របស់ពួកសប្បុរស និងធម៌
របស់ពួកអសប្បុរស រមែងមាន សមាគម របស់សប្បុរស
ទាំងឡាយ ឋិតនៅដរាបណា (បុគ្គលអ្នកសំដែង) ក៏រមែង
មាន ដរាបនោះ សមាគម របស់អសប្បុរសទាំងឡាយ
រមែងសាបសូន្យទៅឆាប់រហ័ស ព្រោះហេតុនោះ ធម៌របស់
សប្បុរសទាំងឡាយ ឆ្ងាយអំពីអសប្បុរសទាំងឡាយ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ កុសលាកុសលា សាវជ្ជានវជ្ជា ហីនប្បណីតា កណ្ហ-សុក្កសប្បដិភាគា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។

(៧០៤) ន វត្តព្វំ បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អារាមរោបា វនរោបា យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បរិភោគ-មយំ បុញ្ញំ វឌ្ឍតីតិ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលមិនគួរនិយាយថា ពួកធម៌ ជាកុសលនិងអកុសល មានទោសនិងមិនមានទោស ថោកទាបនិងឧត្តម មានចំណែកខ្មៅនិងចំណែកស មកកាន់ការចំពោះមុខទេ ។

(៧០៤) បុគ្គលមិនគួរនិយាយថា បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ តែក្រែងមានព្រះភាគ ទ្រង់ត្រាស់ថា

ជនទាំងឡាយណា ជាអ្នកដាំសួនច្បារ អ្នកដាំដើមឈើ អ្នកធ្វើស្ពាន ជនទាំងឡាយណា ឲ្យទាន ជាក់ទានទឹកផង អណ្តូងទឹកផង ទីសំណាក់អាស្រ័យផង បុណ្យ តែងចម្រើនដល់ជនទាំងនោះ ទាំងថ្ងៃទាំងយប់ សព្វកាល ជនទាំងនោះ ជាអ្នកតាំងនៅក្នុងធម៌ បរិបូណ៌ដោយសីល តែងទៅកាន់ឋានសួគ៌

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើន ។

(៧០៨) ន វត្តព្វំ បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ចត្តារោមេ ភិក្ខវេ បុញ្ញាភិសន្ទា កុសលាភិសន្ទា សុខស្សាហារា សោវគ្គិកា សុខវិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ យស្ស ភិក្ខវេ ភិក្ខុ ចីវរំ បរិភុញ្ជមានោ អប្បមាណំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ អប្បមាណោ តស្ស បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ យស្ស ភិក្ខវេ ភិក្ខុ បិណ្ឌបាតំ បរិភុញ្ជមានោ ។បេ។ សេនាសនំ បរិភុញ្ជមានោ ។បេ។ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បរិភុញ្ជមានោ អប្បមាណំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ អប្បមាណោ តស្ស បុញ្ញាភិសន្ទោ កុសលាភិសន្ទោ

(៧០៨) បុគ្គលមិនគួរនិយាយថា បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឡើង ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អភិសន្ទនៃបុណ្យ អភិសន្ទនៃកុសល ៤ យ៉ាងនេះ នាំមកនូវសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីឲ្យនូវអវយវៈដ៏ប្រសើរក្រៃលែង មានវិបាកជាសុខ ប្រព្រឹត្តទៅ ដើម្បីឋានសួគ៌ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីគាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ អភិសន្ទនៃបុណ្យ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ បរិភោគ (ប្រើប្រាស់) ចីវរ របស់ទាយកណា ហើយចូលកាន់ចេតោសមាធិ មានប្រមាណមិនបាន អភិសន្ទនៃបុណ្យ អភិសន្ទនៃកុសល នាំមកនូវសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីឲ្យនូវអវយវៈដ៏ប្រសើរក្រៃលែង មានវិបាកជាសុខ ប្រព្រឹត្តទៅ ដើម្បីឋានសួគ៌ មានប្រមាណមិនបាន រមែងប្រព្រឹត្តទៅ ដើម្បី សេចក្តីប្រាថ្នា ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីគាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទាយកនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ បរិភោគបិណ្ឌបាត ។បេ។ បរិភោគសេនាសនៈ ។បេ។ បរិភោគគិលានប្បច្ច័យភេសជ្ជបរិក្ខារ របស់ទាយកណា ហើយចូលកាន់ចេតោសមាធិ មានប្រមាណមិនបាន អភិសន្ទនៃបុណ្យ អភិសន្ទនៃកុសល

សុខស្សាហារកោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្ត-និកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ឯវមេវ ខោ ភិក្ខវេ ចត្តារោ បុញ្ញាភិសន្ទា កុសលាភិសន្ទា សុខស្សាហារកា សោវគ្គិកា សុខ-វិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។

[៧០៦] បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាម-ន្តា ។ ទាយកោ ទានំ ទេតិ បដិគ្គាហកោ បដិគ្គ-ហេត្វា ន បរិភុញ្ជតិ ឆឌ្ឌេតិ វិស្សជ្ជេតិ ហោតិ បុញ្ញន្តិ ។ អាមន្តា ។ ហញ្ចិ ទាយកោ ទានំ ទេតិ បដិគ្គាហកោ បដិគ្គហេត្វា ន បរិភុញ្ជតិ ឆឌ្ឌេតិ វិស្សជ្ជេតិ ហោតិ បុញ្ញំ នោ វត រេ វត្តព្វេ បរិភោគ-មយំ បុញ្ញំ វឌ្ឍតីតិ ។

[៧០៧] បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។ អាមន្តា ។

នាំមកនូវសេចក្ដីសុខ ប្រព្រឹត្តទៅ ដើម្បីឲ្យនូវអាយតនៈដ៏ប្រសើរក្រៃលែង មានវិបាកជាសុខ ប្រព្រឹត្តទៅ ដើម្បីឋានសួគ៌ មានប្រមាណមិនបាន រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីប្រាថ្នា ដើម្បីសេចក្ដីរីករាយ ដើម្បីសេចក្ដីគាប់ចិត្ត ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទាយកនោះ ម្នាលភិក្ខុទាំងឡាយ អភិសន្ទនៃបុណ្យ អភិសន្ទនៃកុសល ៤ យ៉ាងនេះឯង នាំមកនូវសេចក្ដីសុខ ប្រព្រឹត្តទៅ ដើម្បីឲ្យ នូវអាយតនៈដ៏ប្រសើរក្រៃលែង មានវិបាកជាសុខ ប្រព្រឹត្តទៅដើម្បីឋានសួគ៌ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីប្រាថ្នា ដើម្បីសេចក្ដីរីករាយ ដើម្បីសេចក្ដីគាប់ចិត្ត ដើម្បីប្រ-យោជន៍ ដើម្បីសេចក្ដីសុខ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើន ។

(៧០៦) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។ ទាយកឲ្យទាន បដិគ្គាហកៈទទួលហើយ មិនបរិភោគ លះបង់ចោល បុណ្យ រមែងមានឬ ។ អើ ។ បើទាយកឲ្យទាន បដិគ្គាហកៈទទួលហើយ មិនបរិភោគ លះបង់ចោល បុណ្យ រមែងមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនទេ ។

(៧០៧) បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនឬ ។ អើ ។

ទាយកោ ទានំ ទេតិ បដិគ្គាហកោ បដិគ្គហិតេ រាជានោ វា ហរន្តិ ចោរា វា ហរន្តិ អគ្គិ វា ឌហតិ ឧទកំ វា វហតិ អប្បិយា វា ទាយាទា ហរន្តិ ហោតិ បុញ្ញន្តិ ។ អាមន្តា ។ ហញ្ចិ ទាយកោ ទានំ ទេតិ បដិគ្គាហកោ បដិគ្គហិតេ រាជានោ វា ហរន្តិ ចោរា វា ហរន្តិ អគ្គិ វា ឌហតិ ឧទកំ វា វហតិ អប្បិយា វា ទាយាទា ហរន្តិ ហោតិ បុញ្ញំ តេន វត រេ វត្តព្វេ បរិភោគមយំ បុញ្ញំ វឌ្ឍតីតិ ។

បរិភោគមយបុញ្ញកថា ។

ឥតោ ទិន្នកថា

(៧០៨) ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។ អាមន្តា ។ ឥតោ ចីវរំ ទេន្តិ តំ ចីវរំ តត្ថ បរិភុញ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥតោ បិណ្ឌបាតំ ទេន្តិ ឥតោ សេនាសនំ ទេន្តិ ឥតោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេន្តិ ឥតោ ខាទនីយំ ទេន្តិ ឥតោ ភោជនីយំ ទេន្តិ ឥតោ បានីយំ ទេន្តិ

ទាយកឲ្យទាន កាលបើបដិគ្គាហកៈ ទទួលហើយ ពួកស្ដេចយកទៅក្ដី ពួកចោរលួចយកទៅក្ដី ភ្លើងឆេះក្ដី ទឹកបណ្ដែតទៅក្ដី ពួកទាយាទៈមិនជាទីស្រឡាញ់យកទៅក្ដី បុណ្យ រមែងមានឬ ។ អើ ។ បើទាយកឲ្យទាន កាលបើបដិគ្គាហកៈ ទទួលហើយ ពួកស្ដេចយកទៅក្ដី ពួកចោរលួចទៅក្ដី ភ្លើងឆេះក្ដី ទឹកបណ្ដែតទៅក្ដី ពួកទាយាទៈមិនជាទីស្រឡាញ់យកទៅក្ដី បុណ្យ រមែងមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរនិយាយថា បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើនទេ ។

ចប់ បរិភោគមយបុញ្ញកថា ។

ឥតោទិន្នកថា

(៧០៨) ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះ បានដែរឬ ។ អើ ។ ញាតិទាំងឡាយ ឲ្យចីវរ អំពីមនុស្សលោកនេះ ពួកប្រេតបរិភោគចីវរនោះ ក្នុងបេតវិស័យនោះបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកញាតិ ឲ្យបិណ្ឌបាត អំពីមនុស្សលោកនេះ ឲ្យសេនាសនៈ អំពីមនុស្សលោកនេះ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ អំពីមនុស្សលោកនេះ ឲ្យវត្ថុគួរទំពាស៊ី អំពីមនុស្សលោកនេះ ឲ្យវត្ថុគួរបរិភោគ អំពីមនុស្សលោកនេះ ឲ្យទឹកគួរផឹក អំពីមនុស្សលោកនេះ

តំ នាដីយំ តត្ថ បរិភុញ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧០៩) ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។ អាមន្តា ។ អញ្ញោ អញ្ញស្ស ការកោ បរកតំ សុខទុក្ខំ អញ្ញោ ករោតិ អញ្ញោ បដិសំវេទេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧១០) ន វត្តព្វំ ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។ អាមន្តា ។ ននុ បេតា អត្តនោ អត្ថាយ ទានំ ទេន្តំ អនុមោទន្តិ ចិត្តំ បសាទេន្តិ បីតឹ ឧប្បាទេន្តិ សោមនស្សំ បដិលភន្តីតិ ។ អាមន្តា ។ ហញ្ចិ បេតា អត្តនោ អត្ថាយ ទានំ ទេន្តំ អនុមោទន្តិ ចិត្តំ បសាទេន្តិ បីតឹ ឧប្បាទេន្តិ សោមនស្សំ បដិលភន្តិ តេន វត រេ វត្តព្វេ ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។

ពួកប្រេត បរិភោគទឹកក្នុងទីកនោះ ក្នុងបេតវិស័យនោះបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧០៩) ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបានឬ ។ អើ ។ បុគ្គលដទៃ ជាអ្នកធ្វើនូវបុគ្គលដទៃ សុខទុក្ខដែលបុគ្គលដទៃធ្វើ បុគ្គលដទៃ ធ្វើ បុគ្គលដទៃ ទទួលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧១០) បុគ្គលមិនគួរនិយាយថា ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះទេឬ ។ អើ ។ ក្រែងពួកប្រេត អនុមោទនា នូវទានដែលញាតិកាលឲ្យ ដើម្បីប្រយោជន៍ខ្លួន ហើយញុំាងចិត្តឲ្យជ្រះថ្លា ញុំាងបីតិឲ្យកើតឡើង បានចំពោះនូវសោមនស្សឬ ។ អើ ។ បើពួកប្រេត អនុមោទនា នូវទាន ដែលញាតិកាលឲ្យ ដើម្បីប្រយោជន៍ខ្លួន ហើយញុំាងចិត្តឲ្យជ្រះថ្លា ញុំាងបីតិឲ្យកើតឡើង បានចំពោះនូវសោមនស្ស ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបាន ។

(៧១១) ន វត្តព្វំ ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។

អាមន្តា ។ ននុ វុត្តំ ភគវតា

ឧណ្ណតេ ឧទកំ វុដ្ឋំ យថា និន្នំ បវត្តតិ

ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ

យថា វារិវហា បូរា បរិបូរេន្តិ សាគរំ

ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ

ន ហិ តត្ថ កសី អត្ថិ គោរក្ខេត្ថ ន វិជ្ជតិ

វណិជ្ជា តាទិសី នត្ថិ ហិរញ្ញេន កយាកយំ

ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហិំ

(៧១១) បុគ្គលមិនគួរនិយាយថា ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ទឹកភ្លៀង ដែលមហាមេឃបង្អុរចុះហើយ ក្នុងទីទួល រមែងហូរទៅកាន់ទីទាប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ អំពីលោកនេះ ក៏រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះឯង ផ្លូវទឹកដ៏ពេញ រមែងញុំាងសាគរគឺសមុទ្រ ឲ្យពេញប្រៀប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ អំពីមនុស្សលោកនេះ ក៏រមែងសម្រេចផល ដល់ប្រេតទាំង-ឡាយ ដូច្នោះឯង ការភ្ជួរស្រែ ក៏មិនមាន ក្នុងបេតវិស័យនោះ ការរក្សាគោ ក៏មិនមាន ក្នុងបេតវិស័យនោះ ការជួញប្រែជាហេតុបានទូវសម្បត្តិ ប្រាកដដូច្នោះ ក៏មិនមាន ការលក់ទិញ ផ្លាស់ប្តូរដោយប្រាក់ ក៏មិនមាន ពួកប្រេតកាលធ្វើកាលកិរិយាទៅកើត ក្នុងបេតវិស័យនោះ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបាន

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ឥតោ ទិន្នេន តត្ថ យាបេតីតិ ។

(៧១៦) ន វត្តព្វំ ឥតោ ទិន្នេន តត្ថ យាបេតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិមានិ ភិក្ខវេ ឋានានិ សម្បស្សន្តា មាតាបិតរោ បុត្តំ ឥច្ឆន្តិ កុលេ ជាយមានំ ។ កតមានិ បញ្ច ។ ភតោ វា នោ ភរិស្សតិ កិច្ចំ វា នោ ករិស្សតិ កុលវំសោ ចិរំ ឋស្សតិ ទាយជ្ជំ បដិបជ្ជតិ អថ វា បន បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សតីតិ ។ ឥមានិ ខោ ភិក្ខវេ បញ្ច ឋានានិ សម្បស្សន្តា មាតាបិតរោ បុត្តំ ឥច្ឆន្តិ កុលេ ជាយមានន្តិ

បញ្ច ឋានានិ សម្បស្សំ បុត្តំ ឥច្ឆន្តិ បណ្ឌិតា
ភតោ វា នោ ភរិស្សតិ កិច្ចំ វា នោ ករិស្សតិ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបាន ។

(៧១៦) បុគ្គលមិនគួរនិយាយថា ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មាតានិងបិតា កាលឃើញច្បាស់ នូវស្ថាន ៥ យ៉ាងនេះ ទើបប្រាថ្នាបុត្រ ដែលកើតក្នុងត្រកូល ។ ស្ថានទាំង ៥ យ៉ាង តើដូចម្តេច ។ គឺបុត្រដែលយើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ ១ នឹងធ្វើកិច្ចរបស់យើង ១ វង្សត្រកូលនឹងឋិតនៅអស់កាលយូរ ១ បុត្រនឹងទទួលគ្រប់គ្រងមត៌ក ១ មួយទៀត បុត្រនឹងឧទ្ទិសបញ្ជូនទក្ខិណាទានដល់យើង ដែលធ្វើកាលកិរិយាទៅកើត ក្នុងបរលោកនាយ ១ ម្នាលភិក្ខុទាំងឡាយ មាតានិងបិតា កាលឃើញច្បាស់ នូវស្ថានទាំង ៥ យ៉ាងនេះឯង ទើបប្រាថ្នាបុត្រដែលកើត ក្នុងត្រកូល

បណ្ឌិតទាំងឡាយ កាលបើឃើញច្បាស់ នូវស្ថាន ទាំង ៥
យ៉ាងហើយ ទើបប្រាថ្នាបុត្រ (ដោយគិតថា) បុត្រដែលយើង
ចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ ១ នឹងធ្វើកិច្ចរបស់យើង ១

កុលវំសោ ចិរំ តិដ្ឋេ   ញាយរដ្ឋំ បដិបជ្ជតិ

អជ ភ បន បេតានំ   ឧក្កំសំ អនុប្បទស្សតិ

ហានានេតានំ សម្បស្សំ   បុត្តំ ឥច្ឆន្តិ បណ្ឌិតា

ឥណ្ហា សន្តោ សប្បុរិសា   កតញ្ញូ កតវេទិនោ

ភរន្តិ មាតាបិតរោ   បុព្វេ កតមនុស្សរំ

ករោន្តិ តេសំ កិច្ចានិ   យថា តំ បុព្វការិនំ

ឱវាទការី ភតបោសី   កុលវំសំ អហាបយំ

សទ្ធោ សីលេន សម្បន្នោ បុត្តោ ហោតិ បសំសិយោតិ

អត្ថោ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ឥតោ

និន្ទេន តត្ថ យាបេន្តីតិ ។

ឥតោ ទិន្នកថា ។

វង្សត្រកូលតៗទៅអស់កាលយូរ ១ បុត្រនឹងទទួលគ្រប់គ្រងមត៌ក ១ មួយទៀត បុត្រនឹងឧទ្ទិសបញ្ជូនទក្ខិណាទាន ដល់យើង ដែលធ្វើកាលកិរិយាទៅកើត ក្នុងបរលោក ១ បណ្ឌិតទាំងឡាយ កាលបើឃើញច្បាស់ នូវស្ថានទាំង ៥ យ៉ាងនេះឯង ទើបប្រាថ្នាបុត្រ ព្រោះហេតុនោះ សប្បុរសទាំងឡាយ មានចិត្តស្ងប់ហើយ អ្នកដឹងនូវឧបការគុណ ដែលគេធ្វើហើយប្រាកដ កាលរឭកឃើញ នូវឧបការៈគុណដែលមាតាបិតាធ្វើហើយ ក្នុងកាលមុន រមែងចិញ្ចឹម មាតាបិតា ធ្វើកិច្ចទាំងឡាយ ដល់មាតានិងបិតាទាំងនោះ ដែលជាបុព្វការី ដោយពិត បុត្រជាអ្នកធ្វើតាមឱវាទ អ្នកចិញ្ចឹមមាតាបិតា ដែលចិញ្ចឹមខ្លួន ញ៉ាំងវង្សត្រកូល មិនឲ្យវិនាស ជាអ្នកមានសទ្ធា បរិបូណ៌ដោយសីល អ្នកប្រាជ្ញ រមែងសរសើរ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកប្រេត ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងវេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះ ។

ចប់ ឥតោទិន្នកថា ។

បឋវី កម្មវិបាកោតិកថា

(៧១៣) បឋវី កម្មវិបាកោតិ ។ អាមន្តា ។ សុខវេទនិយា ទុក្ខវេទនិយា អទុក្ខមសុខវេទនិយា សុខាយ វេទនាយ សម្បយុត្តា ទុក្ខាយ វេទនាយ សម្បយុត្តា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ផស្សេន សម្បយុត្តា វេទនាយ សម្បយុត្តា សញ្ញាយ សម្បយុត្តា ចេតនាយ សម្បយុត្តា ចិត្តេន សម្បយុត្តា សារម្មណា អត្ថិ តាយ អាវដ្ដនា អាភោគោ សមន្នាហារោ មនសិការោ ចេតនា បត្ថនា បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន សុខវេទនិយា ន ទុក្ខវេទនិយា ន អទុក្ខមសុខវេទនិយា ន សុខាយ វេទនាយ សម្បយុត្តា ន ទុក្ខាយ វេទនាយ សម្បយុត្តា ន អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ន ផស្សេន សម្បយុត្តា ន វេទនាយ សម្បយុត្តា ន សញ្ញាយ សម្បយុត្តា ន ចេតនាយ សម្បយុត្តា ន ចិត្តេន សម្បយុត្តា អនារម្មណា នត្ថិ តាយ អាវដ្ដនា អាភោគោ សមន្នាហារោ មនសិការោ

បឋវីកម្មវិបាកោតិកថា

(៧១៣) ប្រឹថពី ជាវិបាក (ផល) នៃកម្ម ។ អើ ។ ប្រឹថពី គួរដល់ការនៃសុខ គួរដល់ការនៃទុក្ខ គួរដល់ការនៃអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាធម្មជាតប្រកបដោយអារម្មណ៍ ការនឹកនា ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃប្រឹថពីនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងប្រឹថពី មិនគួរដល់ការនៃសុខ មិនគួរដល់ការនៃទុក្ខ មិនគួរដល់ការនៃអារម្មណ៍ មិនជាទុក្ខ មិនជាសុខ មិនប្រកបដោយសុខវេទនា មិនប្រកបដោយទុក្ខវេទនា មិនប្រកបដោយអទុក្ខមសុខវេទនា មិនប្រកបដោយផស្សៈ មិនប្រកបដោយវេទនា មិនប្រកបដោយសញ្ញា មិនប្រកបដោយចេតនា មិនប្រកបដោយចិត្ត ជាធម្មជាតមិនមានអារម្មណ៍ ការនឹកនា ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត

ចេតនា បត្ថនា បណិធិ ។ អាមន្តា ។ ហញ្ចិ ន សុខវេទនិយា ន ទុក្ខវេទនិយា ។បេ។ អនា-រម្មណា នត្ថិ តាយ អាវដ្ដនា ។បេ។ បណិធិ នោ វត រេ វត្តព្វេ បឋវី កម្មវិបាកោតិ ។

(៧១៦) ផស្សោ កម្មវិបាកោ ផស្សោ សុខ-វេទនិយោ ទុក្ខវេទនិយោ អទុក្ខមសុខវេទនិយោ សុខាយ វេទនាយ សម្បយុត្តោ ទុក្ខាយ ។បេ។ អទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ផស្សេន សម្បយុត្តោ វេទនាយ សម្បយុត្តោ សញ្ញាយ សម្ប-យុត្តោ ចេតនាយ សម្បយុត្តោ ចិត្តេន សម្បយុត្តោ សារម្មណោ អត្ថិ តស្ស អាវដ្ដនា ។បេ។ បណិ-ធិ ។ អាមន្តា ។ បឋវី កម្មវិបាកោ បឋវី សុខវេទនិយា ទុក្ខវេទនិយា អទុក្ខមសុខវេទនិយា សុខាយ វេទនាយ សម្បយុត្តា ទុក្ខាយ វេទនាយ សម្បយុត្តា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ផស្សេន សម្បយុត្តា វេទនាយ សម្បយុត្តា សញ្ញាយ

ការនឹក ការប្រាថ្នា ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃប្រឹថពីនោះ មិនមានទេឬ ។ អើ ។ បើប្រឹថពី មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។បេ។ ជាធម្មជាតមិនមានអារម្មណ៍ ការនឹក ។បេ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃប្រឹថពីនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ប្រឹថពី ជាវិបាកនៃកម្មទេ ។

(៧១៦) ផស្សៈ ជាវិបាកនៃកម្ម ផស្សៈ គួរដល់ការរងសុខ គួរដល់ការរងទុក្ខ គួរដល់ការរងអារម្មណ៍ មិនជាទុក្ខមិនជាសុខ ប្រកបដោយសុខវេទនា ដោយទុក្ខវេទនា ។បេ។ ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាសភាវៈប្រកបដោយអារម្មណ៍ ការនឹកនា ។បេ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃផស្សៈនោះ មានដែរឬ ។ អើ ។ ប្រឹថពី ជាវិបាកនៃកម្ម ប្រឹថពី គួរដល់ការរងសុខ គួរដល់ការរងទុក្ខ គួរដល់ការរងអារម្មណ៍ មិនជាទុក្ខមិនជាសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខម-សុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា

សម្បយុត្តា ចេតនាយ សម្បយុត្តា ចិត្តេន សម្បយុត្តា សារម្មណា អត្ថិ តាយ អាវដ្ដនា អាភោគោ សមន្នាហារោ មនសិការោ ចេតនា បត្ថនា បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧១៥) បឋវី កម្មវិបាកោ បឋវី ន សុខវេទនិយា ន ទុក្ខវេទនិយា ។ បេ ។ អនារម្មណា នត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ផស្សោ កម្មវិបាកោ ផស្សោ ន សុខវេទនិយោ ន ទុក្ខវេទនិយោ ។ បេ ។ អនារម្មណោ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧១៦) បឋវី កម្មវិបាកោតិ ។ អាមន្តា ។ បឋវី ឧក្ខេបនិក្ខេបូបគា ឆេទនភេទនូបគាតិ ។ អាមន្តា ។ កម្មវិបាកោ ឧក្ខេបនិក្ខេបូបគោ ឆេទនភេទនូបគោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧១៧) លព្ភា បឋវី កេតុំ វិក្កេតុំ អាឋបេតុំ ឱចិនិតុំ វិចិនិតុន្តិ ។ អាមន្តា ។ លព្ភា កម្មវិបាកោ

ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាធម្មជាតិប្រកបដោយអារម្មណ៍ ការនឹកនា ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃប្រឹថពីនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧១៥) ប្រឹថពី ជាវិបាកនៃកម្ម ប្រឹថពី មិនគួរដល់ការនៃសុខ មិនគួរដល់ការនៃទុក្ខ ។ បេ ។ ជាធម្មជាតិមិនមានអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃប្រឹថពីនោះ មិនមានទេឬ ។ អើ ។ ផស្សៈ ជាវិបាកនៃកម្ម ផស្សៈ មិនគួរដល់ការនៃសុខ មិនគួរដល់ការនៃទុក្ខ ។ បេ ។ ជាសភាវៈមិនមានអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧១៦) ប្រឹថពី ជាវិបាកនៃកម្មឬ ។ អើ ។ ប្រឹថពី គួរដល់ការលើកឡើងនិងការដាក់ចុះ គួរដល់ការដាច់បង់និងការបែកធ្លាយដែរឬ ។ អើ ។ វិបាកនៃកម្ម គួរដល់ការលើកឡើងនិងការដាក់ចុះ គួរដល់ការដាច់បង់និងការបែកធ្លាយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧១៧) ប្រឹថពី បុគ្គលគប្បីបាន ដើម្បីទិញ ដើម្បីលក់ ដើម្បីតាំងទុក ដើម្បីសន្សំទុក ដើម្បីជ្រើសរើសដែរឬ ។ អើ ។ វិបាកនៃកម្ម

កេតុំ វិក្កេតុំ អាវបេតុំ ឧច្ចិនិតុំ វិចិនិតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧១៨) បថវី បរេសំ សាធារណាតិ ។ អាមន្តា ។ កម្មវិបាកោ បរេសំ សាធារណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧១៩) កម្មវិបាកោ បរេសំ សាធារណោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អសាធារណមញ្ញេសំ អចោរាហរណោ និធិ

កយិរាថ មច្ចោ បុញ្ញានិ ស វេ សុចរិតំ ចរេតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ កម្មវិបាកោ បរេសំ សាធារណោតិ ។

(៧២០) បថវី កម្មវិបាកោតិ ។ អាមន្តា ។ បឋមំ បថវី សណ្ឋាតិ បច្ឆា សត្តា ឧប្បជ្ជន្តីតិ ។ អាមន្តា ។ បឋមំ វិបាកោ ឧប្បជ្ជតិ បច្ឆា វិបាកប្បដិលាភាយ កម្មំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧២១) បថវី សព្វសត្តានំ កម្មវិបាកោតិ ។ អាមន្តា ។ សព្វេ សត្តា បថវី បរិភុញ្ជន្តីតិ ។ ន ហេវំ វត្តព្វេ

បុគ្គលគប្បីបាន ដើម្បីទិញ ដើម្បីលក់ ដើម្បីតំកល់ទុក ដើម្បីសន្សំទុក ដើម្បីជ្រើសរើសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧១៨) ប្រឹថពី ជាសាធារណៈ ដល់ពួកសត្វដទៃដែរឬ ។ អើ ។ វិបាកនៃកម្ម ជាសាធារណៈ ដល់ពួកសត្វដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧១៩) វិបាកនៃកម្ម ជាសាធារណៈ ដល់ពួកសត្វដទៃដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

កំណប់ទ្រព្យគឺបុណ្យ មិនជាសាធារណៈ ដល់ពួកសត្វដទៃ

ទេ ចោរលួចយកមិនបានទេ សត្វនោះ គប្បីធ្វើបុណ្យទាំង-

ឡាយ គប្បីប្រព្រឹត្តធម៌នោះ ឲ្យសុចរិតដោយពិត

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា វិបាកនៃកម្ម ជាសាធារណៈ ដល់ពួកសត្វដទៃទេ ។

(៧២០) ប្រឹថពី ជាវិបាកនៃកម្មឬ ។ អើ ។ ប្រឹថពី តាំងនៅមុន ហើយទើបសត្វទាំងឡាយ កើតឡើងជាខាងក្រោយឬ ។ អើ ។ វិបាក កើតឡើងមុន ទើបសត្វទាំងឡាយ ធ្វើកម្ម ដើម្បីបាននូវវិបាកក្នុងកាលជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧២១) ប្រឹថពី ជាវិបាកនៃកម្ម របស់សត្វទាំងអស់ឬ ។ អើ ។ សត្វទាំងអស់ បរិភោគប្រឹថពីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ

។ បេ ។ សព្វេ សត្តា បឋវី បរិភុញ្ជន្តីតិ ។ អាមន្តា ។ អត្ថិ កេចិ បឋវី បរិភុញ្ជិត្វា បរិនិព្វាយន្តីតិ ។ អាមន្តា ។ អត្ថិ កេចិ កម្មវិបាកំ អខេបេត្វា បរិនិព្វាយន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧៦២) បឋវី ចក្កវត្តិសត្តស្ស កម្មវិបាកោតិ ។ អាមន្តា ។ អញ្ញេ សត្តា បឋវី បរិភុញ្ជន្តីតិ ។ អាមន្តា ។ ចក្កវត្តិសត្តស្ស កម្មវិបាកំ អញ្ញេ សត្តា បរិភុញ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្កវត្តិសត្តស្ស កម្មវិបាកំ អញ្ញេ សត្តា បរិភុញ្ជន្តីតិ ។ អាមន្តា ។ ចក្កវត្តិសត្តស្ស ផស្សំ វេទនំ សញ្ញំ ចេតនំ ចិត្តំ សទ្ធំ វីរិយំ សតឹ សមាធឹ បញ្ញំ អញ្ញេ សត្តា បរិភុញ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧៦៣) ន វត្តព្វំ បឋវី កម្មវិបាកោតិ ។ អាមន្តា ។ ននុ អត្ថិ ឥស្សរិយសំវត្តនិយំ កម្មំ អធិបច្ចសំវត្តនិយំ កម្មន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ ឥស្សរិយសំវត្តនិយំ កម្មំ អធិបច្ចសំវត្តនិយំ កម្មំ តេន វត រេ វត្តព្វេ បឋវី កម្មវិបាកោតិ ។

បឋវី កម្មវិបាកកថា ។

។ បេ ។ សត្វទាំងអស់ បរិភោគប្រឹថពីឬ ។ អើ ។ សត្វពួកខ្លះ បរិភោគប្រឹថពី ហើយរលត់ទៅ មានដែរឬ ។ អើ ។ សត្វពួកខ្លះ ញុំាងវិបាកនៃកម្មមិនឲ្យអស់ទៅ ហើយរលត់ទៅ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧៦២) ប្រឹថពី ជាវិបាកនៃកម្ម របស់សត្វជាចក្រពត្តិឬ ។ អើ ។ ពួកសត្វដទៃ បរិភោគប្រឹថពីឬ ។ អើ ។ ពួកសត្វដទៃ បរិភោគវិបាកនៃកម្ម របស់សត្វជាចក្រពត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វដទៃ បរិភោគវិបាកនៃកម្ម របស់សត្វជាចក្រពត្តិឬ ។ អើ ។ ពួកសត្វដទៃ បរិភោគផស្សៈ វេទនា សញ្ញា ចេតនា ចិត្ត សទ្ធា វីរិយៈ សតិ សមាធិ បញ្ញា របស់សត្វជាចក្រពត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧៦៣) បុគ្គលមិនគួរនិយាយថា ប្រឹថពី ជាវិបាកនៃកម្មទេឬ ។ អើ ។ ក្រែងកម្មដែលគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាឥស្សរៈ កម្មដែលគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាអធិបតី មានដែរឬ ។ អើ ។ បើកម្មដែលគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាឥស្សរៈ កម្មដែលគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាអធិបតី រមែងមាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ប្រឹថពី ជាវិបាកនៃកម្ម ។

ចប់ បឋវីកម្មវិបាកកថា ។

ជរាមរណំ វិបាកោតិកថា

(៧៦៤) ជរាមរណំ វិបាកោតិ ។ អាមន្តា ។ សុខ- វេទនិយំ ទុក្ខវេទនិយំ អទុក្ខមសុខវេទនិយំ សុខាយ វេទនាយ សម្បយុត្តំ ទុក្ខាយ វេទនាយ សម្បយុត្តំ អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ផស្សេន សម្ប- យុត្តំ វេទនាយ សម្បយុត្តំ សញ្ញាយ សម្បយុត្តំ ចេត- នាយ សម្បយុត្តំ ចិត្តេន សម្បយុត្តំ សារម្មណំ អត្ថិ តស្ស អាវដ្ដនា អាភោគោ សមន្នាហារោ មនសិការោ ចេតនា បត្ថនា បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន សុខវេទនិយំ ន ទុក្ខវេទនិយំ ។ បេ ។ អនារម្មណំ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ ន សុខវេទនិយំ ន ទុក្ខវេទនិយំ ។ បេ ។ អនារម្មណំ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធិ នោ ច វត រេ វត្តព្វេ ជរាមរណំ វិបាកោតិ ។

ជរាមរណវិបាកោតិកថា

(៧៦៤) ជរានិងមរណៈ ជាវិបាកឬ ។ អើ ។ ជរានិងមរណៈ គួរដល់ការនៃសុខ គួរដល់ការនៃទុក្ខ គួរដល់ការនៃអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាធម្មជាតប្រកបដោយអារម្មណ៍ ការនឹកនា ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃជរានិងមរណៈនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងជរានិងមរណៈ មិនគួរដល់ការនៃសុខ មិនគួរដល់ការនៃទុក្ខ ។ បេ ។ ជាធម្មជាតមិនមានអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃជរានិងមរណៈនោះ មិនមានទេឬ ។ អើ ។ បើជរានិងមរណៈ មិនគួរដល់ការនៃសុខ មិនគួរដល់ការនៃទុក្ខ ។ បេ ។ ជាធម្មជាតមិនមានអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃជរានិងមរណៈនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ជរានិងមរណៈ ជាវិបាកទេ ។

ជរាមរណំ វិបាកោតិកថា

[៧៦៥] ផស្សោ វិបាកោ ផស្សោ សុខវេទនិយោ ទុក្ខវេទនិយោ ។ បេ ។ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ ។ អាមន្តា ។ ជរាមរណំ វិបាកោ ជរាមរណំ សុខវេទនិយំ ទុក្ខវេទនិយំ ។ បេ ។ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៦៦] ជរាមរណំ វិបាកោ ជរាមរណំ ន សុខវេទនិយំ ន ទុក្ខវេទនិយំ ។ បេ ។ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ ។ អាម-ន្តា ។ ផស្សោ វិបាកោ ផស្សោ ន សុខវេទនិយោ ន ទុក្ខវេទនិយោ ។ បេ ។ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៦៧] អកុសលានំ ធម្មានំ ជរាមរណំ អកុ-សលានំ ធម្មានំ វិបាកោតិ ។ អាមន្តា ។ កុសលានំ ធម្មានំ ជរាមរណំ កុសលានំ ធម្មានំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ជរាមរណកម្មវិបាកោតិកថា

(៧៦៥) ផស្សៈ ជាវិបាក ផស្សៈ គួរដល់ការនៃសុខ គួរដល់ការនៃទុក្ខ ។ បេ ។ ជាសភាវៈប្រកបដោយអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (ខួរសេចក្តីប្រាថ្នា) នៃផស្សៈនោះ មានដែរឬ ។ អើ ។ ជរានិងមរណៈ ជាវិបាក ជរានិងមរណៈ គួរដល់ការនៃសុខ គួរដល់ការនៃទុក្ខ ។ បេ ។ ជាធម្មជាតប្រកបដោយអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (ខួរសេចក្តីប្រាថ្នា) ជរានិងមរណៈនោះមានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ។

(៧៦៦) ជរានិងមរណៈ ជាវិបាក ជរានិងមរណៈ មិនគួរដល់ការនៃសុខ មិនគួរដល់ការនៃទុក្ខ ។ បេ ។ ជាធម្មជាតមិនមានអា-រម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (ខួរសេចក្តីប្រាថ្នា) នៃជរានិងមរណៈនោះ មិនមានទេឬ ។ អើ ។ ផស្សៈ ជាវិបាក ផស្សៈ មិនគួរដល់ការនៃសុខ មិនគួរដល់ការនៃទុក្ខ ។ បេ ។ ជាសភាវៈមិនមានអារម្មណ៍ ការនឹក ។ បេ ។ ការតាំងទុក (ខួរសេចក្តីប្រាថ្នា) នៃផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧៦៧) ជរានិងមរណៈ នៃពួកកុសលធម៌ ជាវិបាកនៃអកុ-សលធម៌ឬ ។ អើ ។ ជរានិងមរណៈ នៃពួកកុសលធម៌ ជាវិបាក នៃពួកកុសលធម៌ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧២៨) កុសលំ ធម្មំ ជានមានោ ន វត្តព្វំ កុសលំ ធម្មំ វិបាកោតិ ។ អាមន្តា ។ អកុសលំ ធម្មំ ជានមានោ ន វត្តព្វំ អកុសលំ ធម្មំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧២៩) កុសលំ ធម្មំ ជានមានោ អកុសលំ ធម្មំ វិបាកោតិ ។ អាមន្តា ។ អកុសលំ ធម្មំ ជានមានោ កុសលំ ធម្មំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧៣០) អកុសលំ ធម្មំ ជានមានោ ន វត្តព្វំ កុសលំ ធម្មំ វិបាកោតិ ។ អាមន្តា ។ កុសលំ ធម្មំ ជានមានោ ន វត្តព្វំ អកុសលំ ធម្មំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧៣១) កុសលញ្ច អកុសលញ្ច ធម្មំ ជានមានោ អកុសលំ ធម្មំ វិបាកោតិ ។ អាមន្តា ។ កុសលញ្ច អកុសលញ្ច ធម្មំ ជានមានោ កុសលំ ធម្មំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧២៨) ជនដឹងមរណៈ នៃពួកកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកកុសលធម៌ទេឬ ។ អើ ។ ជនដឹងមរណៈ នៃពួកអកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកអកុសលធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៧២៩) ជនដឹងមរណៈ នៃពួកកុសលធម៌ ជាវិបាក នៃពួកអកុសលធម៌ឬ ។ អើ ។ ជនដឹងមរណៈ នៃពួកអកុសលធម៌ ជាវិបាក នៃពួកកុសលធម៌ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៧៣០) ជនដឹងមរណៈ នៃពួកអកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកកុសលធម៌ទេឬ ។ អើ ។ ជនដឹងមរណៈ នៃពួកកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកអកុសលធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៧៣១) ជនដឹងមរណៈ នៃពួកកុសលធម៌ និងពួកអកុសលធម៌ ជាវិបាក នៃពួកអកុសលធម៌ឬ ។ អើ ។ ជនដឹងមរណៈ នៃពួកកុសលធម៌ និងពួកអកុសលធម៌ ជាវិបាក នៃពួកកុសលធម៌ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៧៣៦] កុសលានញ្ច អកុសលានញ្ច ធម្មានំ ជរាមរណំ ន វត្តព្វំ កុសលានំ ធម្មានំ វិបាកោតិ ។ អាមន្តា ។ កុសលានញ្ច អកុសលានញ្ច ធម្មានំ ជរាមរណំ ន វត្តព្វំ អកុសលានំ ធម្មានំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៧៣៧] ន វត្តព្វំ ជរាមរណំ វិបាកោតិ ។ អាមន្តា ។ ននុ អត្ថិ ទុព្វណ្ណសំវត្តនិយំ កម្មំ អប្បាយុកសំវត្តនិយំ កម្មន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ ទុព្វណ្ណសំវត្តនិយំ កម្មំ អប្បាយុកសំវត្តនិយំ កម្មំ តេន វត រេ វត្តព្វេ ជរាមរណំ វិបាកោតិ ។

ជរាមរណំ វិបាកោតិកថា ។

អរិយធម្មវិបាកកថា

[៧៣៨] នត្ថិ អរិយធម្មវិបាកោតិ ។ អាមន្តា ។ ននុ មហប្ផលំ សាមញ្ញំ មហប្ផលំ ព្រហ្មញ្ញន្តិ ។ អាមន្តា ។ ហញ្ចិ មហប្ផលំ សាមញ្ញំ មហប្ផលំ ព្រហ្មញ្ញំ នោ វត រេ វត្តព្វេ នត្ថិ អរិយធម្មវិបាកោតិ ។

[៧៣៩] នត្ថិ អរិយធម្មវិបាកោតិ ។ អាមន្តា ។

(៧៣៦) ជរានិងមរណៈ នៃពួកកុសលធម៌ និងពួកអកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកកុសលធម៌ទេឬ ។ អើ ។ ជរានិងមរណៈ នៃពួកកុសលធម៌ និងពួកអកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកអកុសលធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៧៣៧) បុគ្គលមិនគួរនិយាយថា ជរានិងមរណៈ ជាវិបាកទេឬ ។ អើ ។ ក្រែងកម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីពណ៌អាក្រក់ កម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីអាយុខ្លី មានដែរឬ ។ អើ ។ បើកម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីពណ៌អាក្រក់ កម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីអាយុខ្លី មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ជរានិងមរណៈ ជាវិបាក ។

ចប់ ជរាមរណវិបាកកថា ។

អរិយធម្មវិបាកកថា

(៧៣៨) វិបាកនៃអរិយធម៌ (មគ្គ) មិនមានទេឬ ។ អើ ។ ក្រែង សាមញ្ញៈ (មគ្គ) ជាផលដ៏ប្រសើរ ព្រហ្មញ្ញៈ ជាផលដ៏ប្រសើរឬ ។ អើ ។ បើសាមញ្ញៈ ជាផលដ៏ប្រសើរ ព្រហ្មញ្ញៈ ជាផលដ៏ប្រសើរ (រមែងមាន) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបាកនៃអរិយធម៌ មិនមានទេ ។

(៧៣៩) វិបាកនៃអរិយធម៌ មិនមានទេឬ ។ អើ ។

ននុ អត្ថិ សោតាបត្តិផលន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ សោតាបត្តិផលំ តេន វត រេ វត្តព្វេ នត្ថិ អរិយធម្មវិបាកោតិ ។ ននុ អត្ថិ សកទាគាមិផលំ ។បេ។ អនាគាមិផលំ ។បេ។ អរហត្តផលន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ អរហត្តផលំ តេន វត រេ វត្តព្វេ នត្ថិ អរិយធម្មវិបាកោតិ ។

[៧៣៦] សោតាបត្តិផលំ ន វិបាកោតិ ។ អាមន្តា ។ ទានផលំ ន វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។ សោតាបត្តិផលំ ន វិបាកោតិ ។ អាមន្តា ។ សីលផលំ ។បេ។ ភាវនាផលំ ន វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។ សកទាគាមិផលំ ។បេ។ អនាគាមិផលំ ។បេ។ អរហត្តផលំ ន វិបាកោតិ ។ អាមន្តា ។ ទានផលំ ន វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។ អរហត្តផលំ ន វិបាកោតិ ។ អាមន្តា ។ សីលផលំ ។បេ។ ភាវនាផលំ ន វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៧៣៧] ទានផលំ វិបាកោតិ ។ អាមន្តា ។ សោតាបត្តិផលំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

ក្រែងសោតាបត្តិផល មានឬ ។ អើ ។ បើសោតាបត្តិផល មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបាកនៃអរិយធម៌ មិនមានទេ ។ ក្រែងសកទាគាមិផល ។បេ។ អនាគាមិផល ។បេ។ អរហត្តផល មានឬ ។ អើ ។ បើ អរហត្តផល មាន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបាកនៃអរិយធម៌ មិនមានទេ ។

(៧៣៦) សោតាបត្តិផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃទាន មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សោតាបត្តិផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃសីល ។បេ។ ផលនៃភាវនា មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សកទាគាមិផល ។បេ។ អនាគាមិផល ។បេ។ អរហត្តផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃទាន មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរហត្តផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃសីល ។បេ។ ផលនៃភាវនា មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៧៣៧) ផលនៃទាន ជាវិបាកឬ ។ អើ ។ សោតាបត្តិផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ទានផលំ វិបាកោតិ ។ អាមន្តា ។ សកទាគាមិផលំ ។បេ។ អនាគាមិផលំ ។បេ។ អរហត្តផលំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។ សីលផលំ ។បេ។ ភាវនាផលំ វិបាកោតិ ។ អាមន្តា ។ សោតាបត្តិផលំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។ ភាវនាផលំ វិបាកោតិ ។ អាមន្តា ។ សកទាគាមិផលំ ។បេ។ អនាគាមិផលំ ។បេ។ អរហត្តផលំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧៣៨) កាមាវចរំ កុសលំ សវិបាកន្តិ ។ អាមន្តា ។ លោកុត្តរំ កុសលំ សវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ រូបាវចរំ កុសលំ ។បេ។ អរូបាវចរំ កុសលំ សវិបាកន្តិ ។ អាមន្តា ។ លោកុត្តរំ កុសលំ សវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧៣៩) លោកុត្តរំ កុសលំ អវិបាកន្តិ ។ អាមន្តា ។ កាមាវចរំ កុសលំ អវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ លោកុត្តរំ កុសលំ អវិបាកន្តិ ។ អាមន្តា ។ រូបាវចរំ ។បេ។ អរូបាវចរំ កុសលំ អវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

ផលនៃទាន ជាវិបាកឬ ។ អើ ។ សកទាគាមិផល ។បេ។ អនាគាមិផល ។បេ។ អរហត្តផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផលនៃសីល ។បេ។ ផលនៃភាវនា ជាវិបាកឬ ។ អើ ។ សោតាបត្តិផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ផលនៃភាវនា ជាវិបាកឬ ។ អើ ។ សកទាគាមិផល ។បេ។ អនាគាមិផល ។បេ។ អរហត្តផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៧៣៨) កាមាវចរកុសល ប្រកបដោយវិបាកឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបាវចរកុសល ។បេ។ អរូបាវចរកុសល ប្រកបដោយវិបាកឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៧៣៩) លោកុត្តរកុសល មិនមានវិបាកទេឬ ។ អើ ។ កាមាវចរកុសល មិនមានវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ លោកុត្តរកុសល មិនមានវិបាកទេឬ ។ អើ ។ រូបាវចរៈ ។បេ។ អរូបាវចរកុសល មិនមានវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៧៦០] កាមាវចរំ កុសលំ សវិបាកំ អាចយគាមីតិ ។ អាមន្តា ។ លោកុត្តរំ កុសលំ សវិបាកំ អាចយគាមីតិ ។ ន ហេវំ វត្តព្វេ ។បេ។ រូបាវចរំ ។បេ។ អរូបាវចរំ កុសលំ សវិបាកំ អាចយគាមីតិ ។ អាមន្តា ។ លោកុត្តរំ កុសលំ សវិបាកំ អាចយគាមីតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៧៦១] លោកុត្តរំ កុសលំ សវិបាកំ អបចយគាមីតិ ។ អាមន្តា ។ កាមាវចរំ កុសលំ សវិបាកំ អបចយគាមីតិ ។ ន ហេវំ វត្តព្វេ ។បេ។ លោកុត្តរំ កុសលំ សវិបាកំ អបចយគាមីតិ ។ អាមន្តា ។ រូបាវចរំ ។បេ។ អរូបាវចរំ កុសលំ សវិបាកំ អបចយគាមីតិ ។ ន ហេវំ វត្តព្វេ ។បេ។

អរិយធម្មវិបាកកថា ។

វិបាកោ វិបាកធម្មធម្មោតិកថា

[៧៦២] វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។

[៧៦០] កាមាវចរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងនៃវដ្ដឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងនៃវដ្ដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបាវចរៈ ។បេ។ អរូបាវចរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងនៃវដ្ដឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងនៃវដ្ដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៧៦១] លោកុត្តរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងនៃវដ្ដឬ ។ អើ ។ កាមាវចរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងនៃវដ្ដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ លោកុត្តរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងនៃវដ្ដឬ ។ អើ ។ រូបាវចរៈ ។បេ។ អរូបាវចរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងនៃវដ្ដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ អរិយធម្មវិបាកកថា ។

វិបាកវិបាកធម្មធម្មោតិកថា

[៧៦២] វិបាក ជាធម៌ដែលមានវិបាកជាប្រក្រតីឬ ។ អើ ។

តស្ស វិបាកោ វិបាកធម្មធម្មោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តស្ស វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ តស្ស តស្សេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧៦៣) វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ វិបាកោតិ វា វិបាកធម្មធម្មោតិ វា វិបាកធម្មធម្មោតិ វា វិបាកោតិ វា ឯសេ សេ ឯកដ្ឋេ សមេ សមភាគេ តជ្ជាតេតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧៦៤) វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ វិបាកោ ច វិបាកធម្មធម្មោ ច វិបាកធម្មធម្មោ ច វិបាកោ ច សហគតា សហជាតា សំសដ្ឋា សម្បយុត្តា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧៦៥) វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ តញ្ញេវ អកុសលំ សោ អកុសលស្ស វិបាកោ តញ្ញេវ កុសលំ សោ កុសលស្ស វិបាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

វិបាក នៃធម៌ដែលមានវិបាកជាប្រក្រតីនោះ ជាធម៌មានវិបាកជាប្រក្រតីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិបាក នៃធម៌ដែលមានវិបាកជាប្រក្រតីនោះ ជាធម៌មានវិបាកជាប្រក្រតីឬ ។ អើ ។ ការធ្វើនូវទីបំផុត នៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្ដៈ មិនមាន ការរលត់នូវអនុបាទា មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧៦៣) វិបាក ជាធម៌ដែលមានវិបាកជាប្រក្រតីឬ ។ អើ ។ ធម៌ថាវិបាកក្តី ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មានវិបាកជាប្រក្រតីក្តី វិបាកក្តី នុ៎ះជាធម៌កាន់ទៅជាមួយគ្នា ស្មើគ្នា មានចំណែកស្មើ កើតជាមួយនឹងធម៌នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧៦៤) វិបាក ជាធម៌មានវិបាកជាប្រក្រតីឬ ។ អើ ។ វិបាកក្តី ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មានវិបាកជាប្រក្រតីក្តី វិបាកក្តី ជាធម៌ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧៦៥) វិបាក ជាធម៌មានវិបាកជាប្រក្រតីឬ ។ អើ ។ អកុសលនោះឯង ជាវិបាកនៃអកុសលនោះ កុសលនោះឯង ជាវិបាកនៃកុសលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៤៦] វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ យេនេវ ចិត្តេន បាណំ ហនតិ តេនេវ ចិត្តេន និរយេ បច្ចតិ យេនេវ ចិត្តេន ទានំ ទេតិ តេនេវ ចិត្តេន សគ្គេ មោទតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៤៧] ន វត្តព្វំ វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ ននុ វិបាកា ចត្តារោ ខន្ធា អរូបិនោ អញ្ញមញ្ញប្បច្ចយាតិ ។ អាមន្តា ។ ហញ្ចិ វិបាកា ចត្តារោ ខន្ធា អរូបិនោ អញ្ញមញ្ញប្បច្ចយា តេន វត រេ វត្តព្វេ វិបាកោ វិបាកធម្មធម្មោតិ ។

វិបាកោ វិបាកធម្មធម្មោតិកថា ។

សត្តមោ វគ្គោ ។

តស្សុទ្ទានំ

សង្គហោ សម្បយុត្តោ ចេតសិកោ ធម្មោ ចេតសិកំ ទានំ បរិភោគមយំ បុញ្ញំ វឌ្ឍតិ ឥតោ ទិន្នេន តត្ថ យាបេន្តិ បថវី កម្មវិបាកោ ជរាមរណំ វិបាកោ ឆត្តិ អរិយធម្មវិបាកោ វិបាកោ វិបាកធម្មធម្មោតិ ។

---

[៧៤៦] វិបាក ជាធម៌ដែលមានវិបាកជាប្រក្រតីឬ ។ អើ ។ បុគ្គល សម្លាប់សត្វដោយចិត្តណា រមែងឆេះនៅក្នុងនរក ដោយចិត្តនោះឯង ឲ្យទានដោយចិត្តណា រមែងរីករាយក្នុងឋានសួគ៌ ដោយចិត្តនោះឯងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៤៧] បុគ្គលមិនគួរនិយាយថា វិបាក ជាធម៌ដែលមានវិបាកជាប្រក្រតីទេឬ ។ អើ ។ ក្រែង វិបាកទាំងឡាយ ជាខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យដល់គ្នានឹងគ្នាឬ ។ អើ ។ បើវិបាកទាំងឡាយ ជាខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យដល់គ្នានឹងគ្នា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិបាក ជាធម៌មានវិបាកជាប្រក្រតី ។

ចប់ វិបាកវិបាកធម្មធម្មោតិកថា ។

ចប់ សត្តមវគ្គ ។

ឧទ្ទាននៃសត្តមវគ្គនោះ គឺ

និយាយអំពី ការសង្គ្រោះ ១ ការប្រកបព្រម ១ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ១ ទានប្រព្រឹត្តទៅក្នុងចិត្ត ១ បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើន ១ ពួកប្រេត ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបត្តិវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីលោកនេះ ១ ប្រឹថពី ជាវិបាកនៃកម្ម ១ ជរានិងមរណៈ ជាវិបាក ១ វិបាកនៃអរិយធម៌ មិនមាន ១ វិបាក ជាធម៌មានវិបាកជាប្រក្រតី ១ ។

(៧៤៨) ឆ គតិយោតិ ។ អាមន្តា ។ ននុ បញ្ច គតិយោ វុត្តា ភគវតា និរយោ តិរច្ឆានយោនិ បិត្តិវិសយោ មនុស្សា ទេវាតិ ។ អាមន្តា ។ ហញ្ចិ បញ្ច គតិយោ វុត្តា ភគវតា និរយោ តិរច្ឆានយោនិ បិត្តិវិសយោ មនុស្សា ទេវា នោ ច វត រេ វត្តព្វេ ឆ គតិយោតិ ។

(៧៤៩) ឆ គតិយោតិ ។ អាមន្តា ។ ននុ កាលកញ្ចិកា អសុរា បេតានំ សមានវណ្ណា(១) សមានភោគា សមានាហារា សមានាយុកា បេតេហិ សហ អាវាហវិវាហំ គច្ឆន្តីតិ ។ អាមន្តា ។ ហញ្ចិ កាលកញ្ចិកា អសុរា បេតានំ សមានវណ្ណា សមានភោគា សមានាហារា សមានាយុកា បេតេហិ សហ អាវាហវិវាហំ គច្ឆន្តិ នោ ច វត រេ វត្តព្វេ ឆ គតិយោតិ ។

(៧៥០) ឆ គតិយោតិ ។ អាមន្តា ។ ននុ វេបចិត្តិបរិសា ទេវានំ សមានវណ្ណា សមានភោគា

១ ឯកច្ចេសុ វិភត្តិ អន្នកប្បាយំ ទិស្សតិ; វីមា ទុទ្ទសិតាតិ តក្កេត្វា ។

(៧៤៨) គតិ មាន ៦ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គតិ មាន ៥ គឺ នរក ១ កំណើតសត្វតិរច្ឆាន ១ បិត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គតិ មាន ៥ គឺ នរក ១ កំណើតសត្វតិរច្ឆាន ១ បិត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិ មាន ៦ ទេ ។

(៧៤៩) គតិ មាន ៦ ឬ ។ អើ ។ ក្រែងពួកកាលកញ្ជិកាសុរ មានវណ្ណៈស្មើគ្នា មានភោគៈគឺមេថុនស្មើគ្នា មានអាហារស្មើគ្នា មានអាយុស្មើគ្នានឹងពួកប្រេត ទៅកាន់អាវាហៈនិងវិវាហៈជាមួយនឹងពួកប្រេត ដែរឬ ។ អើ ។ ប្រសិនបើ ពួកកាលកញ្ជិកាសុរ មានវណ្ណៈស្មើគ្នា មានភោគៈគឺមេថុនស្មើគ្នា មានអាហារស្មើគ្នា មានអាយុស្មើគ្នានឹងពួកប្រេត ទៅកាន់អាវាហៈនិងវិវាហៈជាមួយនឹងពួកប្រេត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិ មាន ៦ ទេ ។

(៧៥០) គតិ មាន ៦ ឬ ។ អើ ។ ក្រែង ពួកបរិស័ទរបស់ព្រះឡាវេបចិត្តិ មានវណ្ណៈស្មើគ្នា មានភោគៈគឺបញ្ចកាមគុណស្មើគ្នា

សមានាហារា សមានាយុកា ទេវេហិ សហ ឯកាហ-
វិហារំ គច្ឆន្តីតិ ។ អាមន្តា ។ ហញ្ចិ វេបចិត្តិបរិសា
ទេវានំ សមានវណ្ណា សមានភោគា សមានាហារា
សមានាយុកា ទេវេហិ សហ ឯកាហវិហារំ គច្ឆន្តិ
តេន វត រេ វត្តព្វេ ឆ គតិយោតិ ។

(៧៩១) ឆ គតិយោតិ ។ អាមន្តា ។ ននុ
វេបចិត្តិបរិសា បុព្វទេវាតិ ។ អាមន្តា ។ ហញ្ចិ
វេបចិត្តិបរិសា បុព្វទេវា តេន វត រេ វត្តព្វេ ឆ
គតិយោតិ ។

(៧៩២) ន វត្តព្វំ ឆ គតិយោតិ ។ អា-
មន្តា ។ ននុ អត្ថិ អសុរកាយោតិ ។ អាមន្តា ។
ហញ្ចិ អត្ថិ អសុរកាយោ តេន វត រេ វត្តព្វេ ឆ
គតិយោតិ ។

ឆគតិកថា ។

អន្តរាភវកថា

(៧៩៣) អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ កាម-
ភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អន្តរាភវោតិ ។
អាមន្តា ។ រូបភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

មានអាហារស្មើគ្នា មានអាយុស្មើគ្នានឹងពួកទេវតា ទៅកាន់ឯកាហៈនិង
វិហារៈជាមួយនឹងពួកទេវតាដែរឬ ។ អើ ។ ប្រសិនបើ ពួកបរិស័ទរបស់
ព្រះបាទវេបចិត្តិ មានវណ្ណៈស្មើគ្នា មានភោគៈគឺបញ្ចកាមគុណស្មើគ្នា
មានអាហារស្មើគ្នា មានអាយុស្មើគ្នានឹងពួកទេវតា ទៅកាន់ឯកាហៈនិង
វិហារៈជាមួយនឹងពួកទេវតា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិ
មាន ៦ ទេ ។

(៧៩១) គតិ មាន ៦ ឬ ។ អើ ។ ក្រែង ពួកបរិស័ទរបស់
ព្រះបាទវេបចិត្តិ ជាទេវតាដើមឬ ។ អើ ។ ប្រសិនបើ ពួកបរិស័ទ
របស់ព្រះបាទវេបចិត្តិ ជាទេវតាដើម ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរ
ពោលថា គតិ មាន ៦ ទេ ។

(៧៩២) បុគ្គលមិនគួរនិយាយថា គតិ មាន ៦ ទេឬ ។ អើ ។
ក្រែងអសុរកាយ មានដែរឬ ។ អើ ។ ប្រសិនបើ អសុរកាយ មាន
ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា គតិ មាន ៦ យ៉ាង ។

ចប់ ឆគតិកថា ។

អន្តរាភវកថា

(៧៩៣) អន្តរាភព (ភពដែលមានក្នុងចន្លោះបុគ្គលកើត) មានឬ ។
អើ ។ គឺកាមភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព
មានឬ ។ អើ ។ គឺរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អរូបភវេតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៨៤] អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ កាមភវស្ស ច រូបភវស្ស ច អន្តរេ អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ រូបភវស្ស ច អរូបភវស្ស ច អន្តរេ អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៨៥] កាមភវស្ស ច រូបភវស្ស ច អន្តរេ នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ហញ្ចិ កាមភវស្ស ច រូបភវស្ស ច អន្តរេ នត្ថិ អន្តរាភវោ នោ វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។ រូបភវស្ស ច អរូបភវស្ស ច អន្តរេ នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ហញ្ចិ រូបភវស្ស ច អរូបភវស្ស ច អន្តរេ នត្ថិ អន្តរាភវោ នោ វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។

[៧៨៦] អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ បញ្ចមី សា យោនិ ឆដ្ឋមី[១] សា គតិ អដ្ឋមី សា វិញ្ញាណដ្ឋិតិ ។

១ ម. ឆដ្ឋី ។

អន្តរាភព មានឬ ។ អើ ។ គឺអរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៨៤] អន្តរាភព មានឬ ។ អើ ។ អន្តរាភព មាន ក្នុងចន្លោះនៃកាមភពនិងរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព មានឬ ។ អើ ។ អន្តរាភព មាន ក្នុងចន្លោះនៃរូបភពនិងអរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៨៥] អន្តរាភព មិនមាន ក្នុងចន្លោះនៃកាមភពនិងរូបភពទេឬ ។ អើ ។ ប្រសិនបើ អន្តរាភព មិនមាន ក្នុងចន្លោះនៃកាមភពនិងរូបភពទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។ អន្តរាភព មិនមាន ក្នុងចន្លោះ នៃរូបភពនិងអរូបភពទេឬ ។ អើ ។ ប្រសិនបើ អន្តរាភព មិនមាន ក្នុងចន្លោះ នៃរូបភពនិងអរូបភពទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។

[៧៨៦] អន្តរាភព មានឬ ។ អើ ។ គឺកំណើតជាគម្រប់ ៥ នោះ គតិជាគម្រប់ ៦ នោះ វិញ្ញាណដ្ឋិតិជាគម្រប់ ៨ នោះ

ទសមោ សោ សត្តាវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អន្តរាភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អន្តរាភវូបគំ កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អន្តរាភវូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អន្តរាភវេ សត្តា ជាយន្តិ ជីយន្តិ មីយន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អន្តរាភវេ អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អន្តរាភវោ បញ្ចវោការភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧៤៧) អត្ថិ កាមភវោ កាមភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អត្ថិ អន្តរាភវោ អន្តរាភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កាមភវូបគំ កម្មន្តិ ។ អាមន្តា ។ អត្ថិ អន្តរាភវូបគំ កម្មន្តិ ។

សត្តាវាសៈជាគម្រប់ ១០ នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព មានឬ ។ អើ ។ អន្តរាភព គឺភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបាននូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូលទៅកើតក្នុងអន្តរាភព មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ ចូលទៅកើតក្នុងអន្តរាភព មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងអន្តរាភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧៤៧) កាមភព រមែងមាន ចុះកាមភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបាននូវអត្តភាព (មាន)ដែរឬ ។ អើ ។ អន្តរាភព រមែងមាន ចុះអន្តរាភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបាននូវអត្តភាព (មាន)ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូលទៅកើតក្នុងកាមភព មានដែរឬ ។ អើ ។ កម្ម នាំចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កាមភវូបគា សត្តាតិ ។ អាមន្តា ។ អត្ថិ អន្តរាភវូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមភវេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តិ ។ អាមន្តា ។ អន្តរាភវេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមភវេ អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ អាមន្តា ។ អន្តរាភវេ អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមភវោ បញ្ចវោការភវោតិ ។ អាមន្តា ។ អន្តរាភវោ បញ្ចវោការភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧៤៨) អត្ថិ រូបភវោ រូបភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អត្ថិ អន្តរាភវោ អន្តរាភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ រូបភវូបគំ កម្មន្តិ ។ អាមន្តា ។ អត្ថិ អន្តរាភវូបគំ កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ ចូលទៅកើតក្នុងកាមភព មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងកាមភពដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងកាមភពដែរឬ ។ អើ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមភព គឺបញ្ចវោការភពឬ ។ អើ ។ អន្តរាភព គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧៤៨) រូបភព រមែងមាន ចុះរូបភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព (មាន) ដែរឬ ។ អើ ។ អន្តរាភព រមែងមាន ចុះអន្តរាភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព (មាន) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូលទៅកើតក្នុងរូបភព មានដែរឬ ។ អើ ។ កម្ម នាំចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អត្ថិ រូបភវូបគា សត្តាតិ ។ អាមន្តា ។ អត្ថិ អន្តរា-ភវូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបភវេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ អាមន្តា ។ អន្តរាភវេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបភវេ អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ អាមន្តា ។ អន្តរាភវេ អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបភវោ បញ្ចវោការភវោតិ ។ អាមន្តា ។ អន្តរាភវោ បញ្ច-វោការភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧៥៩) អត្ថិ អរូបភវេ អរូបភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភា-វប្បដិលាភោតិ ។ អាមន្តា ។ អត្ថិ អន្តរាភវេ អន្តរា-ភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អរូបភវូបគំ កម្មន្តិ ។ អាមន្តា ។ អត្ថិ អន្តរាភវូបគំ កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ពួកសត្វ ចូលទៅកើតក្នុងរូបភព មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងរូបភពដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងរូបភពដែរឬ ។ អើ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូបភព គឺបញ្ចវោការភពឬ ។ អើ ។ អន្តរាភព គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧៥៩) អរូបភព រមែងមាន ចុះអរូបភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ ទីងការបានចំពោះនូវអត្តភាព (មាន)ដែរឬ ។ អើ ។ អន្តរាភព រមែងមាន ចុះអន្តរាភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ ទីងការបានចំពោះនូវអត្ត-ភាព (មាន)ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូលទៅកើតក្នុងអរូបភព មានដែរឬ ។ អើ ។ កម្ម នាំចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អត្ថិ អរូបភវូបគា សត្តាតិ ។ អាមន្តា ។ អត្ថិ អន្តរាភវូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរូបភវេ សត្តា ជាយន្តិ ជីយន្តិ មីយន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ អាមន្តា ។ អន្តរាភវេ សត្តា ជាយន្តិ ជីយន្តិ មីយន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរូបភវេ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ អាមន្តា ។ អន្តរាភវេ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរូបភវោ ចតុវោការភវោតិ ។ អាមន្តា ។ អន្តរាភវោ ចតុវោការភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៧៦០) អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ សព្វេសញ្ញេវ សត្តានំ អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វេសញ្ញេវ សត្តានំ នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ហញ្ចិ សព្វេសញ្ញេវ សត្តានំ នត្ថិ អន្តរាភវោ នោ ច វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។

ពួកសត្វ ចូលទៅកើតក្នុងអរូបភព មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអរូបភពដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងអរូបភពដែរឬ ។ អើ ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អរូបភព គឺចតុវោការភពឬ ។ អើ ។ អន្តរាភព គឺចតុវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧៦០) អន្តរាភព មានដែរឬ ។ អើ ។ អន្តរាភព របស់ពួកសត្វទាំងអស់ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព របស់ពួកសត្វទាំងអស់ មិនមានទេឬ ។ អើ ។ ប្រសិនបើ អន្តរាភព របស់ពួកសត្វទាំងអស់ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។

(៧៦១) អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អានន្តរិយស្ស បុគ្គលស្ស អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។បេ។ អានន្តរិយស្ស បុគ្គលស្ស នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ហញ្ចិ អានន្តរិយស្ស បុគ្គលស្ស នត្ថិ អន្តរាភវោ នោ វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។

(៧៦២) ន អានន្តរិយស្ស បុគ្គលស្ស អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អានន្តរិយស្ស បុគ្គលស្ស អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។បេ។ អានន្តរិយស្ស បុគ្គលស្ស នត្ថិ អន្តរាភវោតិ ។ អា-មន្តា ។ ន អានន្តរិយស្ស បុគ្គលស្ស នត្ថិ អន្តរា-ភវោតិ ។ ន ហេវំ វត្តព្វេ ។បេ។ និរយូបគស្ស បុគ្គលស្ស ។បេ។ អសញ្ញសត្តូបគស្ស បុគ្គលស្ស ។បេ។ អរូបូបគស្ស បុគ្គលស្ស អត្ថិ អន្តរាភវោ-តិ ។ ន ហេវំ វត្តព្វេ ។បេ។ អរូបូបគស្ស បុគ្គ-លស្ស នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ហញ្ចិ អរូបូបគស្ស បុគ្គលស្ស នត្ថិ អន្តរាភវោ នោ វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។

(៧៦១) អន្តរភព មានដែរឬ ។ អើ ។ អន្តរភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេឬ ។ អើ ។ ប្រសិនបើ អន្តរភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរភព មានទេ ។

(៧៦២) អន្តរភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេឬ ។ អើ ។ អន្តរភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេឬ ។ អើ ។ អន្តរភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមែនជាមិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរភព របស់បុគ្គលអ្នកចូលទៅកើតក្នុងនរក (មាន) ។បេ។ របស់បុគ្គលអ្នកចូលទៅកើតក្នុងអសញ្ញសត្វ (មាន) ។បេ។ របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមានទេឬ ។ អើ ។ ប្រសិនបើ អន្តរភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរភព មានទេ ។

អន្តរាភវកថា

[៧៦៣] ន អរូបូបគស្ស បុគ្គលស្ស អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អរូបូបគស្ស បុគ្គលស្ស អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។បេ។ អរូបូបគស្ស បុគ្គលស្ស នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ន អរូបូបគស្ស បុគ្គលស្ស នត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៧៦៤] ន វត្តព្វំ អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ននុ អន្តរាបរិនិព្វាយី បុគ្គលោ អត្ថីតិ ។ អាមន្តា ។ ហញ្ចិ អន្តរាបរិនិព្វាយី បុគ្គលោ អត្ថិ តេន វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។ អន្តរាបរិនិព្វាយី បុគ្គលោ អត្ថីតិ កត្វា អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ឧបហច្ចបរិនិព្វាយី បុគ្គលោ អត្ថីតិ កត្វា អត្ថិ ឧបហច្ចភវោតិ ។ ន ហេវំ វត្តព្វេ ។បេ។ អន្តរាបរិនិព្វាយី បុគ្គលោ អត្ថីតិ កត្វា អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អសង្ខារបរិនិព្វាយី បុគ្គលោ ។បេ។ សសង្ខារបរិនិព្វាយី បុគ្គលោ អត្ថីតិ កត្វា អត្ថិ សសង្ខារភវោតិ ។ ន ហេវំ វត្តព្វេ ។បេ។

អន្តរាភវកថា ។

អន្តរាភវកថា

[៧៦៣] អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមានទេឬ ។ អើ ។ អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមានទេឬ ។ អើ ។ អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមែនជាមិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

[៧៦៤] បុគ្គលមិនគួរនិយាយថា អន្តរាភព មានទេឬ ។ អើ ។ ក្រែង បុគ្គល ជាអន្តរាបរិនិព្វាយី មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គល ជាអន្តរាបរិនិព្វាយី មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។ អន្តរាភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គល ជាអន្តរាបរិនិព្វាយី មានឬ ។ អើ ។ ឧបហច្ចភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គល ជាឧបហច្ចបរិនិព្វាយី មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អន្តរាភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គល ជាអន្តរាបរិនិព្វាយី មានឬ ។ អើ ។ បុគ្គល ជាអសង្ខារបរិនិព្វាយី ។បេ។ សសង្ខារភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គល ជាសសង្ខារបរិព្វាយី មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ អន្តរាភវកថា ។

កាមគុណកថា

(៧៦៨) បញ្ចេវ កាមគុណា កាមធាតូតិ ។ អាមន្តា ។ ននុ អត្ថិ តប្បដិសំយុត្តោ ឆន្ទោតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ តប្បដិសំយុត្តោ ឆន្ទោ នោ វត រេ វត្តព្វេ បញ្ចេវ កាមគុណា កាមធាតូតិ ។ ននុ អត្ថិ តប្បដិសំយុត្តោ រាគោ តប្បដិសំយុត្តោ ឆន្ទរាគោ តប្បដិសំយុត្តោ សង្កប្បោ តប្បដិសំយុត្តោ រាគោ តប្បដិសំយុត្តោ សង្កប្បរាគោ តប្បដិសំយុត្តា បីតិ តប្បដិសំយុត្តំ សោមនស្សំ តប្បដិសំយុត្តំ បីតិសោមនស្សន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ តប្បដិសំយុត្តំ បីតិសោមនស្សំ នោ វត រេ វត្តព្វេ បញ្ចេវ កាមគុណា កាមធាតូតិ ។

(៧៦៩) បញ្ចេវ កាមគុណា កាមធាតូតិ ។ អាមន្តា ។ មនុស្សានំ ចក្ខុំ ន កាមធាតូតិ ។ ន ហេវំ វត្តព្វេ ។បេ។ មនុស្សានំ សោតំ ។បេ។ មនុស្សានំ ឃានំ ។បេ។ មនុស្សានំ ជិវ្ហា ។បេ។ មនុស្សានំ កាយោ ។បេ។ មនុស្សានំ មនោ ន កាមធាតូតិ ។

កាមគុណកថា

(៧៦៨) កាមគុណ ៥ ជាកាមធាតុឬ ។ អើ ។ ក្រែងឆន្ទៈ ប្រកបដោយកាមគុណនោះ មានដែរឬ ។ អើ ។ ប្រសិនបើឆន្ទៈ ប្រកបដោយកាមគុណនោះ មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាមគុណ ៥ ជាកាមធាតុទេ ក្រែងរាគៈ ប្រកបដោយកាមគុណនោះ ឆន្ទរាគៈ ប្រកបដោយកាមគុណនោះ សង្កប្បៈ ប្រកបដោយកាមគុណនោះ រាគៈ ប្រកបដោយកាមគុណនោះ សង្កប្បរាគៈ ប្រកបដោយកាមគុណនោះ បីតិ ប្រកបដោយកាមគុណនោះ សោមនស្ស ប្រកបដោយកាមគុណនោះ បីតិសោមនស្ស ប្រកបដោយកាមគុណនោះ មានដែរឬ ។ អើ ។ ប្រសិនបើ បីតិសោមនស្ស ប្រកបដោយកាមគុណនោះ មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាមគុណ ៥ ជាកាមធាតុទេ ។

(៧៦៩) កាមគុណ ៥ ជាកាមធាតុឬ ។ អើ ។ ចក្ខុ របស់ពួកមនុស្ស មិនមែនជាកាមធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ត្រចៀក របស់ពួកមនុស្ស ។បេ។ ច្រមុះ របស់ពួកមនុស្ស ។បេ។ អណ្តាត របស់ពួកមនុស្ស ។បេ។ កាយ របស់ពួកមនុស្ស ។បេ។ ចិត្ត របស់ពួកមនុស្ស មិនមែនជាកាមធាតុទេឬ ។ អ្នក

ន ហេវំ វត្តព្វេ ។ បេ ។ មនុស្សានំ មនោ ន កាម-
ធាតូតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

បញ្ច កាមគុណា លោកេ មនោឆដ្ឋា បវេទិតា
ឯត្ថ ឆន្ទំ វិរាជេត្វា ឯវំ ទុក្ខា បមុច្ចតីតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ
មនុស្សានំ មនោ ន កាមធាតូតិ ។

[៧៦៧] បញ្ចេវ កាមគុណា កាមធាតូតិ ។
អាមន្តា ។ កាមគុណា ភវោ គតិ សត្តាវាសោ
សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។
ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កាមគុណូបគំ
កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កាម-
គុណូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
កាមគុណេ សត្តា ជាយន្តិ ជីយន្តិ មីយន្តិ ចវន្តិ
ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមគុណេ
អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ
វត្តព្វេ ។ បេ ។ កាមគុណា បញ្ចវោការភវោតិ ។

៣១៩
កាមគុណកថា

មិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចិត្ត របស់ពួកមនុស្ស មិនមែនជា
កាមធាតុទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

កាមគុណ ៥ មានចិត្តជាគម្រប់ ៦ តថាគត សំដែងទុក
ក្នុងលោក បុគ្គល កំចាត់បង់ឆន្ទៈ ក្នុងកាមគុណទាំងនុ៎ះ រមែង
រួចចាកទុក្ខ ដោយហេតុយ៉ាងនេះឯង

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នក
មិនគួរពោលថា ចិត្ត របស់ពួកមនុស្ស មិនមែនជាកាមធាតុទេ ។

[៧៦៧] កាមគុណ ៥ ជាកាមធាតុឬ ។ អើ ។ កាមគុណ
ជាភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ ឱកាសបាន
ចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូល
ទៅកើតក្នុងកាមគុណ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
ពួកសត្វ ចូលទៅកើតក្នុងកាមគុណ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាង
នេះទេ ។ បេ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ
ក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប
វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងកាមគុណដែរឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមគុណ គឺបញ្ចវោការភពឬ ។

